**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# រដ្ឋបាល និងការគោរពច្បាប់

## ( ជ្រុងទស្សនៈផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅកម្ពុជា )

ស្រាវជ្រាវ ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៤


ស្រាវជ្រាវដោយ៖
និស្សិតឈ្មោះ **ឃុន សុគន្ធាវី**
**តឹក សិរីវិចិត្រ**

សាស្ត្រាចារ្យណែនាំ
លោក **ឡើក ពិដោរ**


ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ
ជំនាន់ទី១៤

ឆ្នាំចូលសិក្សា ២០១០
ឆ្នាំសរសេរសារណា ២០១៤

# អារម្ភកថា

ប្រធានបទសារណា ដែលយើងខ្ញុំទាំងពីរនាក់ បានលើកយកមកសរសេរនេះ មានឈ្មោះថា "**រដ្ឋបាល និងការគោរពច្បាប់**" បានដកស្រង់ និងសរសេរជាសៀវភៅនេះឡើង ដោយធ្វើការពិពណ៌នាអំពីទិដ្ឋភាពទូទៅមួយចំនួននៃរដ្ឋបាលសាធារណៈរបស់រដ្ឋ និងធ្វើការវិភាគឱ្យស៊ីជម្រៅអំពីបច្ចេកទេសរដ្ឋបាលរបស់រដ្ឋ តាំងអំពីថ្នាក់មូលដ្ឋាន រហូតដល់ថ្នាក់កណ្តាល ដោយប្រៀបធៀបជាមួយនឹងបច្ចេកទេសរដ្ឋបាលនៃរដ្ឋទំនើប ជឿនលឿនមួយចំនួននៅក្នុងពិភពលោកផងដែរ ជាពិសេស សំដៅធានាឱ្យបាននូវការគោរពនីត្យនុកូលភាពនៃរដ្ឋបាល។

ឆ្លងតាមការសិក្សា អស់រយៈពេល ៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងការស្រាវជ្រាវឯកសារផ្សេងៗ ព្រមទាំងបានទទួលការណែនាំយ៉ាងយកចិត្តទុកដាក់ពីលោកសាស្ត្រាចារ្យ **ខឿក ពិដោរ** បានផ្តល់ជាចំណេះដឹងដើម្បីចងក្រងជាសារណានេះឡើង។

សារណានេះបានពិពណ៌នាយ៉ាងលម្អិត ដោយផ្អែកតាមច្បាប់រដ្ឋបាល គោលការណ៍ទូទៅនៃច្បាប់ និងទ្រឹស្តីរបស់អ្នកប្រាជ្ញខាងរដ្ឋបាល ទាំងជាតិ និងអន្តរជាតិជាច្រើន។ កាលបើប្រទេសមាន "**នីតិរដ្ឋ**" ពិតណាស់ទៅហើយថា រដ្ឋបាលរបស់ខ្លួន ពិតជាគោរពបាននូវនីត្យាភាពទាំងបច្ចេកទេស និងនយោបាយ។

រដ្ឋបាលគឺជាឧបករណ៍នៃអង្គការ និងស្ថាប័ននយោបាយដែលតំណាងឱ្យអំណាចរដ្ឋ។ ក្នុងឋានៈជាឧបករណ៍ ជាយន្តការបច្ចេកទេសនានារបស់រដ្ឋ ជាគោលការណ៍ រដ្ឋបាលប្រើអ្នកបច្ចេកទេសខុសពីអ្នកនយោបាយ ក្នុងការធ្វើសកម្មភាពរបស់ខ្លួន។

យើងខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា ការចងក្រងជាសារណាបញ្ចប់ការសិក្សាមួយនេះនឹងជួយជម្រុញដល់កិច្ចការរដ្ឋបាលរបស់មន្ត្រីរាជការដែលផ្តល់សេវាសាធារណៈ ជូនដល់រាស្ត្រប្រជា ឱ្យកាន់តែបច្ចេកទេស មានភាពប្រសើរជឿនលឿន ស្របតាមបទដ្ឋានគតិយុត្ត និងគោលការណ៍ទូទៅនៃច្បាប់ ធានាបាននូវប្រយោជន៍ទូទៅ និងសិទ្ធិសេរីភាពបុគ្គលឯកជន ដែលជាគោលការណ៍ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជាយើង។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់ជឿជាក់ថាសារណានេះ ក៏នឹងជាវិភាគទានដ៏សំខាន់ផងដែរ សម្រាប់សិស្សនិស្សិត និងអ្នកទាំងឡាយដែលត្រូវការចំណេះដឹងបន្ថែម សម្រាប់ការសិក្សាស្រាវជ្រាវរបស់ខ្លួន។ យើងខ្ញុំ រីករាយទទួលយកដោយក្តីសោមនស្ស នូវរាល់ការរិះគន់ដើម្បីស្ថាបនារបស់មិត្តអ្នកអានទាំងអស់។

យើងខ្ញុំ ក៏សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង** សាស្ត្រាចារ្យ ទាំងអស់ ជាពិសេស លោកសាស្ត្រាចារ្យ **ខឿក ពិដោរ** ជួបប្រទះតែនឹងសេចក្តីសុខ សុភមង្គល។

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **តឹក សិរីវិចិត្រ** និង **កញ្ញា យុន សុគន្ធារី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ១៤ នៃសាកលវិទ្យាភូមិន្ទនីសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១០-២០១៤៖

**សូមលំឱនកាយសម្ដែងនូវកត្តាញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ**

លោកអ្នកមានគុណ លោកឪពុក អ្នកម្ដាយ ដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅ ព្រមទាំងលះបង់គ្រប់បែបយ៉ាង ទាំងពេលវេលា ទាំងកម្លាំងកាយចិត្ត បញ្ញាស្មារតី ផ្គត់ផ្គង់ ឧបត្ថម្ភ និងលើកទឹកចិត្តគ្រប់ពេលវេលា រហូតយើងខ្ញុំបានបញ្ចប់ថ្នាក់ឧត្ដមសិក្សា និងទទួលបានជោគជ័យយ៉ាងត្រចះត្រចង់។ គុណូបការៈ និងព្រហ្មវិហាធម៌របស់លោកអ្នកមានគុណចំពោះយើងខ្ញុំ មានទំហំធំធេង ស្ថិតនៅក្នុងដួងចិត្តរបស់យើងខ្ញុំជានិរន្តន៍។

ឯកឧត្ដម **សាកលវិទ្យាធិការ សាកលវិទ្យាធិការរង** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ ដែលផ្ដល់ភាពងាយស្រួល និងឱកាសដល់យើងខ្ញុំ រហូតបានសម្រេចនូវសារណាបញ្ចប់ការសិក្សានេះឡើង។

សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ដែលបានខិតខំបង្ហាត់បង្រៀនយើងខ្ញុំតាំងពីបឋមសិក្សា រហូតដល់ឧត្ដមសិក្សា ធ្វើឱ្យយើងខ្ញុំទទួលបាននូវចំណេះដឹងដ៏មានតម្លៃវិសេសវិសាល ព្រមទាំងជាបទពិសោធន៍ល្អៗ។

យើងខ្ញុំសូមថ្លែងអំណរអរគុណជាពិសេស ដល់លោកសាស្ត្រាចារ្យ **ឡើក ពិដោរ** លោកជាសាស្ត្រាចារ្យដែលមានបទពិសោធន៍ និងចំណេះជំនាញយ៉ាងពិតប្រាកដ ផ្នែកនីតិសាធារណៈ ជាពិសេស នីតិរដ្ឋបាល អាស្រ័យដោយការចងក្រងជាសៀវភៅដ៏មានតម្លៃ ដែលត្រូវបានមជ្ឈដ្ឋានទូទៅទទួលស្គាល់ជាច្រើន ដូចជានីតិអន្តរជាតិសាធារណៈ នីតិរដ្ឋបាលទូទៅជាដើម។ លោកសាស្ត្រាចារ្យ បានចំណាយអស់ពីកម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃដូចពេជ្ររបស់លោក ក្នុងការដឹកនាំការចងក្រងសារណារបស់យើងខ្ញុំ រហូតបានសម្រេច ទទួលបានជោគជ័យជាស្ថាពរ។

យើងខ្ញុំ សូមបួងសួងដល់អស់ទេពតា វត្ថុស័ក្ដសិទ្ធក្នុងលោក សូមជួយថែរក្សាលោកអ្នកមានគុណ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ឱ្យជួបប្រទះនូវពុទ្ធពរគ្រប់ប្រការ។

យើងខ្ញុំ សូមគោរពជូនពរ **ឯកឧត្ដមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង** លោកព្រឹទ្ធបុរស លោកសាស្ត្រាចារ្យ ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលោកប្រកបដោយសេចក្ដីសុខ ចំរើនថ្កាន ទទួលបានជោគជ័យលើគ្រប់ភារកិច្ច ដើម្បីរួមចំណែកបណ្ដុះបណ្ដាលធនធានមនុស្ស ស្ថាបនាប្រទេសជាតិ ឈានទៅរកសុខសន្តិភាព ចម្រុងចម្រើនជានិច្ចនិរន្តន៍តរៀងទៅ។

# មាតិកា

**សេចក្តីថ្លែងអំណរគុណ**

**អារម្ភកថា**

**មាតិកា**

**សេចក្តីផ្តើម ........................................................................................................ ០១**

**ជំពូក ១ រដ្ឋបាលកំណត់ដោយក្របខណ្ឌវិធានពិសេស ៖ នីតិរដ្ឋបាល ............០៣**

**ផ្នែក ១ រដ្ឋបាលត្រូវគោរពនីតិរដ្ឋបាល ៖ ហេតុអ្វី? ..........................................០៣**

**កថាខណ្ឌ ១ នីតិរដ្ឋបាលប្រៀបធៀប ................................................................ ០៥**

១.នីតិវិធីរដ្ឋបាល ........................................................................................ ០៦

២.វង្វង់សកម្មភាពរដ្ឋបាល..................................................................................០៧

៣.តើរដ្ឋបាលនៅកម្ពុជាស្ថិតនៅក្រោមនីតិរដ្ឋបាលដែរឬទេ?................................ ០៩

**កថាខណ្ឌ ២ លក្ខណៈនៃនីតិរដ្ឋបាល...................................................................១០**

១.លក្ខណៈសំខាន់ៗ...................................................................................... ១០

**កថាខណ្ឌ ៣ ៖ ការវិវត្តថ្មីៗនៃនីតិរដ្ឋបាល ......................................................... ១១**

ក.ការប្រជុំនៃប្រភពផ្សេងៗទៀតនៃច្បាប់ ........................................................ ១១

ខ.លក្ខណៈវិសមភាពនៃនីតិរដ្ឋបាលកាន់តែត្រូវបានទទួលយកតិចទៅៗ .......... ១២

**ផ្នែក ២ រដ្ឋបាលត្រូវគោរពការណ៍នីត្យានុកូលភាព ៖**

**ទិសដៅថ្មីនៃនីតិរដ្ឋបាល ....................................................................................១២**

**កថាខណ្ឌ ១ ការគោរពនៃនីត្យានុកូលភាពជាឋានានុក្រមដោយរដ្ឋបាល .......១៣**

១.បទដ្ឋាននៅក្រៅរដ្ឋបាល ..................................................................................១៣

ក.រដ្ឋធម្មនុញ្ញ........................................................................................................១៣
ខ.សន្ធិសញ្ញាអន្តរជាតិ ....................................................................................... ១៦
គ.ច្បាប់ ........................................................................................................... ១៦
ឃ.គោលការណ៍ទូទៅនៃច្បាប់ ............................................................................. ១៨
ង.យុត្តិសាស្ត្រ ..................................................................................................... ១៨
២.បទដ្ឋានដែលចេញដោយរដ្ឋបាលខ្លួនឯងផ្ទាល់ (បទបញ្ជា)................................. ១៩
ក.ព្រះរាជក្រឹត្យ....................................................................................................២០
ខ.អនុក្រឹត្យ ......................................................................................................... ២០
គ.ប្រកាស............................................................................................................២១
ឃ.ដីកា ...............................................................................................................២១
**កថាខណ្ឌ ២ ៖ ការអនុវត្តប្រែប្រួលនៃគោលការណ៍នីត្យានុកូលភាព............២១**
**១.សមត្ថកិច្ចជាប់ចំណងរបស់រដ្ឋបាល**................................................................២២
**២.អំណាចឆន្ទានុសិទ្ធិរបស់រដ្ឋបាល** ................................................................... ២៣
៣.ករណីបន្ទាន់ ឬកាលៈទេសៈពិសេស ៖ កាសម្រេចតម្រូវនៃគោលការណ៍ នីត្យានុកូលភាព.................................................................................................................... ២៤
៣.១.ទ្រឹស្តីយុត្តិសាស្ត្រនៃកាលៈទេសៈពិសេស ............................................................ ២៤
៣.១.១.សញ្ញានៃកាលៈទេសៈពិសេស........................................................................ ២៥
៣.១.២.អានុភាពនៃកាលៈទេសៈពិសេស ...................................................................២៧
៣.២.វិធានធម្មតានៃសមត្ថកិច្ច..................................................................................២៧

៣.៣.វិធានទម្រង់.....................................................................២៧

៣.៤.ការគោរពគោលការណ៍គ្រឹះ.......................................................២៧

៣.៤.១.របបដែលរៀបចំកាលៈទេសៈពិសេស ...............................២៨

ក.វិក្រឹតិកាល...............................................................................២៨

ខ.ស្ថានភាពបន្ទាន់ .......................................................................២៩

**ជំពូក ២ ការត្រួតពិនិត្យនៃសកម្មភាពរដ្ឋបាល ...................................៣០**

**ផ្នែក ១ ការត្រួតពិនិត្យតាមផ្លូវតុលាការ.............................................៣១**

**កថាខណ្ឌ ១ យុត្តិធម៌រដ្ឋបាល ៖ ការត្រួតពិនិត្យតាមផ្លូវតុលាការ ..................៣១**

**កថាខណ្ឌ ២ យុត្តិធម៌រដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជា...........................៣២**

**ផ្នែក ២ ការត្រួតពិនិត្យមិនមែនតុលាការ ...............................................៣៤**

**កថាខណ្ឌ ១ ការត្រួតពិនិត្យផ្ទៃក្នុង ......................................................៣៤**

ក.ការត្រួតពិនិត្យតាមរយៈបណ្តឹងរដ្ឋបាល.....................................................៣៤

ខ.ការត្រួតពិនិត្យដោយអាគារធិការកិច្ច .......................................................៣៥

គ.ការត្រួតពិនិត្យហិរញ្ញវត្ថុ.......................................................................៣៥

ឃ.ការត្រួតពិនិត្យដោយអភិបាលហិរញ្ញវត្ថុ.....................................................៣៥

**កថាខណ្ឌ ២ ការត្រួតពិនិត្យផ្ទៃក្រៅ......................................................៣៧**

១.ការត្រួតពិនិត្យរបស់រដ្ឋ លើរដ្ឋបាលស្វយ័ត ...........................................៣៧

ក.ការត្រួតពិនិត្យរបស់សភា...................................................................៣៨

ខ.ការត្រួតពិនិត្យដោយអាជ្ញាធររដ្ឋបាលឯករាជ្យ ....................................៣៩

❖ អាជ្ញាធររដ្ឋបាលឯករាជ្យ ............................................................... ៣៩
❖ អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ....................................................... ៤០
❖ មុខងារសាធារណៈ........................................................................ ៤២

**សេចក្តីសន្និដ្ឋាន** ........................................................................ **៤៤**

**អនុសាសន៍** ............................................................................. **៤៦**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

**សន្ទានុក្រម**

# សេចក្តីផ្តើម

ទាំងរដ្ឋប្រជាធិបតេយ្យសេរី និងរដ្ឋប្រជាធិបតេយ្យតាមបែបម៉ាក្សិស សុទ្ធតែមានរដ្ឋបាលដូចគ្នា ពីព្រោះរដ្ឋបាល ជាឧបករណ៍នៃស្ថាប័ននយោបាយ បម្រើស្ថាប័ននយោបាយ ជាពិសេសបំពេញបេសកកម្មនៃផលប្រយោជន៍ទូទៅ តាមជ្រុងទស្សនៈបច្ចេកទេស គូសវាសដោយស្ថាប័ននយោបាយ ដែលជាក្បាលម៉ាស៊ីនរបស់រដ្ឋ។ ស្របគ្នាទៅនឹងពាក្យស្លោកមួយ ដែលនិយាយថា "គ្រប់សង្គមទាំងអស់ ត្រូវការច្បាប់ ហើយច្បាប់ជាផ្លែផ្កានៃសង្គម" ដូចគ្នានេះដែរ ឧទាហរណ៍រដ្ឋបាលរបស់រដ្ឋ ពោលគឺ យន្តការបច្ចេកទេសរបស់រដ្ឋ ដាច់ខាតត្រូវស្ថិតនៅក្រោមវិធាននៃច្បាប់។ ប៉ុន្តែ របៀបនៃការគោរពច្បាប់របស់រដ្ឋប្រជាធិបតេយ្យសេរី ខុសពីរបៀបនៃការគោរពច្បាប់ នៃរដ្ឋមិនប្រជាធិបតេយ្យ។ ភាពខុសគ្នាទាំងនេះ ស្ថិតនៅត្រង់ថា ក្នុងរដ្ឋប្រជាធិតេយ្យសេរី អាជ្ញាធររដ្ឋបាល ក្នុងសេចក្តីសម្រេចរបស់ខ្លួនដែលខ្លួនចេញ ត្រូវស្របនឹងច្បាប់ ឬឱ្យចំពិតប្រាកដនោះត្រូវស្របនឹងនីត្យានុកូលភាព ពោលគឺ "ត្រូវស្របទៅនឹងវិធាននីតិទាំងអស់ របស់រដ្ឋ[១]... ។"

កាលណាអាជ្ញាធររដ្ឋបាល មុននឹងចេញសេចក្តីសម្រេច ត្រូវផ្អែកលើវិធាននីតិជាធរមានយ៉ាងដូចនេះ គេថា អាជ្ញាធររដ្ឋបាល គោរពនីត្យានុកូលភាព ឬនីតិរដ្ឋ ផ្ទុយទៅនឹងរដ្ឋនគរបាលជាភាសាអាល្លឺម៉ង់ គឺ (Polizeistaat)[២] ដែលបញ្ជាក់ថាអាជ្ញាធររដ្ឋបាល ចេញសេចក្តីសម្រេចទៅតាមទំនើងចិត្ត ឬទៅតាមអំណាចផ្តាច់ការរបស់ខ្លួន។

ក្នុងបរិបទនៃព្រះរាជាណាចក្រកម្ពុជាវិញ ដោយយោងតាមបុព្វកថានៃរដ្ឋធម្មនុញ្ញ ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ គោលការណ៍លទ្ធិប្រជាធិបតេយ្យសេរី ត្រូវយកមកអនុវត្តដូចបណ្តាលរដ្ឋប្រជាធិបតេយ្យសេរីទាំងអស់ នៅលើពិភពលោកដែរ។ គោលការណ៍នេះ ដាក់បង្ខំឱ្យអាជ្ញាធររដ្ឋបាលត្រូវគោរពវិធាននីតិ ក្នុងសេចក្តីសម្រេចរបស់ខ្លួនដែលត្រូវចេញ។ មាត្រា ១៥០ថ្មី ចែងថា "ច្បាប់ និងរាល់សេចក្តីសម្រេចរបស់ស្ថាប័នសាធារណៈ ដាច់ខាតត្រូវស្របនឹងរដ្ឋធម្មនុញ្ញ។"

ក្នុងករណី អាជ្ញាធររដ្ឋបាលរំលោភច្បាប់របស់រដ្ឋ អាជ្ញាធររដ្ឋបាល ត្រូវទទួលខុសត្រូវនៅចំពោះមុខតុលាការ (មាត្រា ៣៩ និង មាត្រា ១២៨ថ្មី នៃរដ្ឋធម្មនុញ្ញដដែល)។

នៅទីនេះ ជាពិសេសសារណានេះ នឹងផ្តោតជាសំខាន់ទៅលើការគោរពរបស់រដ្ឋបាល ក្នុងជ្រុងទស្សនៈទ្រឹស្តីផង និងការអនុវត្តជាក់ស្តែងផង ឆ្លងតាមបទពិសោធន៍បរទេស។ ដូច្នេះ

[១] André de Laubadère, Traité de droit administratif, éd.15, L.G.D.J., 1999.

[២] L'étude du caractére d'Etat de droit de la RDC: coquille vide ou réalité? (www.memoireonline.com).

ការអត្ថាធិប្បាយនៃសារណាចំពោះមុខនេះ នឹងកំណត់ពីវិសាលភាពរបស់វា ក្នុងពេលតែមួយលើទ្រឹស្តីច្បាប់ទូទៅ ខាងការគ្រប់គ្រងនៃរដ្ឋបាលសាធារណៈរបស់រដ្ឋ និងការអនុវត្តជាក់ស្តែងទាំងនៅបរទេស និងនៅព្រះរាជាណាចក្រកម្ពុជា ចាប់ពីឆ្នាំ ១៩៩៣ មក។

នីត្យានុកូលភាព មានន័យពីរយ៉ាង ៖ ន័យទីមួយ នីត្យានុកូលភាព គឺភាពស្របទៅនឹងច្បាប់ គឺអ្វីដែលច្បាប់ចែង។ ឧទាហរណ៍ នីត្យានុកូលភាពនៃពន្ធដារ (មាត្រា ៥៧ នៃរដ្ឋធម្មនុញ្ញ ១៩៩៣)។ ន័យទីពីរ នីត្យានុកូលភាពតាម Hans Kelsen គឺការគោរពលិខិតបទដ្ឋានគតិយុត្ត ដែលមានអំណាចឋានានុក្រមទាបជាង ទៅនឹងលិខិតបទដ្ឋានគតិយុត្ត ដែលមានអំណាចគតិយុត្តខ្ពស់ជាងបន្ទាប់ដោយរបៀបនេះ រហូតដល់កំពូលនៃសាជីឋានានុក្រមនៃលិខិតបទដ្ឋានគតិយុត្ត[៣]។ ដូច្នេះ នីត្យានុកូលភាពរដ្ឋបាល តម្រូវឱ្យអាជ្ញាធររដ្ឋបាលដាក់ខ្លួននៅក្រោមវិធាននីតិទាំងអស់របស់រដ្ឋ ទៅតាមឋានានុក្រមរបស់វា ហើយជាពិសេស សេចក្តីសម្រេចរបស់រដ្ឋបាល ដាច់ខាតត្រូវស្របទៅនឹងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា ១៥០ នៃរដ្ឋធម្មនុញ្ញ)។

រដ្ឋបាល តំណាងឱ្យអធិបតេយ្យមួយផ្នែករបស់រដ្ឋ ដូច្នេះរាល់សកម្មភាពរបស់រដ្ឋបាល ត្រូវតែជាសកម្មភាពស្របច្បាប់ ដែលមានគោលបំណងបម្រើផលប្រយោជន៍ទូទៅ ស្របទៅនឹងឃ្លាដ៏ល្បីរបស់ Léon Duguit អ្នកទ្រឹស្តីបារាំងឯកទេសខាងនីតិសាធារណៈនៅដើមសតវត្សទី ២០ ៖ "សេវាសាធារណៈ [សកម្មភាពនៃផលប្រយោជន៍ទូទៅ គ្រប់គ្រង និងធានាដោយបុគ្គលសាធារណៈ] ជាឧទាហរណ៍នៃធម្មានុរូបកម្មរបស់រដ្ឋ"។ វិធានទាំងអស់ដែលរដ្ឋបាលត្រូវ គោរពក្នុងការបម្រើផលប្រយោជន៍ទូទៅ ឬ សកម្មភាពនៃសេវាសាធារណៈ បង្កើតបាននីតិមួយស្វយ័តពីនីតិផ្សេងទៀត ហៅថា "នីតិរដ្ឋបាល"។ កង្វល់ធំបំផុត គឺការគោរពប្រភពនៃច្បាប់ជាតិដោយរដ្ឋបាល ក៏ដូចជាការគោរពនីត្យានុកូលភាពរដ្ឋបាលដែរ។ ដើម្បីធានាឱ្យមានការគោរពច្បាប់នេះ យន្តការត្រួតពិនិត្យឯករាជ្យមួយ ត្រូវបង្កើតឡើង ទោះជាមានលក្ខណៈពិសេសក្តី (តុលាការរដ្ឋបាល) ឬ ជាតុលាការនៃនីតិរួមក្តី។

ដើម្បីបង្ហាញឱ្យឃើញច្បាស់សកម្មភាពនៃរដ្ឋបាលប្រជាធិបតេយ្យ ជាបឋម យើងត្រូវនិយាយ **ពីរដ្ឋបាលដែលកំណត់ដោយក្របខណ្ឌវិធានពិសេស (ជំពូក១)** និងបន្ទាប់មកទៀត **ការត្រួតពិនិត្យនៃសកម្មភាពរបស់រដ្ឋបាល(ជំពូក២) ។**

[៣] http://en.wikipedia.org/wiki/Hans_Kelsen.

# ជំពូក ១
# រដ្ឋបាលកំណត់ដោយក្របខណ្ឌវិធានពិសេស ៖ នីតិរដ្ឋបាល

គ្រប់រដ្ឋទាំងអស់សុទ្ធតែមានរដ្ឋបាលរបស់ខ្លួន ពីព្រោះរដ្ឋបាល ជាឧបករណ៍របស់រដ្ឋ ក្នុងការបម្រើផលប្រយោជន៍ទូទៅ។ រដ្ឋបាលប្រជាធិបតេយ្យ ត្រូវធ្វើសកម្មភាព ដែលត្រូវកំណត់ដោយច្បាប់ ដូច្នេះ រាល់វិធានទាំងអស់ដែលត្រូវអនុវត្តចំពោះការរៀបចំ និងការប្រព្រឹត្តិនៃរដ្ឋបាល បង្កើតបាននីតិរដ្ឋបាល។ ន័យនៃនីតិរដ្ឋបាល ក្នុងប្រទេសដែលមានប្រព័ន្ធច្បាប់ Civil Law មិនដូចគ្នានឹងន័យនៃនីតិរដ្ឋបាលក្នុងប្រទេសដែលមានប្រព័ន្ធច្បាប់ Common Law នោះទេ។ នីតិរដ្ឋបាលបារាំង ដើរមុខនីតិរដ្ឋបាលនៃប្រទេសដែលមានប្រព័ន្ធច្បាប់ Common Law បានន័យថា នីតិរដ្ឋបាលបារាំងបានកើតឡើងចាប់តាំងពីឆ្នាំ ១៧៩០ មួយឆ្នាំក្រោយពីបដិវត្តន៍បារាំង ផ្ទុយទៅវិញសកម្មភាពរដ្ឋបាលនៃប្រទេស Common Law ស្ថិតនៅក្រោមវិធាននៃនីតិរួម[៤]។ នៅទីនេះ យើងនឹងលើកយកមកនិយាយជាសំខាន់ នីតិរដ្ឋបាលរបស់បារាំង ដែលមានគោលបំណងពីរ ទីមួយ កំណត់ព្រំដែនសកម្មភាពនៃរដ្ឋបាល និងទីពីរ ការការពារផលប្រយោជន៍រាស្ត្រប្រជា។ តើរដ្ឋបាលតាមន័យនៃនីតិរដ្ឋបាលបារាំង ត្រូវស្ថិតនៅក្រោមនីតិរដ្ឋបាលយ៉ាងដូចម្ដេច?

## ផ្នែក១
## រដ្ឋបាលត្រូវគោរពនីតិរដ្ឋបាល ៖ ហេតុអ្វី?

សកម្មភាពនៃរដ្ឋបាលប្រជាធិបតេយ្យ ត្រូវធ្វើឡើងក្នុងក្របខណ្ឌនៃច្បាប់ ហើយប្រការនេះត្រូវធានាដោយតុលាការមួយ ទោះជាតុលាការពិសេសក្ដី តុលាការធម្មតាក្ដី។ នីតិរដ្ឋបាលកើតឡើងដោយសារវិធាននីតិទាំងអស់ ដែលត្រូវយកមកអនុវត្តចំពោះការរៀបចំ និងការប្រព្រឹត្តិទៅនៃរដ្ឋបាល។

នីតិរដ្ឋបាល ផ្អែកលើគំនិតជាមូលដ្ឋានងាយយល់ គឺគំនិតនៃឋានានុក្រមកម្មនៃផលប្រយោជន៍។ សកម្មភាពរដ្ឋបាល ខុសពីសកម្មភាពនៃបុគ្គលឯកជន។ វាគោរពគោលបំណងខ្ពស់ជាង គេនោះ គឺផលប្រយោជន៍ទូទៅ។ ផលប្រយោជន៍ទូទៅ មិនមែនជាការបូកធម្មតានៃផលប្រយោជន៍បុគ្គលទេ វាខ្ពស់ជាងផលប្រយោជន៍បុគ្គល និងដាក់បង្ខំឱ្យបុគ្គលគោរពតាម។

[៤] J. Ziller, Administrations comparées. Les systèmes politico-administratifs de l’Europe des Douze, 1993, Montchrestien.

រដ្ឋបាល អាចធ្វើសកម្មភាពក្នុងផលប្រយោជន៍ទូទៅ ពីព្រោះរដ្ឋបាល កើតឡើងដោយស្របច្បាប់ ស្ថិតនៅក្នុងអំណាចនីតិប្រតិបត្តិ។ អំណាចនីតិប្រត្តិបត្តិ ស្ថិតក្នុងដៃរដ្ឋាភិបាល។ រដ្ឋាភិបាលនេះ ទទួលខុសត្រូវ ចំពោះមុខសភា (ក្នុងរបបសភានិយម)។ សភា ជាប់ឆ្នោតកើតចេញពីការបោះឆ្នោត ជាសកល។ ឧត្តមភាពនៃផលប្រយោជន៍ទូទៅនេះ ពន្យល់ពីអំណាចបន្ថែមនៃរដ្ឋបាល ឧទាហរណ៍ អំណាចដែលរដ្ឋបាល មានខាងកិច្ចសន្យារដ្ឋបាល អាចកែសម្រួល ឬបដិសេធចោលកិច្ចសន្យា ជាឯកត្តោភាគី។

ត្រូវផ្សះផ្សាគ្នាឱ្យបាន ផលប្រយោជន៍ទូទៅ ជាមួយនឹងផលប្រយោជន៍ឯកជន។ ជាលក្ខណៈ ខាងក្នុង នីតិរដ្ឋបាល ជានីតិកើតចេញពីការស្រុះស្រួលគ្នា។ គំនិតគឺថា ត្រូវធ្វើយ៉ាងណាឱ្យ សម្រេចផលប្រយោជន៍ទូទៅ ដោយមិនប៉ះពាល់ផលប្រយោជន៍បុគ្គល។ ជាការពិត នីតិឯកជន ក៏ជានីតិនៃការផ្សះផ្សាគ្នា និងការស្រុះស្រួលគ្នាផងដែរ វាជាការងាយណាស់ ដែលក្នុងការសម្រេច ទៅដល់ការព្រមព្រៀងគ្នានេះ ពីព្រោះបុគ្គលឯកជន ជាបុគ្គលដែលមានសមភាពរវាងគ្នាតាមផ្លូវ ច្បាប់។ សមាមាត្រនៃនីតិរដ្ឋបាល មានលក្ខណៈស្មុគស្មាញជាង ប៉ិនប្រសប់ជាង។ ត្រូវធានាឱ្យ បាននូវការផ្សះផ្សាគ្នា រវាងបុគ្គលវិសមភាពខាងរចនាសម្ព័ន្ធ។ នីតិរដ្ឋបាលស្វែងរកនូវលំនឹងអចិន្ត្រៃយ៍ មួយ ។ លំនឹងនេះ បង្ហាញនូវលក្ខណៈពិសេស មួយៈ

វាមានលក្ខណៈប៉ិនប្រសប់ ផ្តល់អំណាចច្រើនទៅឱ្យរដ្ឋបាល អាចមានអានុភាពបំផ្លាញសេរីភាព។ ប៉ុន្តែ ប្រសិនបើគេផ្តល់អាទិភាពទៅឱ្យផលប្រយោជន៍ឯកជនខ្លាំងហួស មានហានិភ័យមួយ នៃភាព គ្មានប្រសិទ្ធិភាពនៃសកម្មភាពសាធារណៈ។

វាមានលក្ខណៈវិវត្តការផ្សះផ្សា រវាងផលប្រយោជន៍ទូទៅ និងផលប្រយោជន៍ឯកជន ត្រូវធ្វើ ឡើងទៅតាមសម័យកាល។ លំនឹង អាស្រ័យលើការវិវត្តនៃសង្គម នយោបាយ។ ជាមូលដ្ឋានការវិវត្ត ជាប្រវត្តិសាស្ត្រ បានផ្តល់សិទ្ធិកាន់តែច្រើនឡើងៗទៅឱ្យឯកជន។ នេះជាការវិវត្តទូទៅម្តងម្កាល ប្រការនេះ រារាំងដល់ការវិវត្ត ដែលអាចដើរថយដោយផ្តល់បុព្វសិទ្ធិច្រើនទៅឱ្យរដ្ឋបាល។ ឧទាហរណ៍ ការទទួលខុសត្រូវរបស់ពេទ្យក្នុងឆ្នាំ ១៩៥៩ កុងសីដេតា ចាត់ទុកថា ដើម្បីឱ្យមានការទទួលខុសត្រូវ របស់រដ្ឋ ក្នុងករណីមានកំហុសពេទ្យកើតឡើង កំហុសត្រូវមានលក្ខណៈធ្ងន់ធ្ងរ ប្រព្រឹត្តឡើងដោយ គ្រូពេទ្យ គឺសាលដីកា Rouzet។ គេផ្តល់អាទិភាពដល់សេវាសាធារណៈពេទ្យ ជាងអ្នកជំងឺ។ សព្វថ្ងៃ អ្នកជំងឺចាត់ទុកថា វេជ្ជសាស្ត្រត្រូវតែជាវិទ្យាសាស្ត្រពិត។ សាលដីការបស់កុងសីដេតា ឆ្នាំ១៩៩២ កំហុសធម្មតា មិនធ្ងន់ធ្ងរ ក៏អាចគ្រប់គ្រាន់ ដើម្បីឱ្យមានការទទួលខុសត្រូវរបស់ពេទ្យ។ ដូច្នេះ

មានការព្រមព្រៀងថ្មីមួយ រវាងផលប្រយោជន៍អ្នកជំងឺ និងផលប្រយោជន៍មន្ទីរពេទ្យ។ ដូចគ្រប់ការព្រមព្រៀងគ្នាដែរ ភាគីមិនដែលពេញចិត្តទាំងអស់ទេ។

### កថាខណ្ឌ ១ នីតិរដ្ឋបាលប្រៀបធៀប[៥]

ដូចគ្នានឹងការប្រមូលផ្តុំនៃនីតិសាធារណៈ ក្រោមគំរូទ្រឹស្តីផ្អែកលើបទពិសោធន៍របស់មនុស្ស និងច្បាប់ធម្មជាតិរបស់វា ហើយគ្មានអាជ្ញាយុកាល បានផ្លាស់ប្តូរយ៉ាងស៊ីជម្រៅ ទិដ្ឋភាពនៃនីតិរដ្ឋធម្មនុញ្ញ វាបានផ្លាស់នីតិរដ្ឋបាលយ៉ាងស៊ីជម្រៅ។ ពីទស្សនៈនៃអំណាច "សាធារណៈ" ដែលរៀបចំជារចនាសម្ព័ន្ធឡើងនូវមុខវិជ្ជានេះ នៅសតវត្សទី ២០ បានកំណត់ស្មារតីនៃមុខវិជ្ជានេះផងដែរ នោះគឺលក្ខណៈវិនិច្ឆ័យនៃសមត្ថកិច្ចរបស់នីតិរដ្ឋបាល។ នៅទីនេះ មិនមែនជាការសួរលើបញ្ហាដែលត្រូវដឹងថា តើត្រូវមានសមាមាត្ររវាងនិយមន័យនៃមុខវិជ្ជាមួយ និងលក្ខណៈវិនិច្ឆ័យ ដែលប្រគល់តួនាទីទៅឱ្យតុលាការមួយចំនួន ក្នុងការដោះស្រាយវិវាទ ហើយមិនមែនប្រគល់តួនាទីនេះ ទៅឱ្យតុលាការផ្សេងនោះទេ ប៉ុន្តែតុលាការមួយ មិនចំឡែកទាំងស្រុងពីតុលាការឯទៀតនោះទេ។

នៅបរទេស នីតិរដ្ឋបាល រៀបចំឡើងនៅជុំវិញតម្លៃផ្សេង ក្រៅពីអំណាចសាធារណៈ។ តម្លៃទាំងនេះ ចារឹកនៅជុំវិញមិនមែនអំណាចរបស់រដ្ឋទេ ប៉ុន្តែនៅជុំវិញមនុស្ស និងសិទ្ធិសេរីភាពរបស់មនុស្ស។ ជាការពិត នៅប្រទេសអង់គ្លេស ដែលចៅក្រមអង់គ្លេសបានកសាងនីតិរដ្ឋបាលអង់គ្លេស នៅជុំវិញគំនិតយុត្តិធម៌ធម្មជាតិ (Natural Justice) ជាសញ្ញាណ Common Law ដែលបានធ្វើឱ្យតម្លៃនៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប កាន់តែមានតម្លៃខ្ពស់[៦]។ ជាការពិត នៅសហរដ្ឋអាមេរិក ដែលចៅក្រមអាមេរិក បានរុញច្រានដោយលទ្ធិ ដែលលែងពេញចិត្តនឹងនីតិវិធីស្របច្បាប់នៃច្បាប់ (Procedural due process of law) តាមទស្សនៈទម្រង់ ត្រូវបានអញ្ជើញ ឱ្យពង្រីកនីតិរដ្ឋបាល ដោយផ្តើមចេញពីតម្លៃនៃនីតិសាធារណៈ (Public law values) ដូច្នេះ ត្រូវបានអញ្ជើញឱ្យងាកមកមើលរយៈកាលមួយ ដែលត្រូវស្តីបន្ទោសឱ្យខ្មាសគេ ដោយប្រវត្តិសាស្ត្រច្បាប់របស់សហរដ្ឋអាមេរិក នោះគឺ រដ្ឋាភិបាលរបស់ចៅក្រម[៧] កាលណាតុលាការកំពូល គ្រប់គ្រងប្រទេសដោយប្រើមធ្យោបាយនៃនីតិវិធីត្រឹមត្រូវនៃច្បាប់ តាមទស្សនៈសម្ភារៈ (Substantive due process)។ ជាការពិត នៅទីបញ្ចប់ នៅប្រទេសអាល្លឺម៉ង់ ដែលអាទិភាពនៃចៅក្រមរដ្ឋបាល លែងជាអាទិភាពនៃអំណាចសាធារណៈទៀតហើយ

---

[៥] Droit Admistratif comparé (Responsible : Gilles J. Guglielmi)។

[៦] អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ៤ វិច្ឆិកា ១៩៥០។

[៧] (judicial activism) គឺបកស្រាយទៅលើសេចក្តីសម្រេចតុលាការជាឯកច្ឆ័ន្ទ ឬ សេចក្តីសម្រេចនយោបាយ ជាជាងការពឹងផ្អែកទៅលើច្បាប់ដែលមានស្រាប់។

(Staat Sgewalt) ប៉ុន្តែជាអាទិភាពនៃសិទ្ធិជាមូលដ្ឋាន ដែលមានចែងនៅក្នុងច្បាប់ជាមូលដ្ឋាន និយាយម្យ៉ាងទៀត សិទ្ធិអត្តវិស័យរបស់រាស្ត្រប្រជា។ នៅទីបញ្ចប់ នៅអាមេរិកឡាទីន ដែលបំណងប្រាថ្នារបស់ប្រជាជន ត្រូវបានឱភាសកម្ម នៅក្នុងទសវត្សរ៍ទី ២០ នៃបណ្តាលឆ្នាំចុងក្រោយ ការប្រើប្រាស់ពិតប្រាកដនៃសកម្មភាពសាធារណៈ ដោយរំលោភសិទ្ធិបុគ្គល ដែលតុលាការអន្តរអាមេរិកាំងនៃសិទ្ធិមនុស្សបានចោទឡើងនូវបណ្តុំគោលការណ៍រួម ដែលទទួលបាននូវការបន្ទន់មួយចំនួន រហូតដល់ក្នុងវិវាទរដ្ឋបាលរបស់រដ្ឋផ្សេងៗ ដែលក្នុងនោះ តុលាការធម្មនុញ្ញមួយចំនួន ធ្វើជាភស្តុតាង នៃសកម្មភាពនិយមមួយ ដែលរុញច្រានរដ្ឋាភិបាល ឱ្យផ្តល់នូវខ្លឹមសារចម្បងមួយ ទៅឱ្យសិទ្ធិមួយចំនួនទាំងនេះ ដូចជានៅក្នុងប្រទេសកូឡុំប៊ីជាដើម។

ការផ្លាស់ប្តូរចម្បងៗទាំងនេះ ត្រូវបានបញ្ចូលទៅក្នុងច្បាប់បារាំង ជាពិសេសតាមរយៈច្បាប់អ៊ឺរ៉ុប ដែលបានទទួលយកវាឡើងវិញប្រដូច និងនាំចេញវិញ ប៉ុន្តែប្រហែលជាមិនបានរៀបចំជាគំនិតឱ្យបានគ្រប់គ្រាន់នៅឡើយ។

### ១. នីតិវិធីរដ្ឋបាល

តាំងពីយូមកហើយ នីតិវិធីរដ្ឋបាល ស្ថិតនៅក្រោមគំរូនៃបទពិសោធន៍នៃអំណាចរបស់រដ្ឋ (ឯកសិទ្ធិនៃសេចក្តីសម្រេចដែលត្រូវប្រតិបត្តិ បុព្វសិទ្ធិនៃអំណាចសាធារណៈ រាជស័ក្តិ)។ ចៅក្រមរដ្ឋបាលបារាំង បានតស៊ូដោយឥតទម្លាក់ដៃ ដើម្បីកំណត់អានុភាពនៃអំណាចនេះលើបុគ្គល។ ស្ថិតក្នុងកង្វល់នេះ ចៅក្រម បានចេញសាលដីកាពីមួយទៅមួយ ដែលបង្កើតបាននូវមូលដ្ឋានដ៏រឹងមាំនៃនីតិរដ្ឋបាល។ ប៉ុន្តែ គឺបន្ទាប់ពីឆ្នាំ ១៩៤៥ មក ទំព័រសំខាន់ៗនៃសាលដីកាទាំងនេះ ត្រូវបានសរសេរឡើង ចៅក្រម បានធ្វើការវិភាគប្រៀបធៀបលក្ខណៈស៊ីជម្រៅ ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងបច្ចេកទេសនៃការត្រួតពិនិត្យរបស់ខ្លួន (ការត្រួតពិនិត្យសមាមាត្រ) និងពង្រឹងអំណាចសម្រេចរបស់ខ្លួន រហូតធ្វើឱ្យមានការបញ្ចូលក្រោមទម្រង់ដីកាប្រញាប់-សេរីភាព នូវអំណាចបង្ខំ អំណាចនេះបង្គាប់ឱ្យភ្នាក់ងារនៃអង្គការនីតិប្រតិបត្តិឱ្យធ្វើអ្វីមួយ ហើយដែលប្រាប់ឱ្យដឹងជាសញ្ញា ពីអំណាចពិសេសនៃចៅក្រមCommon Law។

ការសិក្សានៃដំណោះស្រាយវិវាទ ដែលទទួលបាននៅបរទេស បើកផ្លូវផ្សេងទៀត ដោយបង្ហាញឱ្យឃើញថា នីតិរដ្ឋបាលបារាំង មានលក្ខណៈយ៉ាងម៉េច ហើយបើប្រៀបធៀបទៅនឹងច្បាប់បរទេស វាមានភាពសម្បូណ៌បែបយ៉ាងម៉េច។ នេះជាមូលហេតុនៃការសិក្សាប្រៀបធៀប ហើយយើងអាចដឹងបានពីខ្លួនយើងច្បាស់ តាមការស្វែងយល់រឿងទាំងអស់នេះ នៅក្នុងវប្បធម៌

ប្រៀបធៀបនេះឯង។ ជ្រុងទស្សនៈថ្មីនេះ ចាំបាច់ណាស់ ដើម្បីឱ្យនីតិរដ្ឋបាលចោទឡើងនៅគ្រប់ទីកន្លែងទាំងអស់ ស្រដៀងគ្នានៃការត្រួតពិនិត្យលើអង្គហេតុ ការត្រួតពិនិត្យនីត្យានុកូលភាព ជាមួយនឹងការប្រើអំណាចឆន្ទានុសិទ្ធិរបស់អាជ្ញាធររដ្ឋបាល។ ភាពជឿនលឿនថ្មីៗទាំងនេះ កើតឡើងដោយសារការបើកទស្សនៈនៅបរទេស។

ក្រៅពីនីតិវិធីជាវិវាទ គឺនីតិវិធីមិនមែនវិវាទ ត្រូវបានធ្វើបដិវត្តន៍ដោយប្រៀបធៀបទៅនឹងច្បាប់បរទេស។ ក្រោមឥទ្ធិពលនៃគំនិត ចេញមកពីសហរដ្ឋអាមេរិក នីតិវិធីទាំងនេះ អាចទទួលយកបាន តាមភាពចាំបាច់ នៃនីតិរដ្ឋធម្មនុញ្ញ គំនិត តួយ៉ាងគំនិតនៃការចូលរួម និងការសម្រេច ដែលមានប្រភពដើមចេញមកពីរដ្ឋធម្មនុញ្ញ ត្រូវបាននាំចូលខាងនីតិរដ្ឋបាល និងត្រូវបានចាត់ទុកថាជាភាពចាំបាច់ថ្មីៗ។

រវាងមុខវិជ្ជាទាំងពីរ នីតិរដ្ឋធម្មនុញ្ញ និងនីតិរដ្ឋបាល មានការសិក្សាតិចតួចនៅឡើយ។ នៅព្រះរាជាណាចក្រកម្ពុជាយើង គ្មានមជ្ឈមណ្ឌលស្រាវជ្រាវ ក៏ដូចជាគ្មានការងារស្រាវជ្រាវថ្នាក់សាកលវិទ្យាល័យ ជារបៀបស៊ីជម្រៅនៅឡើយ។

### ២. វង្វង់សកម្មភាពរដ្ឋបាល

ធ្វើឡើងស្របគ្នាជាមួយនឹងភាពក្រឡាប់ចក្រនៃនីតិវិធី ការរីកសាយនៃវង្វង់សកម្មភាពរដ្ឋបាល បើកផ្លូវស្រាវជ្រាវកាន់តែធំ ទៅរកការវិភាគប្រៀបធៀប។ ស្ថិតនៅចន្លោះរដ្ឋាភិបាល និងសង្គម។ អាជ្ញាធររដ្ឋបាលរាល់ថ្ងៃ ពង្រឹងអភិបាលកិច្ចរបស់ខ្លួន ធ្វើសកម្មភាពរបស់ខ្លួនជាថ្មីឡើងវិញ និងប្រើវិធីសាស្ត្រខុសៗគ្នា ទៅតាមប្រទេស ជាពិសេសជម្រុញដោយទ្រឹស្តីសេដ្ឋកិច្ចសេរីថ្មីលេចធ្លោ និងការអនុវត្តរបស់វា ខាងនីតិសាធារណៈ ជាពិសេស ការវិភាគផ្នែកសេដ្ឋកិច្ចនៃច្បាប់ និងទ្រឹស្តីនៃជម្រើសសាធារណៈ។ វិធីសាស្ត្ររដ្ឋបាល ត្រូវបានកែសម្រួលយ៉ាងស៊ីជម្រៅក្នុងទ្រឹស្តីនេះ។ ជាដំបូង នៅក្នុងប្រទេស Common Law បន្ទាប់មកទៀត នៅអឺរ៉ុបទ្វីប និងទីបញ្ចប់ នៅក្នុងប្រទេសដែលទើបនឹងដើបចេញពីភាពក្រីក្រ ជាការអនុគ្រោះ ដល់អនុសាសន៍នៃមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក។

គ្រប់ប្រទេសទាំងអស់ ប្រឈមទៅនឹងភាពចាំបាច់នៃនិយ័តកម្ម។ ជាដំបូង ភាពចាំបាច់នេះ វិវត្តន៍ជាមួយនឹងបច្ចេកទេស។ នៅក្នុងទស្សនៈវិស័យនេះ ជាការចាំបាច់ណាស់ ក្នុងការធ្វើការវិភាគប្រៀបធៀប លើយន្តការនៃការកែតម្រូវខាងច្បាប់និយ័តកម្ម ទៅនឹងការវិវត្តនៃបច្ចេកវិទ្យាថ្មីៗ។ នេះជារបៀបមួយ នៃការបញ្ជាក់ពីបញ្ហានៃទំនាក់ទំនងថ្មីៗ រវាងច្បាប់ វិទ្យាសាស្ត្រ និងបច្ចេកទេស។ បន្ទាប់មកទៀត និយ័តកម្មដាក់បង្ខំចំពោះកម្រិតភូមិសាស្ត្រផ្សេងៗ មូលដ្ឋាន តំបន់ ជាតិ

ហើយបច្ចុប្បន្ន ពិភពលោក។ និយ័តកម្មពហុកម្រិត ចោទឡើងនូវបញ្ហានៃរដ្ឋបាលដែនដី និងសមត្ថកិច្ចរវាងសហាគមន៍ជាតិ និងសមូហភាពមូលដ្ឋាន។

បញ្ហាមួយផ្សេងទៀត ដែលមានសារៈសំខាន់ខ្លាំងខាងនីតិសាធារណៈ គឺការបែងចែកនីតិសាធារណៈ និងនីតិឯកជន។ ឯកជនភាវូបនីយកម្ម ធ្វើឡើងនៅក្នុងប្រទេស Common Law បន្ទាប់មកទៀត បានលាតសន្ធឹងដល់ប្រទេសអឺរ៉ុបទ្វីប និងដាក់បង្ខំឱ្យប្រទេសដែលទើបនឹងងើបចេញផុតពីភាពក្រីក្រ បានផ្តល់ឡើងវិញនូវរឿងថ្មីមួយ ចំពោះបញ្ហានេះ។ នៅសហរដ្ឋអាមេរិក ក៏ដូចជានៅប្រទេសអង់គ្លេសដែរ ឯកជនភាវូបនីយកម្ម បានដាស់ក្នុងចំណោមអ្នកច្បាប់ ផលប្រយោជន៍សម្រាប់នីតិសាធារណៈ និងតម្លៃរបស់វា។ ចម្លងការនៃសកម្មភាពរបស់រដ្ឋជាច្រើនទៅទីផ្សារ បានធ្វើឱ្យប្រទេសទាំងនោះ មានមនៈសិការច្រើនជាងមុនលើនីតិសាធារណៈ។ តើរហូតដល់ណា រដ្ឋអាចដកខ្លួនចេញបាន? តើត្រូវបង្កើតនូវកម្រិតទៅតាមវិស័យដែលបានធ្វើឯកជនភាវូបនីយកម្ម កម្រិតដែលរដ្ឋអាចចេញទាំងស្រុង កម្រិតដែលក្នុងនោះ រដ្ឋត្រូវមានវត្តមាន ដោយទុកក្នុងករណីខ្លះការត្រួតពិនិត្យលើសកម្មភាពដែលត្រូវបានធ្វើឯកជនភាវូបនីយកម្ម (តាមរយៈ Golden Share) និងកម្រិតដែលក្នុងនោះ រដ្ឋត្រូវបដិសេធចំពោះសហគ្រាសឯកជន នូវលទ្ធភាពក្នុងការធ្វើប្រតិបត្តិការរបស់ខ្លួន ក្រៅការបង្ខិតបង្ខំនៃនីតិសាធារណៈ? នៅត្រង់នេះហើយ ដែលអ្នករដ្ឋបាលត្រូវទទួលបន្ទុកធ្វើការវិភាគ។

ថ្មីៗនេះ គំនិតផ្តួចផ្តើមដែលបង្ហាញឱ្យឃើញពីការងាករបស់ពិភព Common Law ចំពោះតម្លៃនៃនីតិសាធារណៈ ដែលត្រូវបានធ្វើឡើងជាមួយនឹងការធ្វើនីតិសម្បទា នៃគំនិតនីតិភាពជាពលរដ្ឋដែលដាក់បង្ខំឱ្យទទួលយកកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ (កាតព្វកិច្ចទទួលបន្ទុកហិរញ្ញវត្ថុ អាករ) និងការទទួលខុសត្រូវមួយចំនួនចំពោះរដ្ឋ។ តើភាពជាប្រជាពលរដ្ឋ គឺព្រំដែនចំពោះការបោះបង់ចោល ក្នុងវិស័យឯកជននៃសេវាកម្ម ដែលកាលពីដើម ត្រូវផ្តល់ឡើងដោយរដ្ឋដូចជា ការអប់រំ ឬ ការធានារ៉ាប់រងចាស់ជរា? តើនេះជាមូលហេតុ ដើម្បីធ្វើឱ្យបុគ្គលទទួលខុសត្រូវ នៅចំពោះមុខបន្ទុករួមឬ? សំណួរនេះ ត្រូវបានចោទជាស្រេចនៅបរទេសជាអាទិ៍ នៅសហរដ្ឋអាមេរិក ហើយវាមិនមែនជារឿងទាត់ចោលទេ ដែលថាវាត្រូវលើកឡើងនៅប្រទេសកម្ពុជានោះ ក្នុងវិស័យមួយចំនួនដូចជា ឧត្តមសិក្សា និងវិស័យសុខាភិបាល។

នៅទីបញ្ចប់ សព្វថ្ងៃ សកម្មភាពរដ្ឋបាល លាតសន្ធឹងតាមវិធីមួយចំនួនដែលខ្ចីពីព័ត៌មាននៃការវិភាគផ្នែកសេដ្ឋកិច្ច។ អាជ្ញាធរសាធារណៈ បន្តិចម្តងៗ លើកលែងតែក្នុងវិស័យកំណត់ជាក់លាក់ រមែងបង្ខំជាប់ចំណងដោយសិទ្ធិកម្មសិទ្ធិ(ពន្ធ និងអស្សាមិករណ៍) ហើយសកម្មភាពនេះ ញ៉ាំងកាន់

តែខ្លាំងឡើងៗ។ តើចាប់ពីពេលណាមក ការជម្រុញខាងផ្នែកហិរញ្ញវត្ថុ ក្លាយជាការបង្ខិតបង្ខំ? ព្រំដែនដែលវាបង្ខិតបង្ខំ ចំពោះសេរីភាពនៃការជ្រើសរើសជាប្រធានបទ នៃការពិចារណា ដែលគួសិក្សាឱ្យបានច្រើនតាមការប្រៀបធៀបពីប្រទេសទៅប្រទេស។

### ៣. តើរដ្ឋបាលនៅកម្ពុជាស្ថិតនៅក្រោមនីតិរដ្ឋបាលដែរឬទេ?

គោលការណ៍នៃការបែងចែកមុខងាររដ្ឋបាល និងតុលាការនៅព្រះរាជាណាចក្រកម្ពុជា ត្រូវនាំមកដោយអាណានិគមបារាំង បានន័យថា មុនការមកដល់នៃអាណានិគមបារាំង មុខងារទាំងពីរនេះ មិននៅដាច់ពីគ្នាទេ ព្រោះអំណាច ត្រូវប្រមូលផ្តុំនៅក្នុងព្រះហស្តព្រះមហាក្សត្រតែអង្គឯង។ ទាញចេញពីគោលការណ៍នៃការចែកដាច់គ្នានៃមុខងារទាំងពីរនេះ រដ្ឋបាលត្រូវដោះស្រាយជម្លោះ(វិវាទរដ្ឋបាល)[៨] របស់ខ្លួនដោយខ្លួនឯង។ គោលការណ៍នេះ ហាមថៅក្រមនៃតុលាការធម្មតា ជ្រៀតជ្រែកក្នុងសកម្មភាពរដ្ឋបាល ជាប្រការដែលនាំឱ្យលេចចេញនៃនីតិរដ្ឋបាល និងថៅក្រមពិសេស នោះគឺថៅក្រមរដ្ឋបាល។ ថៅក្រមនេះ ឯករាជ្យពីអង្គការនីតិប្រត្តិបត្តិ នីតិរដ្ឋបាលដែលជានីតិពិសេស ត្រូវបានតាក់តែងឡើង និងឯករាជ្យពីនីតិរដ្ឋប្បវេណី ដែលទទួលយកដោយរដ្ឋបាល។

តុលាការរដ្ឋបាលនៅកម្ពុជា ក៏ត្រូវបានលេចពន្លកចេញនៅបណ្តាលឆ្នាំ ១៩២២-១៩២៣[៩]។ ប៉ុន្តែគំនិតត្រូវបានបរាជ័យ ដោយសារមូលហេតុពីរ៖ មូលហេតុនយោបាយ និងហិរញ្ញវត្ថុ។ គំនិតនេះត្រូវបានលេចចេញសារជាថ្មី ក្នុងឆ្នាំ១៩៩៤ ដែលតាមនេះ សភារដ្ឋបាលមួយនឹងត្រូវបង្កើតឡើង នៅសាលាឧទ្ធរណ៍ ដែលនឹងមានសមត្ថកិច្ចជាន់ទីមួយ ប៉ុន្តែត្រូវបរាជ័យទៀត ដោយសារមរណភាពនៃឯកឧត្តមចែមស្នួនកាលនោះជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ទោះជាមានឧបសគ្គយ៉ាងដូចនោះក៏ដោយ ក៏គំនិតនៃការបង្កើតតុលាការរដ្ឋបាលមួយ ឬតុលាការឯកទេសសម្រាប់ដោះស្រាយវិវាទរដ្ឋបាល នៅតែមិនត្រូវបានបោះបង់ចោល ហើយត្រូវបានលើកយកមកនិយាយ នៅក្នុងគោលនយោបាយរបស់រាជរដ្ឋាបាលកម្ពុជាបច្ចុប្បន្ន ទាក់ទងទៅនឹងកំណែទម្រង់នៃប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលជាកំណែទម្រង់មួយផ្អែកលើមាត្រា ១២៨ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។

នីតិរដ្ឋបាល ជានីតិផ្អែកលើការអនុវត្តជាក់ស្តែង ឬបទពិសោធន៍ដែលមានចែងពីវិធានពិសេសក្នុងគោលបំណងផ្សះផ្សាតម្រូវការនៃសេវាសាធារណៈ (ផលប្រយោជន៍ទូទៅ និងផលប្រយោជន៍បុគ្គល)។

---

[៨] ឌៀក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ (ភ្នំពេញ៖ ឈីវទីមិច គ្រុប, ២០១១) ២៣១។

[៩] Jean ImBert, Histoire des institutions Khmers (Phnom Penh៖ Enterprise Khmer de Librairie, 1961)។

ជានីតិស្វយ័ត បើប្រៀបធៀបទៅនឹងនីតិរដ្ឋប្បវេណី គឺជានីតិវិសមភាព កើតចេញពីបុព្វសិទ្ធិនៃអំណាចសាធារណៈ ហើយដាក់ការបង្ខិតបង្ខំដល់រាស្ត្រប្រជា។

### កថាខណ្ឌ ២ លក្ខណៈនៃនីតិរដ្ឋបាល

#### ១. លក្ខណៈសំខាន់ៗ

នីតិរដ្ឋបាល ជានីតិពិសេសព្រោះវាចែងពីវិធានដែលមានលក្ខណៈវិសមភាព រវាងរាជការ និងរាស្ត្រប្រជា។ ជានីតិបាត់លំនឹង ជាប្រយោជន៍ដល់រដ្ឋបាល ប៉ុន្តែនីតិនេះការពារសកម្មភាពរបស់រដ្ឋ កំណត់អំណាចរបស់អាជ្ញាធររដ្ឋបាល ដោយការពាររាស្ត្រប្រជា។ អាទិភាពនៃនីតិរដ្ឋបាលបញ្ជាក់ពីទំនាស់ផលប្រយោជន៍ពីរៈ កំណត់ដែនសកម្មភាពរបស់រដ្ឋបាល និងការពាររាស្ត្រប្រជា។ នីតិរដ្ឋបាលជានីតិដែលកើតឡើងដោយផ្អែកលើយុត្តិសាស្ត្រ។ យុត្តិសាស្ត្រគឺបណ្ដាសេចក្ដីសម្រេចរបស់តុលាការដែលដោះស្រាយវិវាទ ដែលមានប្រភេទដូចគ្នា នៅក្នុងមែកធាងផ្សេងទៀតនៃច្បាប់ ច្បាប់គឺជាប្រភពនៃនីតិនៅទីនេះ គឺយុត្តិសាស្ត្រ។ ការដោះស្រាយវិវាទដោយផ្អែកលើយុត្តិសាស្ត្រ ផ្ដល់នូវផលល្អ និងផលអាក្រក់មួយចំនួន។ ផលល្អ គឺថា យុត្តិសាស្ត្រ ទន់ភ្លន់ជាងប្រភពផ្សេងទៀតនៃច្បាប់។ វាអាចសម្របដោយស្ទៀមស្ទាត់ទៅនឹងតថភាពសង្គម ចៅក្រមអាចដោះស្រាយវិវាទដោយផ្អែកទៅលើបរិបទសង្គម។ បើប្រៀបធៀបទៅនឹងច្បាប់ យុត្តិសាស្ត្រមានឧត្តមភាព មាននិរន្តរភាពៈ ចៅក្រមមិនមែនជាអ្នកទោស នៃសេចក្ដីសម្រេចមុនៗនោះទេ។

ប៉ុន្តែពេលខ្លះ យុត្តិសាស្ត្រក៏បង្ហាញពីផលអាក្រក់មួយចំនួនដែរ។ រាស្ត្រប្រជា និងរដ្ឋបាលអាចទទួលរងនូវការផ្លាស់ប្ដូររបស់តុលាការដែរ ព្រោះពេលខ្លះ ចៅក្រមសម្រេចផ្សេង មិនដូចពីការសម្រេចរបស់ចៅក្រមមុនៗ។ យុត្តិសាស្ត្រ មិនមែនជាវិធានសរសេរទុកដូចវិធានច្បាប់នោះទេ។ ដូច្នេះ គ្មានសន្តិសុខនៃវិធានសរសេរនោះទេ។ ចំណែកឯជ្រុងទស្សនៈខាងវិវាទវិញ គ្មានទស្សនៈរួមចំពោះដំណោះស្រាយនៃរាល់វិវាទដែលបានកើតឡើង។

ជាយូរលង់ណាស់មកហើយ យុត្តិសាស្ត្រ បានដើរតួនាទីសំខាន់ ក្នុងការកំណត់វិធាននៃនីតិរដ្ឋបាលបារាំង។ ត្រូវងាកទៅមើលសាលដីកា Blanco តុលាការវិវាទសមត្ថកិច្ច បានបង្កើតនូវភាពខ្វះទទេមួយ ពីព្រោះនីតិឯកជន មិនអាចអនុវត្តបាន តុលាការ បានបង្កើតរបបរដ្ឋបាលនៃការទទួលខុសត្រូវ។ នៅក្នុងសាលដីកា Blanco តុលាការវិវាទសមត្ថកិច្ច បានបង្កើតរបបនៃការទទួលខុសត្រូវនេះ ដោយផ្អែកប៉ុណ្ណោះ។ ពីព្រោះតុលាការ និយាយពីខ្សែបន្ទាត់ធំៗនៃការទទួលខុសត្រូវរដ្ឋបាល។ តុលាការនិយាយថា ការទទួលខុសត្រូវរបស់រដ្ឋ មិនត្រូវមានលក្ខណៈទូទៅ និងដាច់ខាតទេ វិធាន

ដែលទាក់ទងទៅនឹងការទទួលខុសត្រូវរបស់រដ្ឋ ត្រូវប្រែប្រួលទៅតាមតម្រូវការនៃសេវាសាធារណៈ។ តុលាការវិវាទសមត្ថកិច្ច កំណត់ក្របខណ្ឌគតិយុត្តដ៏ទូលាយនៃការទទួលខុសត្រូវរដ្ឋបាល ជាក្របខណ្ឌគតិយុត្តដែលបន្ទាន់ ត្រូវបំពេញដោយចៅក្រមរដ្ឋបាល ដោយសារយុត្តិសាស្ត្ររបស់ខ្លួន សារៈសំខាន់នៃសំណេរជាប្រវត្តិសាស្ត្រខ្លាំងជាងខាងនីតិរដ្ឋបាល។ យុត្តិសាស្ត្ររដ្ឋបាល ចម្លងគំរូតាមអត្ថបទច្បាប់ យុត្តិសាស្ត្រនឹងបំពេញច្បាប់សរសេរ ប៉ុន្តែ ជួនកាលចៅក្រមរដ្ឋបាល បង្កើតវិធានផ្តើមចេញពីគ្មានអ្វីសោះ។ ចៅក្រមជាអ្នកបង្កើតច្បាប់។ ឧទាហរណ៍ ខាងនគរបាលរដ្ឋបាល ឬការទទួលខុសត្រូវ ។ ចៅក្រមបានទាញចេញនូវគោលការណ៍ទូទៅមួយចំនួន។

សព្វថ្ងៃ គេត្រូវធ្វើឱ្យខុសគ្នាបន្តិច លក្ខណៈយុត្តិសាស្ត្រនៃនីតិរដ្ឋបាល គេឃើញមានការបង្កើតនីតិរដ្ឋបាល ពោលគឺថា វិធានត្រូវលើកយកមកនិយាយឡើងវិញ ដោយអត្ថបទសរសេរ គឺច្បាប់ ឬ បទបញ្ជា។ នីតិរដ្ឋបាល ក្លាយជានីតិមួយកាន់តែត្រូវបានសរសេរច្រើនឡើង គេឃើញមានចលនានៃការចងក្រងជាច្បាប់ខាងនីតិរដ្ឋបាល ឧទាហរណ៍ ច្បាប់ភូមិបាល ចែងពីវិធាននៃនីតិរដ្ឋបាលនៃទ្រព្យសម្បត្តិសាធារណៈ។

នីតិរដ្ឋបាលគឺជានីតិស្វយ័ត ដូច្នេះវិធាននៃនីតិឯកជន ខុសពីវិធាននៃនីតិរដ្ឋបាលគេអាចនិយាយថាវាស្វយ័ត ព្រោះវាត្រូវបានអនុវត្តដោយចៅក្រមផ្ទាល់របស់វា(ចៅក្រមរដ្ឋបាល)។

## កថាខណ្ឌ ៣ ការវិវត្តថ្មីៗនៃនីតិរដ្ឋបាល

### ក. ការប្រជុំនៃប្រភពផ្សេងៗទៀតនៃច្បាប់

ច្បាប់សរសេរ (ច្បាប់ និង បទបញ្ជា កាន់តែសំខាន់ឡើងៗ ក្រោមឥទ្ធិពលនៃនីតិអន្តរជាតិ ដែលក្នុងនោះ នីតិសហគមអឺរ៉ុប)[១០]។ យុត្តិសាស្ត្រនៃក្រុមប្រឹក្សាធម្មនុញ្ញ នៅក្នុងនោះ សាលដីកាមានសារៈសំខាន់លំដាប់ទីមួយ ចៅក្រមនៃតុលាការធម្មតា ធ្វើអន្តរាគមន៍កាន់តែច្រើនឡើង ដើម្បីកាត់សេចក្តី និងវាយតម្លៃលើសកម្មភាពរបស់រដ្ឋបាលជាមួយនឹងលក្ខណៈវិនិច្ឆ័យផ្សេងទៀត (ការយោងទៅលើគ្រឹះស្ថានសាធារណៈ ដែលគ្រប់គ្រង ដោយសមាគមន៍ដែលប្រើនីតិឯកជន)។

[១០]នៅក្នុងក្របខណ្ឌនៃការអភិវឌ្ឍ ការកសាងសហគមន៍អឺរ៉ុប គេឃើញមានការបង្កើតសន្ធិសញ្ញាសំខាន់ៗ ដូចជាសន្ធិសញ្ញាទីក្រុងរ៉ូម (Traité de Rome) ចុះថ្ងៃទី ២៥ មិនា ឆ្នាំ១៩៥៧ បង្កើតសហគមន៍សេដ្ឋកិច្ចអឺរ៉ុប។ អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី ២ វិច្ឆិកា ឆ្នាំ១៩៥០។ សន្ធិសញ្ញា ម៉ាកអាស្ទ្រីត (Traité de Masstricht) ឆ្នាំ ១៩៩២ បង្កើតសហភាពអឺរ៉ុបជាជំនួសសហគមន៍អឺរ៉ុប និងសន្ធិសញ្ញា អាំស្ទែរដាំ (Traité d'Amsterdam) ឆ្នាំ ១៩៩៧ដែលរៀបចំពង្រឹងសហគមន៍អឺរ៉ុបជាដើម។

**ខ. លក្ខណៈវិសមភាពនៃនីតិរដ្ឋបាលកាន់តែត្រូវបានទទួលយកតិចទៅៗ**

រដ្ឋបាលត្រូវបានធ្វើទំនើបកម្ម។ រដ្ឋសេរីមិនធ្វើអន្តរាគមន៍នៅក្នុងសកម្មភាពសេដ្ឋកិច្ចដែលជារបស់បុគ្គលឯកជនទេ។ រដ្ឋបាលប្រើបច្ចេកទេសកិច្ចសន្យា។ រដ្ឋបាលចរចា(ជាមួយដៃគូសង្គម) ជាជាងចេញសេចក្តីសម្រេចជាឯកតោភាគី ដាក់បង្ខំឱ្យដៃគូរបស់ខ្លួនអនុវត្ត ប្រការនេះ ត្រូវបានអះអាងបញ្ជាក់ដោយយុត្តិសាស្ត្រអឺរ៉ុប តុលាការសិទ្ធិមនុស្សអឺរ៉ុប ថារឿងនេះ នឹងពង្រឹងបុគ្គល និងសិទ្ធិរបស់បុគ្គល ប្រឈមនឹងរដ្ឋបាល (វប្បធម៌អង់គ្លូសាកសង់) ប្រការនេះ នាំឱ្យមានលំនឹងឡើងវិញនៃនីតិរដ្ឋបាល។ ត្រូវកំណត់ព្រំដែនមួយចំនួនដើម្បីឱ្យសកម្មភាពរបស់រដ្ឋបាលមិនត្រូវរំខាន។ ជានិច្ចកាល ផលប្រយោជន៍ទូទៅ ត្រូវយកមកសំអាងធ្វើជាច្បាប់មុនគេបង្អស់។

## ផ្នែក ២

## រដ្ឋបាលត្រូវគោរពគោលការណ៍នីត្យានុកូលភាព ៖ ទិសដៅថ្មីនៃនីតិរដ្ឋបាល

រដ្ឋបាលជាឧបករណ៍ ឬជាយន្តការបច្ចេកទេសរបស់រដ្ឋក្នុងការអនុវត្តសកម្មភាពនៃការបម្រើផលប្រយោជន៍ទូទៅ[១១]។ រដ្ឋបាល ក៏ជាដៃជាជើងរបស់ស្ថាប័ននយោបាយផងដែរ។ ដូច្នេះ ស្ថាប័នទាំងពីរ ដែលជាស្ថាប័នសាធារណៈ ត្រូវរួមចំណែកក្នុងការដោះស្រាយ នូវរាល់បញ្ហាសាធារណៈ ដោយផ្អែកលើវិធាននីតិជាធរមាន។ កាលណារដ្ឋបាលគោរពវិធាននីតិជាធរមាន មុននឹងចេញសេចក្តីសម្រេចរបស់ខ្លួន គេថារដ្ឋបាលនេះជារដ្ឋបាលនៃរដ្ឋប្រជាធិបតេយ្យ ពោលគឺ រដ្ឋបាល ត្រូវគោរពគោលការណ៍នីត្យានុកូលភាព៖ រដ្ឋធម្មនុញ្ញ សន្ធិសញ្ញាអន្តរជាតិ ច្បាប់ បទបញ្ជា និងគោលការណ៍ទូទៅនៃច្បាប់។

ក្នុងករណីរដ្ឋបាលប្រព្រឹត្តនូវកំហុសណាមួយ រដ្ឋបាលត្រូវទទួលខុសត្រូវ។ ការទទួលខុសត្រូវនេះ ត្រូវធ្វើឡើងនៅចំពោះមុខចៅក្រម។ ចៅក្រម ត្រួតពិនិត្យនីត្យានុកូលភាពផ្ទៃក្រៅលិខិត (សមត្ថកិច្ចរបស់អាជ្ញាធរដែលចេញសេចក្តីសម្រេច ទម្រង់ នីតិវិធី) និងផ្ទៃក្នុងលិខិត (ការរំលោភច្បាប់ ការភាន់ច្រឡំ ខាងការវាយតម្លៃលើអង្គច្បាប់ អង្គហេតុ)។

រដ្ឋបាល ធ្វើសកម្មភាពនៃផលប្រយោជន៍ទូទៅ ក្នុងនាមធម្មានុរូបកម្មប្រជាធិបតេយ្យ។ ចំពោះរឿងនេះ រដ្ឋបាលត្រូវកំណត់វិធានដែលការពារពាស្ត្រប្រជា (ហើយតុលាការត្រូវដាក់ទណ្ឌកម្មលើការរំលោភវិធានទាំងនេះ)។ រដ្ឋបាល ធ្វើសកម្មភាពតែក្នុងក្របខណ្ឌនៃបទដ្ឋានជាឋានានុក្រមប៉ុណ្ណោះ។

[១១] George Burdeau, Administrations compares de l´Europe des douze.

ប្រភពនៃនីត្យានុកូលភាពនេះ ត្រូវកំណត់ជាឋានានុក្រមហើយមានច្រើន។ អាជ្ញាធរដែលបង្កើតច្បាប់នេះ ក៏ត្រូវមានឋានានុក្រមដែរ ហើយត្រូវគោរពឋានានុក្រមរវាងគ្នា និងគ្នា។

**កថាខណ្ឌ ១ ការគោរពនៃនីត្យានុកូលភាពជាឋានានុក្រមដោយរដ្ឋបាល**

មាត្រា ១៥០ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ ចែងថា

*"រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។*

*ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។"*

តាម Pure Theory of Law[១២](Hans Kelsen)ត្រូវបានបោះពុម្ពផ្សាយដំបូងនៅឆ្នាំ ១៩៣៤៖ ទ្រឹស្តីនេះបញ្ជាក់ពីឋានានុក្រមនៃច្បាប់ដែលផ្តើមចេញពីបទដ្ឋានជាមូលដ្ឋាន (ឬហៅថា Grundnorm) បទដ្ឋានដែលមានឋានានុក្រមខ្ពស់ជាង មានឧត្តមភាពលើបទដ្ឋានដែលមានឋានានុក្រមទាបជាង។ បទដ្ឋានដែលមានឋានានុក្រមទាបជាង មិនអាចចែងផ្ទុយក៏ដូចជាមិនអាចបន្ថែមលក្ខខណ្ឌចង្អៀតមួយចំនួន ឬ បន្ថយដែនអនុវត្តន៍នៃបទដ្ឋានដែលមានឋានានុក្រមខ្ពស់ជាង។

**១. បទដ្ឋាននៅក្រៅរដ្ឋបាល**

បទដ្ឋានគឺជាកម្មវត្ថុ ខ្លឹមសារ ធាតុសំខាន់នៃលិខិតរដ្ឋបាលមួយ ឬសេចក្តីសម្រេចរដ្ឋបាលមួយ។ បទដ្ឋានផ្ទៃក្រៅ សំដៅដល់សមត្ថកិច្ចនៃអាជ្ញាធរដែលត្រូវចេញលិខិត នីតិវិធី និងទម្រង់ដែលត្រូវគោរព។ ដូច្នេះ ដើម្បីឱ្យសេចក្តីសម្រេចរដ្ឋបាលមួយស្របច្បាប់ ឬមាននីត្យានុកូលភាព តើសេចក្តីសម្រេចរដ្ឋបាលនេះត្រូវស្របទៅនឹងប្រភពនៃច្បាប់ជាតិណាខ្លះ?

**ក.រដ្ឋធម្មនុញ្ញ**

រដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត (មាត្រា ១៥០ ថ្មី នៃរដ្ឋធម្មនុញ្ញ ១៩៩៣)។

[១២] http://en.wikipedia.org/wiki/Hans_Kelsen។

សេចក្តីសម្រេចរដ្ឋបាលមួយ ដាច់ខាតត្រូវស្របទៅនឹងរដ្ឋធម្មនុញ្ញ។ ក្នុងករណីសេចក្តីសម្រេចផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ ចៅក្រមនឹងប្រកាសពីមោឃភាពរបស់វា ហើយគ្មានអានុភាពគតិយុត្តអ្វីឡើយ។ តើបច្ចេកទេសបែបណា ដែលចៅក្រមត្រូវផ្អែកលើ ដើម្បីត្រួតពិនិត្យ និងមោឃភាពចោល សេចក្តីសម្រេចដែលផ្ទុយនេះ។

មាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ចែងថា *"បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងរឿងក្តីណាមួយ ហើយរឿងក្តីនោះឡើងដល់តុលាការ បុគ្គលនោះអាចលើកអំពីអធម្មនុញ្ញភាពនូវបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬសេចក្តីសម្រេច របស់ស្ថាប័ននានាដែលគេអះអាងថាប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេ ជូនតុលាការបាន។*

*បើយល់ឃើញថាការលើកឡើងនេះមានមូលដ្ឋានគ្រប់គ្រាន់ តុលាការត្រូវលើករណីនេះទៅតុលាការកំពូលក្នុងរយៈពេល ១០ថ្ងៃយ៉ាងយូរ។"*

ដើម្បីត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជា ចៅក្រមសាលាដំបូងអនុវត្តទ្រឹស្តីនៃច្បាប់ អេក្រង់ ដូចដែលពន្យល់ដោយមាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅឧត្តម ក្រុមប្រឹក្សានៃអង្គចៅក្រម។

# រដ្ឋធម្មនុញ្ញ




“ទ្រឹស្តីនៃច្បាប់អេក្រង់៖ មាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រក្សា ធម្មនុញ្ញ ឆ្នាំ១៩៩៨។”

### ខ.សន្ធិសញ្ញាអន្តរជាតិ

តាមគោលការណ៍ច្បាប់ សន្ធិសញ្ញាអន្តរជាតិជាប្រភពមួយនៃច្បាប់អន្តរជាតិមិនជាប់ពាក់ព័ន្ធនឹងច្បាប់ជាតិទេ។ ប្រព័ន្ធច្បាប់ទាំងពីរនៅដាច់ពីគ្នា ឯករាជ្យពីគ្នា ស្វយ័តរៀងៗខ្លួន ដោយផ្អែកលើកត្តាបី ៖ ប្រភពឆន្ទៈនៃការបង្កើតវិធានច្បាប់ ប្រធាននៃច្បាប់ ឋានានុក្រមនៃច្បាប់។

ប្រភពឆន្ទៈ ៖ សន្ធិសញ្ញាអន្តរជាតិកើតចេញពីប្រធាននៃនីតិច្រើន( រដ្ឋ អង្គការអន្តរជាតិ) ចំណែកឯច្បាប់ជាតិវិញ កើតចេញពីរដ្ឋជាតិតែមួយប៉ុណ្ណោះ។ ប្រធាននៃច្បាប់អន្តរជាតិគឺរដ្ឋ និងអង្គការអន្តរជាតិ ចំណែកឯប្រធាននៃច្បាប់ជាតិវិញគឺរដ្ឋជាតិ និងបុគ្គល។ ក្នុងប្រព័ន្ធច្បាប់អន្តរជាតិ គ្មានទេឋានានុក្រមរវាងប្រភព។ ផ្ទុយទៅវិញរវាងប្រភពនៃច្បាប់ជាតិវិញមានឋានានុក្រម។

ប្រការដែលថា ប្រព័ន្ធច្បាប់ទាំងពីរឯករាជ្យពីគ្នានេះ មិនមែនមានន័យថាវាមិនទាក់ទងគ្នានោះទេ។ សន្ធិសញ្ញាអន្តរជាតិអាចក្លាយជាប្រភពមួយទាំងស្រុងនៃច្បាប់ជាតិ កាលណារដ្ឋជាតិព្រមទទួលយកវាមកអនុវត្តដូចជាប្រភពនៃច្បាប់ជាតិដែរ តាមការផ្តល់សច្ចាប័ន ការចុះហត្ថលេខា ការអនុម័តយល់ព្រម ស្វីការ ការសុំចូលជាភាគី ហើយដើម្បីពន្យល់ពីការព្រមទទួលយកនេះ មានទ្រឹស្តីពីរដែលត្រូវធ្វើជាមូលដ្ឋាន៖ ទ្រឹស្តីទ្វិកនិយម និងទ្រឹស្តីឯកនិយម។ ចំពោះទ្រឹស្តីទីមួយ ប្រព័ន្ធច្បាប់ទាំងពីរមានសុពលភាពដូចគ្នាក្នុងការអនុវត្តវា។ ចំពោះទ្រឹស្តីទីពីរ ដើម្បីអោយសន្ធិសញ្ញាមួយមានសុពលភាព ត្រូវបញ្ចូលវាទៅក្នុងប្រព័ន្ធច្បាប់ជាតិជាមុនសិនតាមរយៈអត្ថបទច្បាប់ជាតិ និងកំណត់ពីទីតាំងនៃឋានានុក្រមរបស់វា។

នៅពេលដែលវាក្លាយទៅជាប្រភពមួយ ក្នុងចំណោមប្រភពទាំងឡាយនៃច្បាប់ជាតិ អាជ្ញាធររដ្ឋបាលមានសមត្ថកិច្ចរបស់រដ្ឋ មានកាតព្វកិច្ចគោរពសន្ធិសញ្ញាទាំងនេះ។ ក្នុងករណីផ្ទុយ នឹងត្រូវមោឃភាពដោយតុលាការជាតិ។ នេះហើយ ជាការគោរពនីត្យានុកូលភាពរបស់រដ្ឋបាលប្រជាធិបតេយ្យ។

**គ. ច្បាប់**

ច្បាប់ជាវិធានដែលតាក់តែង និងអនុម័តឡើងដោយសភាទៅតាមនីតិវិធីមួយកំណត់ ដោយរដ្ឋធម្មនុញ្ញ។ មាត្រា ១៥០ ថ្មីចែងថា *"ច្បាប់និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត"*។ មាត្រា ២៨ ថ្មីចែងថា *"ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខា លើព្រះរាជក្រមប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ..."*។ ដូច្នេះ ដើម្បីឱ្យច្បាប់បង្កើតអានុភាពគតិយុត្ត ពោលគឺបង្កើតសិទ្ធិ និងកាតព្វកិច្ចទៅបាន លុះត្រាតែមានព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ដែលសភាទាំងពីរអនុម័ត។ របៀបនៃការចូលជាធរមាននៃច្បាប់រៀបចំអង្គការ និងច្បាប់ធម្មតាមិនដូចគ្នាទេ។

ចំពោះការចូលជាធរមាននៃច្បាប់រៀបចំអង្គការ ទាមទារឱ្យមានការត្រួតពិនិត្យជាអាទិកាលនៃធម្មនុញ្ញភាពរបស់វាជាមុនសិន ដោយក្រុមប្រឹក្សាធម្មនុញ្ញ។ មាត្រា ១៤០ ថ្មី ចែងថា *"ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភាឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័ត ទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នោះត្រូវប្រកាសឱ្យប្រើ។ បទបញ្ជាផ្ទៃក្នុងរដ្ឋសភាបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឱ្យប្រើ។ ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចក្នុងរយៈពេល សាមសិប (៣០)ថ្ងៃយ៉ាងយូរ ថាតើច្បាប់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើ ស្របឬមិនស្របនឹងរដ្ឋធម្មនុញ្ញ"*។ ផ្ទុយទៅវិញ ច្បាប់ធម្មតា ចូលជាធរមានចាប់តាំងពីការប្រកាសឱ្យប្រើជាផ្លូវការដោយព្រះរាជក្រម[១៣]។ អធម្មនុញ្ញភាពរបស់វា អាចត្រូវត្រួតពិនិត្យជាបច្ឆាកាល ដោយក្រុមប្រឹក្សាធម្មនុញ្ញ។ មាត្រា ១៤១ ថ្មី ចែងថា *"ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិក ព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ ឬតុលាការ អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ។"* *ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីធម្មនុញ្ញភាពនៃច្បាប់បានតាមរយៈតំណាងរាស្ត្រ ឬ ប្រធានរដ្ឋសភា ឬសមាជិកព្រឹទ្ធសភាឬប្រធានព្រឹទ្ធសភាដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ។*

*តាមឋានានុក្រមនៃលិខិតបទដ្ឋានគតិយុត្ត បទបញ្ជា ត្រូវស្របដាច់ខាតទៅនឹងច្បាប់។ ដើម្បីធានាការគោរពឋានានុក្រមនេះ តុលាការត្រួតពិនិត្យអនីត្យានុកូលភាពនៃរាល់សេចក្តីសម្រេចរដ្ឋបាលទាំងឡាយណាដែលផ្ទុយទៅនឹងច្បាប់ តាមរយៈឧបាស្រ័យ ពីបទរំលោភអំណាចក្តី ឬឧបាស្រ័យពីវិវាទពេញទី។ មាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា "អំណាចតុលាការ ជាអំណាចឯករាជ្យ។ អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ អំណាចតុលាការ គ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង។ អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែកនិងគ្រប់ជាន់ថ្នាក់។"*

មាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញ បើកសិទ្ធិឱ្យប្រជាពលរដ្ឋអាចប្តឹងទាស់នឹងការរំលោភច្បាប់ដោយអាជ្ញាធររបស់រដ្ឋ។ មាត្រា ៣៩ *"ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ាឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម*

[១៣] មាត្រា ៩៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣។

*និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាត ជាសមត្ថកិច្ចរបស់តុលាការ។"*

រដ្ឋបាលមិនអាចគេចផុតពីការត្រួតពិនិត្យរបស់តុលាការបានឡើយ កាលណារដ្ឋបាលចេញសេចក្តីសម្រេចអនីត្យានុកូលមួយ។ តុលាការក្នុងពេលតែមួយ កំណត់ពីព្រំដែននៃការប្រើអំណាចរបស់រដ្ឋបាលផង និងធានាការគោរពសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋផង។ ជានិច្ចកាល រដ្ឋបាលក្នុងន័យនៃការគោរពនីតិរដ្ឋ ត្រូវស្ថិតនៅក្រោមវិធានច្បាប់។

**ឃ. គោលការណ៍ទូទៅនៃច្បាប់[១៤]**

គោលការណ៍ទូទៅនៃច្បាប់ ជាវិធានដែលចៅក្រមបង្កើតឡើង ដោយទាញចេញពីស្មារតីនៃច្បាប់ជាធរមាន ហើយចៅក្រម អះអាងថា វាមានអានុភាពអនុវត្តន៍ដាច់ខាត ដែលអាជ្ញាធររដ្ឋបាលត្រូវតែគោរព។ ចៅក្រម បង្កើតគោលការណ៍ទូទៅនៃច្បាប់នេះ ក្នុងគោលបំណងបំពេញភាពខ្វះចន្លោះនៃច្បាប់សរសេរ។ គោលការណ៍ទូទៅនៃច្បាប់អាចមានតម្លៃជារដ្ឋធម្មនុញ្ញ អាចមានតម្លៃខ្ពស់ជាងបទបញ្ជា។ គោលការណ៍នេះ បច្ចុប្បន្នមានតួនាទីមិនសូវសំខាន់ប៉ុន្មានទេ ដោយសារសុក្រឹតភាពនៃច្បាប់។ ចំពោះច្បាប់អន្តរជាតិវិញ គោលការណ៍ទូទៅនៃច្បាប់ ដើរតួនាទីដ៏សំខាន់មួយ ក្នុងចំណោមប្រភពផ្សេងទៀតនៃច្បាប់អន្តរជាតិ។ មាត្រា៣៨ នៃលក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ ចែងថា *"តុលាការ... អនុវត្តអនុសញ្ញាទូទៅក្តី ពិសេសក្តី ទំនៀមទម្លាប់អន្តរជាតិ គោលការណ៍ទូទៅនៃច្បាប់ ..."*។

ក្នុងការអនុវត្តច្បាប់ ក្នុងន័យទូលាយនៃច្បាប់ តុលាការជាតិរបស់យើងមិនទាន់អនុវត្តគោលការណ៍នេះនៅឡើយ។

រាល់សេចក្តីសម្រេចរដ្ឋបាល ដាច់ខាតត្រូវស្របទៅនឹងគោលការណ៍ទូទៅនៃច្បាប់។ ក្នុងករណីផ្ទុយ សេចក្តីសម្រេចនេះនឹងត្រូវមោឃភាពដោយតុលាការ។

គោលការណ៍ទូទៅនៃច្បាប់ត្រូវ បានធ្វើចំណាត់ថ្នាក់ដូចតទៅៈ

**ក្រុមទី១** គោលការណ៍ដែលឆ្លុះបញ្ចាំងពីប្រពៃណីសេរីៈ គោការណ៍សមភាពនៃអ្នកប្រើប្រាស់នៅចំពោះមុខសេវាសាធារណៈ គោលការណ៍សមភាពក្នុងការចូលទៅប្រឡងប្រជែងក្នុង មុខងារសាធារណៈ សេរីភាពសម្តែងមតិ សេរីភាពមនៈសិការ សេរីភាពនៃការបង្រៀន សេរីភាពបញ្ចេញមតិ...។

[១៤] Fr.wikipedia.org/wiki/Hiérarchie_des_normes_en_droit_français. 28/07/2014។

**ក្រុមទី២** គោលការណ៍ដែលទាក់ទងទៅនឹងការការពារនៃរាស្ត្រប្រជាៈ គោលការណ៍នៃភាពមិនប្រតិសកម្មនៃលិខិតរដ្ឋបាល គោលការណ៍នៃសិទ្ធិការពារខ្លួន គោលការណ៍នៃលក្ខខណៈចំពោះមុខនៃគ្រប់ គោលការណ៍នៃលក្ខខណៈចំពោះមុខនៃគ្រប់នីតិវិធីតុលាការ (ភាគីត្រូវដឹងពីទឡ្ហីករសំណុំឯកសារនីតិវិធីរបស់ភាគីមួយផ្សេងទៀត ដើម្បីការពារខ្លួនឱ្យបានល្អ) ភាពមិនលម្អៀងនៃ រដ្ឋបាល។

**ក្រុមទី៣** គោការណ៍ទូទៅនៃសមធម៌ និងសេដ្ឋកិច្ចនៃសង្គម ៖ គោលការណ៍សមភាពនៃភេទ គោលការណ៍សមភាពនៅចំពោះមុខនៃបន្ទុកសាធារណៈ គោលការណ៍សមភាពនៅចំពោះមុខសេវាសាធារណៈ គោលការណ៍សមភាពនៃនិរន្តរភាពនៃសេវាសាធារណៈ សិទ្ធិរបស់ជនបរទេសក្នុងការជួបជុំគ្រួសារ។

គោលការណ៍ទូទៅមានគុណសម្បត្តិពីរ ការពាររាស្ត្រប្រជាពីវិធានការលើកលែងចេញដោយរដ្ឋបាល តាមកាលានុវត្តភាព ទាញចេញវិធានសំខាន់ៗដែលធ្វើឱ្យប្រព័ន្ធច្បាប់កាន់តែឃើញច្បាស់ឡើង (ធ្វើឱ្យប្រព័ន្ធច្បាប់ស្មុគស្មាញកាន់តែមើលឃើញច្បាស់)។

### ង. យុត្តិសាស្ត្រ

យុត្តិសាស្ត្រជាសេចក្តីសម្រេចរបស់តុលាការ។ យុត្តិសាស្ត្រមានពីរប្រភេទៈ យុត្តិសាស្ត្រសំខាន់ដែលជាសេចក្តីសម្រេចរបស់តុលាការកំពូលសម្រេចជាសភាពេញអង្គ និងយុត្តិសាស្ត្រធម្មតាដែលជាសេចក្តីសម្រេចរបស់តុលាការជាន់ទាប។ តាមគោលការណ៍ យុត្តិសាស្ត្រមិនមែនជាប្រភពផ្ទាល់នៃច្បាប់ទេ ពីព្រោះវាគ្រាន់តែជាដំណោះស្រាយសម្រាប់ភាគីជម្លោះតែប៉ុណ្ណោះ វាបង្កើតអានុភាពតែចំពោះភាគីជម្លោះប៉ុណ្ណោះ វាគ្មានអានុភាព Erga Omnes ទេ(អានុភាពចាប់បង្ខំឱ្យអនុវត្តទាំងអស់គ្នា។ ប៉ុន្តែ ដើម្បីធានាឱ្យមាន សន្តិភាព ក្នុងការអនុវត្ត អាជ្ញាធររដ្ឋបាលត្រូវគោរពឱ្យបានយុត្តិសាស្ត្រ។

## ២. បទដ្ឋានដែលចេញដោយរដ្ឋបាលខ្លួនឯងផ្ទាល់ (បទបញ្ជា)

បទបញ្ជាជាវិធានទូទៅ និងមិនចំពោះបញ្ញត្តិចេញដោយអាជ្ញាធរដែលមានអំណាចបញ្ជាដាក់បង្ខំឱ្យរាស្ត្រប្រជាអនុវត្តតាម។ បទបញ្ជា ចេញដោយនាយករដ្ឋមន្ត្រី ជាបទបញ្ជាទូទៅនៃនីតិរូមបានន័យថា វាមានវិសាលភាពអនុវត្តគ្របដណ្តប់លើផ្ទៃប្រទេសទាំងមូល និងក្នុងគ្រប់វិស័យទាំងអស់។ ចំណែកឯបទបញ្ជាដែលចេញដោយអាជ្ញាធរក្រៅពីនាយករដ្ឋមន្ត្រី (រដ្ឋមន្ត្រី អភិបាលរាជធានី-ខេត្ត ប្រធានគ្រឹះស្ថានសាធារណៈ...) ជាបទបញ្ជាធម្មតា។ បទបញ្ជាដែលចេញដោយ

អាជ្ញាធរដែលមានឋានានុក្រមទាបជាង ត្រូវគោរពបទបញ្ជាដែលចេញដោយអាជ្ញាធរដែលមានឋានានុក្រមខ្ពស់ជាង ហើយអាជ្ញាធរដែលមានអំណាចចេញបទបញ្ជា ក៏ត្រូវគោរពបទបញ្ជាដែលខ្លួនបានចេញផងដែរ។ នេះហើយជាការគោរពនីត្យានុកូលភាពរដ្ឋបាល។

### ក. ព្រះរាជក្រឹត្យ

រដ្ឋធម្មនុញ្ញផ្តល់ទៅឱ្យអង្គការនីតិប្រតិបត្តិ (ប្រមុខរដ្ឋ និងរាជរដ្ឋាបាល) ក្នុងការចេញលិខិតដែលមានវិសាលភាពទូទៅ និងចំពោះ (អំណាចចេញបទបញ្ជា)។ គឺជាបទដ្ឋានដែលមានឋានានុក្រមខ្ពស់ជាងគេ នៃអំណាចបញ្ជាអនុវត្តដោយអង្គការនីតិប្រតិបត្តិ) ព្រះរាជក្រឹត្យ ត្រូវឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ (មាត្រា ២៨នៃរដ្ឋធម្មនុញ្ញ) ចុះហត្ថលេខាអមដោយនាយករដ្ឋមន្ត្រី និងជូនកាលដោយរដ្ឋមន្ត្រី។ ព្រះរាជក្រឹត្យមាន ព្រះរាជក្រឹត្យតែងតាំង និងព្រះរាជក្រឹត្យបង្កើត នៅទីនេះ យើងនិយាយតែព្រះរាជក្រឹត្យបង្កើតតែប៉ុណ្ណោះដែលជាបទបញ្ជា ខុសពីអនុក្រឹត្យ ប្រកាស ដីកាសេចក្តីណែនាំ...។

### ខ. អនុក្រឹត្យ

អនុក្រឹត្យ ជាសេចក្តីសម្រេចចេញដោយនាយករដ្ឋមន្ត្រី។ មានអនុក្រឹត្យពីរប្រភេទ ៖ អនុក្រឹត្យដែលមានលក្ខណៈជាបទបញ្ជា (អនុក្រឹត្យបង្កើត) និងអនុក្រឹត្យឯកត្តភូត (អនុក្រឹត្យតែងតាំង)។ អនុក្រឹត្យដែលមានលក្ខណៈជាបទបញ្ជា ជាសេចក្តីសម្រេចបញ្ញត្តិចេញនូវវិធានទូទៅ និងមិនចំពោះ ហើយមានវិសាលភាពអនុវត្តន៍លើផ្ទៃប្រទេសទាំងមូល។ បទបញ្ជារបស់នាយករដ្ឋមន្ត្រី ក្រៅពីអនុក្រឹត្យអាចមានទម្រង់ផ្សេងៗទៀត(បទបញ្ជា សេចក្តីសម្រេច សេចក្តីណែនាំ បញ្ជារបស់រាជរដ្ឋាភិបាល)។ ក្នុងកង្វល់នៃការគោរពគោលការណ៍នីត្យានុកូលភាពរដ្ឋបាល រាជរដ្ឋាភិបាល ក៏ដូចជានាយករដ្ឋមន្ត្រីដែរ ដោយមិនគិតពីទម្រង់នៃបទបញ្ជារបស់ខ្លួន ដាច់ខាតត្រូវគោរពបទបញ្ជាដែលខ្លួន បានចេញទាំងនេះ។

នាយករដ្ឋមន្ត្រី អាចចេញបទបញ្ជានគរបាល ពោលគឺ បទបញ្ជាដែលសំដៅអនុញ្ញាតឱ្យធ្វើអ្វីមួយ ឬ ហាមប្រាមមិនឱ្យធ្វើអ្វីមួយ។ និយាយឱ្យច្បាស់ជាងនេះទៅទៀត គឺវិធានការទាំងឡាយណាទាក់ទងនឹងសេរីភាពសាធារណៈ។ ឧទាហរណ៍ បទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ ចុះថ្ងៃ ទី០៧ ខែឧសភា ឆ្នាំ២០១២ ស្តីពីការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច។

បទបញ្ជារបស់នាយករដ្ឋមន្ត្រីហៅថា បទបញ្ជាទូទៅនៃនីតិវិធី។ បទបញ្ជាដែលចេញដោយអាជ្ញាធរក្រៅពីនាយករដ្ឋមន្ត្រីហៅថាបទបញ្ជាធម្មតា។

**គ. ប្រកាស**

ជាសេចក្តីសម្រេចចេញដោយរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ។ ប្រកាសមានពីរប្រភេទ៖ ប្រកាសដែលមានលក្ខណៈជាបទបញ្ជាដែលជាវិធានទូទៅ និងមិនចំពោះ ហើយមានវិសាលភាពអនុវត្តន៍តែក្នុងរង្វង់សមត្ថកិច្ចរបស់ក្រសួង ឬ រដ្ឋលេខាធិការដ្ឋានតែប៉ុណ្ណោះ។ ប្រកាសដែលជាសេចក្តីសម្រេចរដ្ឋបាលឯកត្តភូតទាក់ទងតែទៅនឹងបុគ្គលម្នាក់ ឬ បុគ្គលច្រើននាក់ដែលស្ថិតនៅក្នុងស្ថានភាពដូចៗគ្នា ហើយចង្អុលប្រាប់ឈ្មោះចំៗ(ប្រកាសស្តីពីការតែងតាំង) ។ ក្រៅពីប្រកាស រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ក៏អាចចេញសេចក្តីសម្រេចដែលមានទម្រង់ផ្សេងៗទៀតដែរ (សេចក្តីសម្រេច បទបញ្ជា...)។ រដ្ឋមន្ត្រីដាច់ខាតត្រូវគោរពសេចក្តីសម្រេចដែលខ្លួនបានចេញ។

**ឃ. ដីកា**

ដីកាជាសេចក្តីសម្រេចនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលចេញដោយអាជ្ញាធររៀងគ្នា ក្រុមប្រឹក្សាជាប់ឆ្នោត រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ដីការទាំងនេះសុទ្ធតែមានលក្ខណៈជាបទបញ្ជា។

## កថាខណ្ឌ ២ ការអនុវត្តប្រែប្រួលនៃគោលការណ៍នីត្យានុកូលភាព

ការគោរពរបស់រដ្ឋបាលចំពោះគោលការណ៍នេះ មិនត្រូវរំខានរដ្ឋបាលក្នុងសកម្មភាពរបស់ខ្លួន និងធ្វើឱ្យរដ្ឋបាលគ្មានប្រសិទ្ធភាពនោះទេ។ ជានិច្ចកាល រដ្ឋបាលមិនមានសេរីភាព ក្នុងការធ្វើសកម្មភាពទៅតាមទំនើងចិត្តរបស់ខ្លួនទេ។ តាមពិត គួរញែកឱ្យដាច់ស្ថានភាពពីរ។ ក្នុងករណីទី១ រដ្ឋបាលគ្មានអំណាចឱ្យតម្លៃណាមួយទាល់តែសោះ។ គេនិយាយថា រដ្ឋបាលស្ថិតក្នុងស្ថានភាពនៃសមត្ថកិច្ចជាប់ចំណង[១៥]។ ខ្លឹមសារនៃសេចក្តីសម្រេចរដ្ឋបាល ត្រូវកំណត់ជាមុនទាំងស្រុង ដោយច្បាប់ ដែលកំណត់ពីធាតុនៃអង្គហេតុមួយចំនួនចាំបាច់ សម្រាប់ការចេញសេចក្តីសម្រេច។

ក្នុងស្ថានភាពផ្សេងទៀត រដ្ឋបាលប្រើអំណាចឱ្យតម្លៃបាន ដែលអាចចែកចេញជាពីរ។ ក្នុងករណីមួយចំនួន សេចក្តីសម្រេចរដ្ឋបាលស្ថិតនៅក្រោមធាតុនៃអង្គហេតុមួយចំនួន ដែលរដ្ឋបាលត្រូវឱ្យតម្លៃដោយខ្លួនឯង។ ផ្ទុយទៅវិញ ក្នុងករណីផ្សេងទៀត សេចក្តីសម្រេចរដ្ឋបាល អាចឯករាជ្យ

[១៥]www.vie-public.fr.

ទាំងស្រុងពីធាតុនៃអង្គហេតុ ដូច្នេះ រដ្ឋបាលមានអ្វីដែលគេហៅថា អំណាចឆន្ទានុសិទ្ធិ[១៦]។ ប្រការនេះមានន័យថា ច្បាប់ដែលបានផ្តល់សមត្ថកិច្ចពិសេសទៅឱ្យអាជ្ញាធររដ្ឋបាល ទុកឱ្យរដ្ឋបាលមានសេរីភាពក្នុងការជ្រើសរើស រវាងសេចក្តីសម្រេចជាច្រើន ដែលសុទ្ធតែស្របច្បាប់ទាំងអស់ វិស័យកាន់តែបច្ចេកទេសខ្លាំង ចៅក្រមរដ្ឋបាលកាន់តែមាននិន្នាការចាត់ទុកថា រដ្ឋបាលមានអំណាចឆន្ទានុសិទ្ធិ បែបណាមួយនោះ។

ការត្រួតពិនិត្យធ្វើឡើងដោយចៅក្រមរដ្ឋបាល លើប្រភេទសកម្មភាពរដ្ឋបាលផ្សេងៗទាំងនេះមិនប្រាកដនៅទ្រឹងនោះទេ។ ដូច្នេះ ក្នុងវិស័យមួយចំនួន ដែលស្ថិតនៅក្រោមអំណាចឆន្ទានុសិទ្ធិរបស់រដ្ឋបាល បន្តិចម្តងៗ គេឆ្លងពីការមិនមានការត្រួតពិនិត្យ ទៅកាន់ការត្រួតពិនិត្យអប្បបរមាមួយ ហៅថាការត្រួតពិនិត្យលើការភាន់ច្រឡំជាក់ក្រឡែត នៃការឱ្យតម្លៃដើម្បីបញ្ចប់ដោយការត្រួតពិនិត្យមួយ ដែលមានការពង្រឹង ហៅថាការត្រួតពិនិត្យសមាមាត្រ។ ដូច្នេះ សេចក្តីសម្រេចចេញនៅក្នុងក្របខណ្ឌនៃអំណាចឆន្ទានុសិទ្ធិ គេចមិនផុតពីច្បាប់ ហើយក៏មិនចាំបាច់ត្រូវការពារដោយការ ត្រួតពិនិត្យមួយរបស់ចៅក្រមដ៏មានប្រសិទ្ធភាពនោះទេ។

### ១. សមត្ថកិច្ចជាប់ចំណងរបស់រដ្ឋបាល

សមត្ថកិច្ចជាប់ចំណងខាងនីតិរដ្ឋបាល គឺជាអំណាចមួយ ដែលអាជ្ញាធរមានសមត្ថកិច្ចត្រូវតែប្រើ ទោះជាចង់ ឬមិនចង់។ សញ្ញាណនេះ ផ្ទុយទៅនឹងសញ្ញាណឆន្ទានុសិទ្ធិ។ សមត្ថកិច្ចជាប់ចំណង ពីព្រោះវាត្រូវរៀបចំឡើងដោយអត្ថបទផ្សេងទៀត (គោលការណ៍នីត្យានុកូលភាព) ដែលកំណត់ពីលក្ខខណ្ឌ ដោយពុំទុកឱ្យអាជ្ញាធរមានកិច្ចកំណត់។ ឧទាហរណ៍ ព្រះមហាក្សត្រ ឡាយព្រះហស្តលេខា លើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ដែលអនុម័តដោយសភាទាំងពីរ។ (មាត្រា ២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣)។ ព្រះមហាក្សត្រ តែងតាំងមន្ត្រីជាន់ខ្ពស់យោធា (មាត្រា ២១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)។ តាមទ្រឹស្តីប្រការនេះមានន័យថា ព្រះមហាក្សត្រគ្មានជម្រើស ហើយថានៅក្នុងករណីនៃមាត្រា ២៨ ព្រះមហាក្សត្រ គ្មានព្រះរាជសិទ្ធិជំទាស់ទេ។ តាមពិតព្រះមហាក្សត្រ អាចបដិសេធការឡាយព្រះហស្តលេខាប្រកាសឱ្យប្រើច្បាប់បាន ព្រោះគ្មានទណ្ឌកម្មណាមួយចែងឡើយ។ ទោះជាក្នុងទ្រឹស្តី ច្បាប់ដែលមិនទាន់ប្រកាសឱ្យប្រើ ត្រូវអនុវត្តន៍បានក៏ដោយ ក៏ច្បាប់នោះ អាចនឹងអនុវត្តន៍យ៉ាងលំបាក ដោយសារតែ

[១៦] ibid.

ព្រះមហាក្សត្រ ស្មោះត្រង់នឹងព្រះរាជតួនាទីរបស់ព្រះអង្គ។ ករណីនេះ មិនដែលកើតមានទេ រហូតមកដល់ពេលបច្ចុប្បន្ននេះ ក្រោមព្រះរាជាណាចក្រទីពីរ។

សមត្ថកិច្ចជាប់ចំណង មាននៅគ្រប់ថ្នាក់រដ្ឋបាលទាំងអស់ ពីប្រមុខរដ្ឋដល់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬមេឃុំ ចៅសង្កាត់។

សមត្ថកិច្ចជាប់ចំណាង គឺន័យប្រដូចបានខាងផ្នែករដ្ឋបាល និងទុយោធម្មតា ដោយគ្មានក្បាលម៉ាស៊ីនរ៉ូបីណោ។ ក្បាលរ៉ូបីណោនៅកន្លែងផ្សេង។

## ២. អំណាចឆន្ទានុសិទ្ធិរបស់រដ្ឋបាល

អំណាចឆន្ទានុសិទ្ធិ[១៧] គឺជាអំណាចក្នុងការចេញសេចក្តីសម្រេច ដោយមានសេរីភាពច្រើន ឬតិច ក្នុងការប្រើអំណាចឱ្យតម្លៃទៅតាមកាលានុវត្តភាព។ គោលការណ៍នៃអំណាចឆន្ទានុសិទ្ធិនេះ ត្រូវ ស្ថិតក្រោមគោលការណ៍នីត្យានុកូលភាព។ រដ្ឋបាល មានសេរីភាពក្នុងការចេញសេចក្តីសម្រេចឱ្យស្របទៅនឹងច្បាប់។

លទ្ធភាពក្នុងការរត់ទៅរកជម្រើសមួយចំនួនដែលអាចធ្វើទៅបាន ដោយយោងទៅលើស្ថានភាពដែលត្រូវកំណត់ដោយក្របខណ្ឌច្បាប់ ឬក្នុងករណីពុំមានអត្ថបទច្បាប់ចែងយោងលើយុត្តិសាស្ត្រ។ អំណាចឆន្ទានុសិទ្ធិ ត្រូវកំណត់ដោយកាតព្វកិច្ចនីត្យានុកូលភាព។ តាមធម្មតាអំណាចនេះ ស្ថិតនៅក្រោមការត្រួតពិនិត្យនីត្យានុកូលភាពផ្ទៃក្នុង និងផ្ទៃក្រៅ។

សេចក្តីសម្រេចរបស់រដ្ឋបាល រមែងអមទៅជាមួយការអនុវត្តវិធានការឆន្ទានុសិទ្ធ។ គួរធ្វើ ឬមិនគួរធ្វើ និង គួរអនុម័ត និង មិនគួរអនុម័ត ឬត្រូវអនុម័តដោយមានលក្ខខណ្ឌ។ តួនាទីនៃសេចក្តីសម្រេចដែលចេញត្រូវវិនិច្ឆ័យ ដែលផ្អែកលើពត៌មានដែលពាក់ព័ន្ធ[១៨]។

នៅក្នុងរដ្ឋបាលប្រជាធិបតេយ្យទាំងអស់ មិនថាប្រទេសដែលមានប្រព័ន្ធច្បាប់ Civil Law ឬ Common Law ទេ រដ្ឋបាលត្រូវគោរពនីតិរដ្ឋ[១៩]។ ដូច្នេះ រាល់សេចក្តីសម្រេចរដ្ឋបាល ត្រូវស្របច្បាប់ជានិច្ច បើពុំនោះទេ រដ្ឋដែលស្ថិតនៅក្នុងបញ្ហា នឹងត្រូវវាយតម្លៃថាជារដ្ឋនគរបាល (Polizeisstaat)[២០]។

អ្វីដែលខុសគ្នារវាងរដ្ឋបាលនៃប្រទេសដែលមានប្រព័ន្ធច្បាប់ Common Law និង Civil Law គឺថា រដ្ឋបាល Common Law ចេញសារាចរ ឬសេចក្តីណែនាំ ទាក់ទងនឹងដំណោះស្រាយអ្វី

[១៧] www.toupie.org/Dictionnaire/Pouvoir_discretionnaire.htm.
[១៨] Exercise-of-discretion-in-admin-decision-making.pdf
[១៩] J.Ziller, Administrations compares. Les systèmes politico-administratifs de l'Europe des Douzes, 1994.
[២០] www.google.fr/#q=polizeisstaat (04/03/2014)

មួយដោយរបៀបលម្អិត (អភិក្រមលម្អិត)។ សេចក្តីសម្រេចរដ្ឋបាលក្នុងប្រព័ន្ធ Common Law ស្មើរនឹងសេចក្តីសម្រេចរបស់តុលាការ។ ផ្ទុយទៅវិញ រដ្ឋបាលក្នុងប្រព័ន្ធ Civil Law បកស្រាយច្បាប់មុននឹងអនុវត្តន៍វា។ ដូច្នេះ ក្នុងពេលតែមួយ ដើម្បីចៀសវាងអនីត្យានុកូលភាពរបស់វា រដ្ឋបាលត្រូវផ្អែកលើនីត្យានុកូលភាពផង (សមត្ថកិច្ចជាប់ចំណង) នឹងកាលានុវត្តភាពផង (អំណាចឆន្ទានុសិទ្ធិ)។

រដ្ឋបាល ជាឱបករណ៍ដ៏សំខាន់នៃអំណាច។ វាមានលក្ខណៈផ្តាច់ការ រដ្ឋបាលបង្ខំឱ្យបុគ្គលអនុវត្តន៍សេចក្តីសម្រេចរបស់ខ្លួនជាឯកត្តោភាគី។ ក្នុងករណីរឹងទទឹង រដ្ឋបាលបង្ខំតាមការប្រើកម្លាំងឱ្យបុគ្គលអនុវត្តន៍សេចក្តីសម្រេចរបស់ខ្លួន។ រដ្ឋអាចប្រើសេចក្តីសម្រេចសាធារណៈ ដែលខ្លួនមានភាពផ្តាច់មុខ ប៉ុន្តែការប្រើកម្លាំងនេះ ក៏ត្រូវគោរពព្រំដែនរបស់វាដែរ មានន័យថា គេបង្ខំរដ្ឋបាល ឱ្យគោរពវិធានមួយចំនួន ដែលរាស្ត្រប្រជាអាចទាមទារឱ្យមានការគោរពនេះ។ ការជំទាស់នេះ ត្រូវបន្ទន់បន្តិចជាមួយនឹងសញ្ញាណនៃរដ្ឋប្រជាធិបតេយ្យ។ វិធាននីតិ មិនចងជើងរដ្ឋបាលដែលទទួលបាននូវអំណាចវាយតម្លៃដ៏ធំទូលាយលើកាលានុវត្តភាពនៃសកម្មភាពរបស់ខ្លួនទេ ចំពោះរឿងនេះ រដ្ឋបាលមានអំណាចឆន្ទានុសិទ្ធិ (ចេញសេចក្តីសម្រេច នៅក្រៅវិធានដែលបានរៀបចំ)។ រដ្ឋបាលក៏មានអំណាចបកស្រាយដ៏ទូលាយដែរ (អំណាចឱ្យតម្លៃលើវិធាន) ស្របទៅនឹងច្បាប់។

### ៣. ករណីបន្ទាន់ ឬកាលៈទេសៈពិសេស ៖ ការសម្របតម្រូវនៃគោលការណ៍នីត្យានុកូលភាព

មានសម្មតិកម្មផ្សេងៗដែលក្នុងនោះ ការគោរពគោលការណ៍នីត្យានុកូលភាពដោយរដ្ឋបាលអាចត្រូវបន្ទន់ ដើម្បីផ្តល់លទ្ធភាពឱ្យរដ្ឋបាល ធ្វើសកម្មភាពដោយម៉ឺងម៉ាត់ផង និងឆាប់រហ័សផង។ ដូច្នេះ គេអាចទទួលយកថា ក្នុងកាលៈទេសៈមានវិបត្តិ ភាពចាំបាច់ ត្រូវឈ្នះលើការគោរពដ៏ម៉ឺងម៉ាត់នៃនីត្យានុកូលភាព។

### ៣.១. ទ្រឹស្តីយុត្តិសាស្ត្រនៃកាលៈទេសៈពិសេស

ទ្រឹស្តីកាលៈទេសៈពិសេស ត្រូវបានបង្កើតឡើងដោយកុងសីដេតា[២១] នៅសង្គ្រាមលោកលើកទីមួយ។

[២១]កុងសីដេតា ៖ ជាតុលាការរដ្ឋបាលកំពូល នៅប្រទេសបារាំង។

### ៣.១.១. សញ្ញាណនៃកាលៈទេសៈពិសេស

Heyriès ខុស។ កុងសីដេតា បានវិនិច្ឆ័យថា ដោយយោងតាមរដ្ឋធម្មនុញ្ញ ក្នុងរឿងនេះមាត្រា ៣ នៃ ច្បាប់ធម្មនុញ្ញ ២៥ កុម្ភៈ ១៨៧៥ វាជាសមត្ថកិច្ចនៃអំណាចសាធារណៈ ក្នុងការឃ្លាំមើលនៅគ្រប់ពេលទាំងអស់ សេវាសាធារណៈដែលបង្កើតឡើងដោយច្បាប់ និងបទបញ្ជាឱ្យស្ថិតនៅក្នុងស្ថានភាពដំណើរការទៅ និងតាមដានមើល រាល់ការលំបាកដែលកើតចេញពីសង្គ្រាម ធ្វើយ៉ាងណាមិនឱ្យគាំងដំណើរការ។

ប្រសិនបើរដ្ឋបាលត្រូវគោរពវិធានដែលបង្កើតគោលការណ៍នីត្យានុកូលភាព គោលការណ៍នេះ អាចធ្វើជាកម្មវត្ថុនៃការបត់បែនមួយចំនួន។ ដូច្នេះ កិច្ចមួយចំនួនដូចជា រដ្ឋាភិបាលកិច្ច ឬវិធានការរៀបចំផ្ទៃក្នុង គេចផុតពីការត្រួតពិនិត្យរបស់ចៅក្រមរដ្ឋបាល។ ដូច្នេះ រដ្ឋបាលមានសេរីភាពក្នុងការអនុវត្តគោលការណ៍ដែលខ្លួនចង់ធ្វើ។ ជាពិសេស ចៅក្រមដ្ឋបាលអាចសម្រេចថា វិធាននីតិជាធម្មតា មិនត្រូវអនុវត្តន៍ ដោយសារសារជាតិពិសេសនៃកាលៈទេសៈ។ តួយ៉ាង បញ្ហាដែលចោទឡើងក្នុងសាលដីកានៃថ្ងៃទី ខែ២៨ ឆ្នាំកុម្ភៈ ១៩១៩។

អភិបាលក្រុង ទូឡុង នៅថ្ងៃទី ០៩ ខែមេសា ១៣ ឧសភា និង ២៤ មិថុនា ១៩១៦ ចេញវិធានការខុសៗគ្នា កំណត់នគរបាលរក្សាទម្លាប់ល្អរបស់សង្គម។ ហាមម្ចាស់ហាងលក់គ្រឿងភេសជ្ជៈ ទទួល និងបម្រើឱ្យផឹកដល់ស្រីៗដែលមកម្នាក់ឯងក្តី ឬមានគ្នាក្តី។ សេចក្តីសម្រេចទាំងនោះ ក៏ហាមផងដែរ ចំពោះស្រីៗមកម្នាក់ឯង ក្នុងការកំដរប្រុសៗនៅក្រៅសង្កាត់រក្សាសិទ្ធិ និងការលក់ភេសជ្ជៈ។ ទណ្ឌកម្ម គឺការបណ្តេញចេញពីជំរំទូឡុង ក្នុងករណីមិនរាងចាល នឹងបិទគ្រឹះស្ថាន។ ប៉ះពាល់ក្នុងសកម្មភាពវិជ្ជាជីវៈរបស់ខ្លួន អ្នកស្រី Dol និង Lauren ជាស្រីកំដរស្នើ សុំឱ្យកុងសីដេតា មោឃភាពវិធានការទាំងបីនេះចោល។ កុងសីដេតា ច្រានចោលពាក្យបណ្តឹង នៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ១៩១៩ ដោយវាយតម្លៃថា ព្រំដែនធ្វើឡើងដោយអភិបាលក្រុង ចំពោះសេរីភាពសាធារណៈ មានការបញ្ជាក់ត្រឹមត្រូវចំពោះកាលៈទេសៈនោះ។

អ្វីដែលកំណត់ជាក់លាក់ នៅក្នុងសេចក្តីសម្រេចរបស់កុងសីដេតា គឺពេលដែលវិធានការទាំងនោះត្រូវបានចេញ ពីព្រោះកាលនោះ វាជាសង្គ្រាមលោកលើកទី១។ នៅអំឡុងពេលនោះ វាតែងតែមិនអាចធានាការការពារផលប្រយោជន៍សាធារណៈបាន ដោយគោរពនីត្យានុកូលភាពជាប្រពៃណីនោះ។ ដើម្បីប្រឈមមុខនឹងស្ថានភាពប្រភេទនេះ ច្បាប់មួយចំនួនត្រូវបានអនុម័ត ក្នុងនោះមាន ច្បាប់ស្តីពីវិក្រឹតិកាល ដែលត្រូវអនុវត្តក្នុងរឿងនេះ។ ច្បាប់ទាំងនោះ អនុញ្ញាតឱ្យអាជ្ញាធររដ្ឋបាល ទៅយ៉ាងឆ្ងាយជាងពេលធម្មតា ក្នុងវិធានការដែលខ្លួនត្រូវចេញ។ ប៉ុន្តែ ដោយច្បាប់មិន

អាចថែងបានគ្រប់ ថៅក្រមបានទទួលស្គាល់គោលការណ៍ផ្សេងៗទាំងនេះ ក្នុងយុត្តិសាស្ត្រមួយដែលត្រូវអនុវត្ត កាលណាច្បាប់មានភាពខ្វះចន្លោះ។ នីត្យានុកូលភាពជាអញ្ញត្រកម្មនេះ ដែលត្រូវទទួលស្គាល់ថា ជាទ្រឹស្តីនៃកាលៈទេសៈ ហើយជាកម្មវត្ថុនៃការទទួលស្គាល់ពិសេស អាចបន្ធូរវិធានទម្រង់ និងវិធានគ្រឹះ ដើម្បីឱ្យរដ្ឋបាលបំពេញបេសកម្មរបស់ខ្លួន។ វាមិនមែនជាការផ្តល់លទ្ធភាពឱ្យថៅក្រមទៅហួសពីច្បាប់ទេ ប៉ុន្តែគឺដើម្បីសម្រប់តម្រូវវិធាននីតិ ទៅនឹងកាលៈទេសៈនៃពេល ដើម្បីឱ្យសេចក្តី សម្រេចចាំបាច់ចំពោះការថែរក្សាផលប្រយោជន៍សាធារណៈអាចចេញបាន តែថាវិធានការទាំងនេះ អាចវិនិច្ឆ័យថា ខុសច្បាប់ក្នុងកាលៈទេសៈធម្មតា។

ប៉ុន្តែ ថៅក្រមមិនមែនគ្មានមធ្យោបាយត្រួតពិនិត្យនោះទេ នៅទីបំផុត គឺថៅក្រមនេះហើយជាអ្នកកំណត់ថា មាន ឬមិនមានកាលៈទេសៈពិសេស។ ការត្រួតពិនិត្យរបស់ថៅក្រម កាន់តែសុក្រឹតឡើង ពីព្រោះថៅក្រមវាយតម្លៃកាលៈទេសៈបែបនេះ តាមការជាក់ស្តែង ហើយមិនមែនដោយរបៀបទូទៅនោះទេលើសពីនេះទៅទៀត បន្ថែមលើការត្រួតពិនិត្យនេះ គឺការត្រួតពិនិត្យខាងនគរបាលរដ្ឋបាល ហើយដែលទាក់ទងទៅនឹងយុត្តិកម្ម និងការសម្របតម្រូវនៃវិធានការដែលចេញ។ ដូច្នេះ ដើម្បីឱ្យស្របច្បាប់ រាល់វិធានការនគរបាលរដ្ឋបាល ត្រូវបញ្ជាក់ដោយការរំខាននៃសណ្តាប់ធ្នាប់សាធារណៈ និងត្រូវសម្របតម្រូវទៅនឹងភាពធ្ងន់ធ្ងរនៃការរំខាននេះ។

នៅក្នុងរឿងក្តី លោកស្រី Dol និង Laurent ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ១៩១៩ កុងសីដេតា បានទទួលស្គាល់និយ័តភាពនៃវិធានការនគរបាល ដូចជាការហាមមិនឱ្យបម្រើដល់ការផឹក ចំពោះនារីសាធារណៈ និងការហាមមិនឱ្យបម្រើផ្លូវភេទ។ ស្ត្រីទាំងពីរនាក់ Dol និង Laurent ប្តឹងសេចក្តីសម្រេច ដោយនិយាយថា វាប៉ះពាល់ដល់សេរីភាពនៃការដើរហើរ។ កុងសីដេតាទទួលយកការកំណត់ព្រំដែនសេរីភាពនេះ ដោយបញ្ជាក់ពីលក្ខណៈពិសេសថា "វាជាសមត្ថកិច្ចរបស់ថៅក្រមដែលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន អំណាចនគរបាលទាំងនេះ ត្រូវធ្វើឡើងដោយពិចារណាដល់ភាពចាំបាច់ ទាញចេញពីស្ថានភាពសង្គ្រាម ទៅតាមកាលៈទេសៈនៃពេល និងទីកន្លែង ប្រភេទបុគ្គលខាងលើ និងប្រភេទគ្រោះភ័យដែលត្រូវបង្ការ ហើយនេះស្ថិតនៅក្នុងការវាយតម្លៃរបស់ថៅក្រម"។

**៣.១.២. អានុភាពនៃកាលៈទេសៈពិសេស**

ទ្រឹស្តីនៃកាលៈទេសៈពិសេស អនុញ្ញាតឱ្យអាជ្ញាធររដ្ឋបាលរួចខ្លួនពីការទទួលខុសត្រូវ។

**៣.២. វិធានធម្មតានៃសមត្ថកិច្ច**

អំណាចចេញបទបញ្ជា អាចធ្វើឡើងក្នុងរង្វង់សមត្ថកិច្ចនៃអំណាចរបស់សភា កាលណាភាពបន្ទាន់ដាក់បង្ខំដល់អំណាចបញ្ជា ហើយសភាមិនអាចប្រជុំបាន (កុងសីដេតា, Ass. 16 April 1948, Heyriès) មន្ត្រីរដ្ឋការ អាចធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព ពីព្រោះមន្ត្រីរដ្ឋការនេះមាននីតិសម្បទាក្នុងការធ្វើ។ កុងសីដេតា ក៏បានទទួលយកផងដែរថា ក្នុងករណីមានភាពខ្វះចន្លោះរបស់អាជ្ញាធររដ្ឋបាល បុគ្គលធម្មតា ក៏អាចជំនួសអាជ្ញាធរនេះបានដែរ ដោយចេញវិធានការនានាទាមទារដោយកាលៈទេសៈ ដូច្នេះបុគ្គលនេះដើរតួនាទីជាមន្ត្រីរដ្ឋការតាមការជាក់ស្តែង។

**៣.៣.វិធានទម្រង់**

សេចក្តីសម្រេចដែលចេញដោយអាជ្ញាធររដ្ឋបាល អាចមានលក្ខណៈជាបទបញ្ជា ឬឯកត្តភូតទៅតាមឋានានុក្រមនៃលិខិតបទដ្ឋាន។

**៣.៤. ការគោរពគោលការណ៍គ្រឹះ**

តាមធម្មតា សកម្មភាពរដ្ឋបាលត្រូវគោរពគោលការណ៍គ្រឹះ ៖ សេរីភាពដើរហើរ សិទ្ធិកម្មសិទ្ធិ សេរីភាពបុគ្គល...។

ប៉ុន្តែ ចៅក្រមរដ្ឋបាល ត្រួតពិនិត្យអង្គសេចក្តី លើវិធានការដែលចេញដោយរដ្ឋបាល ក្នុងក្របខណ្ឌនៃទ្រឹស្តីនៃកាលៈទេសៈពិសេស។ ដំបូង ចៅក្រមត្រួតពិនិត្យអត្ថិភាពនៃកាលៈទេសៈពិសេស ៖ ព្រឹត្តិការណ៍ដែលធ្ងន់ធ្ងរបំផុត ហើយឥតព្រៀងទុក ជាប្រការដែលចែកដាច់ចេញពីកាលៈទេសៈ ពិសេសនៃភាពបន្ទាន់។ ស្ថានភាពនេះត្រូវកើតឡើងនូវកាលបរិច្ឆេទ ដែលសេចក្តីសម្រេចត្រូវបាន ចេញ។ ម្យ៉ាងទៀត ចៅក្រមពីបទរំលោភអំណាច អះអាងថារដ្ឋបាល ពិតជាមិនអាចចេញវិធានការ ដែលស្ថិតក្នុងបញ្ហា ឱ្យបានត្រឹមត្រូវតាមនោះទេ។ នៅទីបញ្ចប់ចៅក្រមរដ្ឋបាល ពិនិត្យឱ្យឃើញថា កិច្ចដែលស្ថិតនៅក្នុងបញ្ហាត្រូវបានចេញក្នុងគោលបំណងនៃផលប្រយោជន៍ទូទៅ ជាពិសេសដើម្បី ធានានិរន្តរភាពរបស់រដ្ឋ ហើយញ៉ាំងឱ្យមានភាពចាំបាច់ដោយកាលៈទេសៈពិសេសនៃពេល។

### ៣.៤.១. របបច្បាប់ដែលរៀបចំកាលៈទេសៈពិសេស

ច្បាប់បារាំង មានអត្ថបទច្បាប់ពីរ ដែលបង្កើនសមត្ថកិច្ចរបស់អាជ្ញាធររដ្ឋបាលនៅក្នុងពេលដែលមានការលំបាកធំៗ៖

ច្បាប់ចុះថ្ងៃទី ០៩ ខែសីហា ឆ្នាំ១៩៤៩ ស្តីពីភាពវិក្រឹតិកាលក៏ដូចជាច្បាប់ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ១៩៥៥ ស្តីពីស្ថានភាពបន្ទាន់។

នៅព្រះរាជាណាចក្រកម្ពុជា មិនទាន់មានអន្តរាគមន៍នៃច្បាប់នេះនៅឡើយ។ វាលែងតែរដ្ឋធម្មនុញ្ញចែងពីគ្រាមានអាសន្ន[២២] និង កាលៈទេសៈពិសេស )[២៣]។

#### ក. វិក្រឹតិកាល[២៤]

ចែងដោយមាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញបារាំង ថ្ងៃទី ០៤ ខែតុលា ឆ្នាំ១៩៥៨ វិក្រឹតិកាល អាចសម្រេចបានតែដោយក្រឹត្យចេញនៅគណៈរដ្ឋមន្ត្រី និងសម្រាប់រយៈពេលអតិបរិមា ១២ ថ្ងៃ។ ផុតរយៈពេលនេះ ការពន្យាពេលនៃវិក្រឹតិកាលត្រូវសម្រេចដោយរដ្ឋសភា។

បង្កើតឡើងដើម្បីប្រឈមទៅនឹងគ្រោះភ័យធំៗ កើតចេញពីសង្គ្រាមឈ្លានពានឬកុប្បកម្មប្រដាប់អាវុធ វិក្រឹតិកាល តម្រូវឱ្យផ្ទេរអំណាចនគរបាលទៅឱ្យអាជ្ញាធរយោធា។ ការជំនួសអាជ្ញាធរស៊ីវិល មានតម្លៃតែចំពោះនគរបាលទូទៅប៉ុណ្ណោះ ហើយមិនមែនចំពោះនគរបាលពិសេសទេ ការជំនួសនេះ ក៏មិនមែនជាស្វ័យប្រវត្តិដែរ ៖ វាកើតឡើងតែក្នុងករណីណា ដែលអ្នកទទួលខុសត្រូវយោធា យល់ឃើញថា វាចាំបាច់ប៉ុណ្ណោះ។ អ្នកទទួលខុសត្រូវយោធាទាំងនេះ អាចអនុញ្ញាតឱ្យអាជ្ញាធរស៊ីវិលធ្វើសកម្មភាពនេះបានតាមប្រតិភូកម្ម។

ការជំនួសអាជ្ញាធរយោធានេះ ត្រូវបញ្ជាក់ផងដែរ ដោយការរឹតត្បិតសេរីភាពសាធារណៈទៅហួសពីអ្វីដែលនីតិរូមអនុញ្ញាត។ ឧទាហរណ៍ សិទ្ធិឆែកឆេរទាំងថ្ងៃទី និងយប់ សិទ្ធិធ្វើឲ្យអ្នកដែលធ្លាប់ជាប់ទោសព្រហ្មទណ្ឌ និងជនដែលគ្មានលំនៅដ្ឋានជាក់លាក់ ចេញឲ្យឆ្ងាយ នៅក្នុងដែនដីដែលដាក់ឱ្យស្ថិតក្នុងវិក្រឹតិកាល សិទ្ធិរឹបអូសអាវុធ និងគ្រាប់រំសេវ សិទ្ធិហាមការប្រជុំគ្នា ដែលនាំឱ្យមានហានិភ័យបាត់បង់សណ្តាប់ធ្នាប់។

[២២]មាត្រា ២២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣។
[២៣]មាត្រា ៨៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣។
[២៤]NORODOM RANARIDDH, DROIT PUBLIC CAMBODGIEN, TOME 1 ,1998។

### ខ. ស្ថានភាពបន្ទាន់

ផ្តល់ទៅឱ្យអាជ្ញាធរស៊ីវិល ក្នុងភូមិសាស្ត្រមួយ ដែលវាត្រូវអនុវត្តន៍នូវអំណាចនគរបាលពិសេស ស្តីពីការតាំងបទបញ្ញាលើចរាចរណ៍ និងការស្នាក់នៅរបស់មនុស្ស លើការបិទទីកន្លែងបើកសម្រាប់ សាធារណៈជន និងស្តីពីការចាប់យកអាវុធ។ របបពិសេសនេះ មិនមានចែងនៅក្នុងច្បាប់ខ្មែរទេ ទាក់ទងទៅនឹងទម្រង់បែបបទនៃការគ្រប់គ្រងវិបត្តិ លើកលែងតែមាត្រា ២២ និង ៨៦ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ (មាត្រា ២២ ៖ *"នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិត នៅក្នុងភាព អាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា។"* មាត្រា ៨៦ ៖ *"ក្នុងកាលៈទេសៈដែលប្រទេសជាតិ រដ្ឋសភាប្រជុំរាល់ថ្ងៃទីជាប្រចាំ។ រដ្ឋសភាមានសិទ្ធិ សម្រេចកាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការអនុញ្ញាត។ បើរដ្ឋសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ជាអាទិ៍ នៅពេលដែលកម្លាំងបរទេសមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។ នៅពេលប្រទេសជាតិឋិតក្នុងភាពអាសន្ន រដ្ឋសភាមិនអាចត្រូវរំលាយបានឡើយ)។"*




(ប្រភពនីត្យានុកូលភាពរដ្ឋបាល)

# ជំពូក ២

# ការត្រួតពិនិត្យនៃសកម្មភាពរដ្ឋបាល

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាត ជាសមត្ថកិច្ចរបស់តុលាការ។ មាត្រានេះ ចែងពីសិទ្ធិរបស់បុគ្គលដែលជាសិទ្ធិរដ្ឋធម្មនុញ្ញ ក្នុងការការពារប្រឆាំងនឹងរាល់ការរំលោភសិទ្ធិ របស់ខ្លួនដោយរដ្ឋបាល។ សិទ្ធិនេះ ក៏ត្រូវពង្រឹងដោយមាត្រា ១២៨ ថ្មី។ មាត្រា ១២៨ ថ្មី *"អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។ អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។"* សិទ្ធិរបស់បុគ្គលនេះ ក៏ត្រូវធានា ដោយសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សដែលមានតម្លៃគតិយុត្តស្មើរដ្ឋធម្មនុញ្ញ[២៥]។

មាត្រា ៨ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស៖

*"ជនគ្រប់រូបមានសិទ្ធិទទួលបាននូវបណ្តឹងជាក់ស្តែងមួយ នៅចំពោះមុខតុលាការជាតិមានសមត្ថកិច្ចប្រឆាំងនូវរាល់អំពើទាំងឡាយណា ដែលរំលោភសិទ្ធិជាមូលដ្ឋាន ដែលត្រូវទទួលស្គាល់ចំពោះខ្លួនដោយរដ្ឋធម្មនុញ្ញ ឬច្បាប់។"*

មានការត្រួតពិនិត្យជាច្រើនត្រូវបានរៀបចំនៅព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានទាំងការ**ត្រួតពិនិត្យមិនមែនតុលាការ និងការត្រួតពិនិត្យតាមផ្លូវតុលាការ** លើសកម្មភាពរដ្ឋបាល។

[២៥] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

# ផ្នែក១
# ការត្រួតពិនិត្យតាមផ្លូវតុលាការ

## កថាខណ្ឌ១ យុត្តិធម៌រដ្ឋបាលៈ ការត្រួតពិនិត្យតាមផ្លូវតុលាការ

អត្ថិភាពនៃតុលាការរដ្ឋបាល ត្រូវពន្យល់បានតាមភាពចាំបាច់ក្នុងការជម្រះក្តី និងត្រួតពិនិត្យរដ្ឋបាល ដើម្បីដោះស្រាយជម្លោះរវាងរដ្ឋបាល និងអ្នកប្រើប្រាស់ (រាស្ត្រប្រជា)។ ក្នុងប្រទេសមួយចំនួន ជាពិសេស ប្រទេសអង់គ្លូសាក់សង់ រដ្ឋបាលត្រូវវិនិច្ឆ័យដូចបុគ្គលដែរ នៅក្នុងតុលាការតែមួយ។ ប៉ុន្តែ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដំណោះស្រាយជម្លោះតាមគោលការណ៍ ត្រូវទទួលបាននៅចពោះមុខសាលាដំបូង ឬ តុលាការនៃនីតិរូម (មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣) ។

ជាទូទៅ រាស្ត្រប្រជាអាចប្តឹងទៅចៅក្រម ពីគ្រប់ជម្លោះទាំងអស់ដែលខ្លួនជំទាស់ទៅនឹងបុគ្គលសាធារណៈ (រដ្ឋ គ្រឹះស្ថានសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ) ឬ នៅក្នុងករណីមួយចំនួន ប្តឹងទាស់អង្គការឯកជនទទួលបន្ទុកសេវាសាធារណៈ។ ការទាមទាររបស់រាស្ត្រប្រជា នៅចំពោះមុខចៅក្រម មានឈ្មោះថា ឧបាស្រ័យវិវាទ ផ្ទុយនឹងបណ្តឹងទៅអាជ្ញាធរចេញសេចក្តីសម្រេច ដែលជាការប្តឹងតវ៉ាទៅរដ្ឋបាលផ្ទាល់។ មូលហេតុដែលអាចនាំឱ្យមានបណ្តឹងបែបនេះមានច្រើន។ អាចជា ៖ ការប្តឹងឱ្យមោឃភាពចោលទាំងស្រុង ឬ មួយផ្នែកនៃសេចក្តីសម្រេចរដ្ឋបាលខុសច្បាប់ ប្តឹងឱ្យរដ្ឋបាលទទួលខុសត្រូវពីព្យសនកម្មទទួលរងដោយរាស្ត្រប្រជា ពោលគឺស្នើសុំឱ្យមានការជួលជុលការខូតខាត។

តុលាការធម្មតាក្តី តុលាការពិសេសក្តី នៅក្នុងរដ្ឋប្រជាធិបតេយ្យ តំណាងឱ្យជម្លោះផលប្រយោជន៍ពីរៈ ការកំណត់ព្រំដែននៃអំណាចរបស់រដ្ឋបាល និងការការពាររាស្ត្រប្រជា។ សម្រាប់ព្រះរាជាណាចក្រកម្ពុជា ការត្រួតពិនិត្យរដ្ឋបាលត្រូវកំណត់ដោយមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ៖

*"...អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។"*

ចំណែកឯប្រទេសដែលមានប្រព័ន្ធច្បាប់ Common Law វិញ ការត្រួតពិនិត្យនេះបានប្រគល់ទៅ ឱ្យតុលាការនៃនីតិរូម។ ការត្រួតពិនិត្យរដ្ឋបាលដោយតុលាការ មានការជឿនលឿនខ្លាំង បើប្រៀបធៀបទៅនឹងការត្រួតពិនិត្យរដ្ឋបាលនៅក្នុងប្រទេស Common Law ប្រព័ន្ធត្រួតពិនិត្យនៅប្រទេសបារាំង។

បារាំងបានបង្កើតតុលាការពិសេស នោះគឺតុលាការរដ្ឋបាល ដែលមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទរដ្ឋបាល។

### កថាខណ្ឌ២ យុត្តិធម៌រដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា ដែលមានប្រពៃណីរាជានិយមផ្តាច់ការ ពីសតវត្សទី១នៃគ្រឹស្តសករាជ ដល់សតវត្សទី១៩ យុត្តិធម៌ស្ថិតនៅក្នុងអំណាចរបស់ព្រះមហាក្សត្រ មានន័យថា អំណាចរបស់រដ្ឋទាំងអស់ ស្ថិតនៅលើព្រះមហាក្សត្រតែអង្គឯង ដែលក្នុងនោះ មានអំណាចតុលាការផង។ ទើបតែមកក្នុង សម័យអាណាព្យាបាលបារាំងប៉ុណ្ណោះ ដែលអំណាចរបស់រដ្ឋត្រូវចែកដាច់ពីគ្នា។ ការដាក់ទណ្ឌកម្ម ចំពោះមន្ត្រីរាជការ អ្នកមុខអ្នកការ ឬ ការប្តឹងទាស់នឹងសេចក្តីសម្រេចរបស់រដ្ឋបាល ត្រូវដោះស្រាយតែដោយព្រះមាហាក្សត្រប៉ុណ្ណោះ។ ទោះជាបារាំង សាកល្បងបញ្ចូលយុត្តិធម៌រដ្ឋបាលមកក្នុងព្រះរាជាណាចក្រកម្ពុជា នៅចុងសតវត្សទី១៩ក៏ដោយ ក៏រឿងនេះ មិនអាចសម្រេចជាសមិទ្ធផលដែរ ដោយសារមូលហេតុចម្បងពីរ គឺមូលហេតុនយោបាយ និងហិរញ្ញវត្ថុ។ ទាក់ទងកនឹងមូលហេតុនយោបាយ គឺថា អ្នកនយោបាយខ្មែរ មិនមានឆន្ទៈចង់ឱ្យតុលាការរដ្ឋបាលកើតឡើងនោះទេ ពីព្រោះវាអាចកាត់បន្ថយអំណាចផ្តាច់ការរបស់ខ្លួន នៅក្នុងករណីដែលផ្ទុត់គំនិតរបស់អ្នកនយោបាយ មិនបានធ្វើការចែកឱ្យដាច់គ្នារវាងនយោបាយ និងរដ្ឋបាល ក៏ដូចតុលាការដែរ។ មូលហេតុហិរញ្ញវត្ថុ ទាក់ទងទៅនឹងថវិការដែលត្រូវយកមកទ្រទ្រង់ការបង្កើតតុលាការ សាលាបណ្តុះបណ្តាលចៅក្រមវិជ្ជាជីវៈសម្រាប់រឿងក្តីរដ្ឋបាល[២៦]។ ដូច្នេះ តាមទម្លាប់តាំងពីបរមកាលមក វិវាទរដ្ឋបាលត្រូវដោះស្រាយ ដោយព្រះរាជសវនការ ដែលមានព្រះមហាក្សត្រជាអ្នកសម្រេច។ ទម្លាប់នេះ ត្រូវអនុវត្តដោយព្រះបាទ សម្តេច**ព្រះនរោត្តម សីហនុ** នៅសម័យសង្គមរាស្ត្រនិយម។ ប៉ុន្តែវាត្រូវបានកាត់ផ្តាច់មួយរយៈធំ នា សម័យខ្មែរក្រហម និងសម័យ សាធារណរដ្ឋប្រជាមានិតកម្ពុជា។ ក្រោយការបោះឆ្នោត ដោយសេរី និងយុត្តិធម៌រៀបចំឡើងដោយអង្គការសហប្រជាជាតិ ជាមួយនឹងការយាងនិវត្តចូលក្នុងប្រទេសវិញ ព្រះបាទសម្តេច**ព្រះនរោត្តម សីហនុ** ក្នុងនាមព្រះអង្គជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គបានផ្សារភ្ជាប់ទម្លាប់នេះឡើងវិញ ដោយអញ្ជើញមន្ត្រីរាជការ អ្នកមុខអ្នកការ ដែលក្នុងនោះមាន រដ្ឋមន្ត្រី អភិបាលខេត្ត ក្រុង និងមន្ត្រីរាជ ការពាក់ព័ន្ធ នៅអង្គុយម្ខាងជ្រុងខាងស្តាំ និង ប្រជារាស្ត្រ ដែលប្តឹង ពីការរំលោភសិទ្ធិដីធ្លីនៅអង្គុយម្ខាងទៀតនៃវេទិការ ជ្រុងខាងឆ្វេង

[២៦] Les aléas de la justice administrative au Cambodge, in Les juridictions et la protection des libertés (au Cambodge, en France et en Thailande.

នៅចំពោះមុខព្រះភ័ក្ត្រ របស់ព្រះអង្គ ព្រះមហាក្សត្រ ព្រះអង្គលើកយកមកអានរឿងក្តីមួយម្តងៗ ហើយព្រះអង្គ លើកនូវសំណើមួយចំនួន ទៅមន្ត្រីរាជការពាក់ព័ន្ធដើម្បីសម្រេច។ ជាទូទៅ គេឃើញថា មន្ត្រីទាំងអស់នោះ តែងតែសម្រេចតាមព្រះរាជសំណើរបស់ព្រះអង្គ ជាប្រយោជន៍ដល់រាស្ត្រដែលជាជនរងគ្រោះ។ ទម្លាប់បែបនេះ មិនបានយូរប៉ុន្មាន (១៩៩៤-១៩៩៥) ក៏ត្រូវបានកាត់ផ្តាច់ទៅវិញ ដោយសារមូលហេតុ មិនច្បាស់លាស់។

នៅឆ្នាំ ១៩៩៥ គម្រោងមួយត្រូវបានបង្កើតឡើង ទាក់ទងទៅនឹងការបង្កើតតុលាការរដ្ឋបាល ប៉ុន្តែ ក្នុងក្របខណ្ឌនៃបទបញ្ញាប៉ុណ្ណោះ ដោយយោងលើមាត្រា ១២៨ ថ្មីនៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។ គម្រោងនេះ ត្រូវបានលិចបាត់ទៅវិញ នៅពេលឯកឧត្តម ចែម ស្ងួន អតីតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ទទួលមរណៈភាព។

រាជរដ្ឋាភិបាល បានដាក់ចេញនូវកំណែទម្រង់នៃប្រព័ន្ធយុត្តិធម៌ នៅព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ រហូតដល់ដំណាក់កាលទី៣។ ប៉ុន្តែ មិនទាន់ឃើញលេចចេញជាសមិទ្ធផលជាក់ស្តែងនៅឡើយ។ តែទោះបីជាយ៉ាងនេះក្តី វិវាទរដ្ឋបាលនឹងត្រូវដោះស្រាយដោយតុលាការនៃនីតិរូម ដោយយោងលើមាត្រា ១២៨ ថ្មី។

មាត្រា ១២៨ ថ្មីនៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ចែងថា *"អំណាចតុលាការជាអំណាច ឯករាជ្យ។*

*អំណាចតុលាការ ធានារក្សាអានាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។*

*អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។*

*អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់"។*

# ផ្នែក ២
# ការត្រួតពិនិត្យមិនមែនតុលាការ

ជាការត្រួតពិនិត្យលើសកម្មភាពរដ្ឋបាលដែលមិនត្រូវធ្វើឡើងដោយចៅក្រម។ ការត្រួតពិនិត្យនេះ អាចជាការត្រួតពិនិត្យ **ផ្ទៃក្នុង ឬ ផ្ទៃក្រៅ**។

## កថាខណ្ឌ ១ ការត្រួតពិនិត្យផ្ទៃក្នុង

ការត្រួតពិនិត្យនេះ ចាំបាច់ចំពោះការតាមដាន ការគោរពច្បាប់ដោយរដ្ឋបាល ហើយការពារនីតិរដ្ឋ ចំពោះរឿងនេះ រដ្ឋបាលមានអង្គការមួយចំនួន ដើម្បីផ្តល់យោបល់ឱ្យខ្លួនៈ ក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា...ប៉ុន្តែធាតុសំខាន់នៃការត្រួតពិនិត្យផ្ទៃក្នុង ទាក់ទងទៅនឹងអំណាចឋានានុក្រម ដែលគេហៅថា ការត្រួតពិនិត្យជាឋានានុក្រម។ ឧទាហរណ៍ ប្រធានឋានានុក្រម អាចកែសម្រួល ឬ លុបចោលកិច្ចទាំងឡាយ របស់ថ្នាក់ក្រោមឱវាទរបស់ខ្លួន ដែលមិនស្រមនីត្យានុកូលភាព ឬ ចេញផ្ទុយទៅនឹងកាលានុវត្តភាព។

### ក. ការត្រួតពិនិត្យតាមរយៈបណ្តឹងរដ្ឋបាល

- ការត្រួតពិនិត្យបណ្តឹងទៅអាជ្ញាធរដែលចេញលិខិត គឺជាបណ្តឹងដែលអាចអនុញ្ញាតឱ្យអ្នកប្រើប្រាស់សេវាសាធារណៈ ឬមន្ត្រីរាជការ ប្តឹងតវ៉ានៅចំពោះមុខអាជ្ញាធរ ដែលជាអ្នកចេញលិខិត ឬ សេចក្តីសម្រេចដែលត្រូវតវ៉ា ដើម្បីសុំឱ្យដកលិខិតនោះចេញវិញ ឬចេញសេចក្តីសម្រេចក្នុងទម្រង់មួយផ្សេងទៀត។ រាល់សេចក្តីសម្រេចរបស់រដ្ឋបាលទាំងអស់ សុទ្ធតែអាចធ្វើជាកម្មវត្ថុនៃបណ្តឹងអធ្យាស្រ័យ។
- បណ្តឹងឋានានុក្រម (ឬបណ្តឹងទៅអាជ្ញាធរអាណាព្យាបាល) ការតវ៉ាត្រូវធ្វើឡើងទៅកាន់អាជ្ញាធរថ្នាក់ខ្ពស់ ជាងអាជ្ញាធរដែលចេញសេចក្តីសម្រេច។ បណ្តឹងឋានានុក្រមនេះ អាចមានអានុភាព បណ្តាលឱ្យមានសេចក្តីសម្រេចថ្មី បញ្ជាក់មូលហេតុត្រឹមត្រូវ ឬមួយដោយសារហេតុផលនៃច្បាប់ ឬមួយដោយសារហេតុផលកាលានុវត្តភាព សុទ្ធតែជាបណ្តឹងមិនមានទម្រង់ច្បាស់ លាស់ទេ គឺជាបណ្តឹងផ្ទៃក្នុងរដ្ឋបាល ប្រភេទបណ្តឹងទាំងនេះសុទ្ធតែអាចធ្វើទៅបានលើកលែងតែមានច្បាប់ហាមឃាត់។

**ខ. ការត្រួតពិនិត្យដោយអាគារធិការកិច្ច**

អង្គអធិការកិច្ច ក៏ចូលរួមផងដែរ ក្នុងការត្រួតពិនិត្យផ្ទៃក្នុង សុទ្ធតែជាអង្គការរដ្ឋបាលដែលមាននៅក្នុងក្រសួងហើយស្ថិតនៅក្រោមរដ្ឋមន្ត្រីផ្ទាល់ ទទួលបន្ទុកត្រួតពិនិត្យសេវា (អាគារធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង)។ យោងតាមអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន ឬ អធិការដ្ឋាន (ខាងក្រៅ) ចំណុះក្រសួង ឬ រដ្ឋលេខាធិការដ្ឋានមានដំណើរការល្អ។ ក្នុងករណីនេះ អាគារធិការដ្ឋាន ឬ អធិការដ្ឋាន មានភារកិច្ចត្រួតពិនិត្យដំណើរការរបស់អង្គភាព និងនាយកដ្ឋានទាំងនេះ ឱ្យស្របតាមគោលច្បាប់ ស្របតាមទិសដៅ និងបទបញ្ជាតបស់ប្រធានស្ថាប័ន។ អាគារធិការដ្ឋាន ឬអធិការដ្ឋាន រាយការណ៍អំពីបេសកកម្មរបស់ខ្លួន ជូនប្រធានស្ថាប័ន ប៉ុន្តែពុំមានសិទ្ធិសម្រេច ជំនួសទេ។ (មាត្រា ១០)

**គ.ការត្រួតពិនិត្យហិរញ្ញវត្ថុ**

ក្រសួង ឬ រដ្ឋលេខាធិការដ្ឋាននីមួយៗ មានអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ។ អភិបាលត្រួតពិនិត្យ ឬ ហិរញ្ញវត្ថុមួយ ឬ ពីរនាក់ជ្រើសរើសក្នុងចំណោមមន្ត្រីរាជការមានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់ តែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការអមក្រសួង និងរដ្ឋលេខាធិការ ដ្ឋាន។

ការត្រួតពិនិត្យហិរញ្ញកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការរដ្ឋទៅតាមក្រសួង រដ្ឋលេខាធិការដ្ឋាន ខេត្ត ក្រុង។ ករណីនេះ អភិបាលត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវរាយការណ៍ភ្លាមនូវបាតុភូតទាំងឡាយ ដែលខ្លួនបានពិនិត្យឃើញជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលខ្លួននៅក្រោមឱវាទ និង ជូនរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការជាប្រធានស្ថាប័នសាមី។

ការត្រួតពិនិត្យហិរញ្ញវត្ថុ គឺជាទិដ្ឋភាពចុងក្រោយនៃការត្រួតពិនិត្យផ្ទៃក្នុងនេះ ការត្រតួពិនិត្យនេះ ធ្វើឡើងដោយតំណាងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អភិបាលហិរញ្ញវត្ថុ ឬ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ)។

**ឃ. ការត្រួតពិនិត្យដោយអភិបាលហិរញ្ញវត្ថុ**

ការត្រួតពិនិត្យផ្ទៃក្នុងរដ្ឋបាល តែងតែធ្វេសប្រហែស លើកលែងតែចំពោះប្រការដែលជាការសិក្សាគតិយុត្តនៃអំណាចឋានានុក្រមប៉ុណ្ណោះ។ តាមធម្មតា ការត្រួតពិនិត្យនេះ ពិបាកជាងគេក្នុងការ

ដឹងឱ្យបានជាក់លាក់។ Jean Rivero : "នៅក្នុងរដ្ឋបាលមជ្ឈការ ថ្នាក់លើមានសិទ្ធិចំពោះ កិច្ចការរបស់ថ្នាក់ក្រោមបង្គាប់អំណាចដ៏ទូលាយបំផុត។ ថ្នាក់លើអាចឱ្យកិច្ចការថ្នាក់ក្រោមធ្វើតាមការបង្គាប់ របស់ខ្លួន ឬ ដាក់ឱ្យកិច្ចរបស់ថ្នាក់ក្រោម ធ្វើតាមការបញ្ជារបស់ខ្លួន។ ក្រោមលក្ខខណ្ឌមួយចំនួនដោយមិនអាចធ្វេសប្រហែសបាន ថ្នាក់លើអាចកែទម្រង់ ឬលុបចោលកិច្ចរបស់ថ្នាក់ក្រោមបង្គាប់មិនត្រឹមតែដោយសារហេតុផលអនីត្យានុកូលភាពប៉ុណ្ណោះទេ ប៉ុន្តែផងដែរ ការការពារខ្លួនយល់ឃើញថាវាជាកាលានុវត្តភាព។ អំណាចទាំងនេះ ថ្នាក់លើមានជាស្វ័យប្រវត្តិ ដោយពុំចាំបាច់មានអត្ថបទចែងប្រគល់សិទ្ធិតួនាទីឱ្យ។ អំណាចទាំងនេះ វាទាក់ទងនឹងតួនាទីរបស់ខ្លួន ក្នុងជួរដែលកំណត់៖ ទោះបីជាធ្វើវិសហមជ្ឈការប៉ះពាល់ដល់អំណាចនេះ បង្គាប់នៅតែស្ថិតនៅក្រោមឋានានុក្រមថ្នាក់លើ និងក្រោមការត្រួតពិនិត្យរបស់ថ្នាក់លើ។ (Rivero et Waline, 1992, p.269) គេអាចបន្ថែមថា វាជាគោលការណ៍រដ្ឋធម្មនុញ្ញ ផលវិបាកផ្ទាល់ចំពោះគោលការណ៍នៃការទទួលខុសត្រូវរបស់រដ្ឋមន្ត្រី។

រដ្ឋបាលថ្នាក់ក្រោមជាតិ ទោះជាត្រូវបានធ្វើវិមជ្ឈការហើយក៏ដោយ ក៏នៅតែស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ (ក្រសួងមហាផ្ទៃ)។ ឧទាហរណ៍ មាត្រា ៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ចែងថា "...ដីកាឃុំសង្កាត់ដែលផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ សន្ធិសញ្ញាអន្តរជាតិ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀត នឹងត្រូវមោឃភាពដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ "នេះជាការត្រួតពិនិត្យមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ លើកិច្ចដែលបានចេញដោយរដ្ឋបាលនេះ ក្នុងកង្វល់ធានាឱ្យបាននូវឯកភាពនៃរដ្ឋបាល។ វិមជ្ឈការ គ្រាន់តែជារបៀបមួយនៃការគ្រប់គ្រងរបស់រដ្ឋទោលដែលតាមនេះ អំណាចកណ្តាល ទទួលស្គាល់ស្វ័យភាពមួយចំនួនចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិប៉ុណ្ណោះ មិនមែនជាការទទួលស្គាល់ឯករាជភាពទេ។

ចំពោះគ្រឹះស្ថានសាធារណៈដែលជាវិមជ្ឈការបច្ចេកទេស មានការត្រួតពិនិត្យនៃអាណាព្យាបាលបច្ចេកទេសផង និងអាណាព្យាបាលហិរញ្ញវត្ថុផង។

មុននឹងសម្រេចកិច្ចការសំខាន់ៗមួយចំនួន គណៈរដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រី ត្រូវពិគ្រោះនឹងក្រុមប្រឹក្សាអ្នកច្បាប់។ រាល់កិច្ចដែលសម្រេចដោយគណៈរដ្ឋមន្ត្រីស្ថិតនៅក្រោមការត្រួតពិនិត្យជាអន្តរក្រសួង។

នៅគ្រប់ក្រសួងទាំងអស់ អាគារធិការដ្ឋាន មានតួនាទីដ៏សំខាន់ក្នុងការត្រួតពិនិត្យកិច្ចការទូទៅរបស់ក្រសួង។ ចំណែកឯនាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញតួនាទីត្រួតពិនិត្យផ្ទៃក្នុងនៃរាល់ប្រតិបត្តិ ការចំណូល ចំណាយ នៃកញ្ចប់ថវិការបស់ក្រសួង។

## កថាខណ្ឌ ២ ការត្រួតពិនិត្យផ្នែកក្រៅ

ការត្រួតពិនិត្យនេះ មានប្រពលភាព និងសារៈសំខាន់ ប្រែប្រួលទៅតាមតួអង្គនៃការត្រួតពិនិត្យ។

**១. ការត្រួតពនិត្យរបស់រដ្ឋលើរដ្ឋបាលស្វយ័ត** (រដ្ឋបាលថ្នាក់ក្រោមជាតិ)

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រកាសមោឃភាពលើដីកាដែលសម្រេចដោយ ឃុំ សង្កាត់ ហើយដែល ផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ សន្ធិសញ្ញា ដែលប្រវាជាណាចក្រកម្ពុជាជាភាគីច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និង លិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតរបស់រដ្ឋ[២៧] ។

ដីកាសម្រេចដោយក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកែប្រែ លុបចោល ដោយ អនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កាលបើដីកាទាំងនេះផ្ទុយទៅនឹង រដ្ឋធម្មនុញ្ញ សន្ធិសញ្ញាអន្តរជាតិ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និង លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋដទៃទៀត[២៨]។

ក្នុងករណីក្រុមប្រឹក្សាអសមត្ថភាព ឬ មិនអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ មានសិទ្ធិរំសាយក្រុមប្រឹក្សា ឃុំ សង្កាត់[២៩]។

ក្នុងករណីដែលក្រុមប្រឹក្សាមិនអាចធ្វើឱ្យសកម្មភាព ឬ សេចក្តីសម្រេចមិនស្របច្បាប់ឱ្យស្រប តាមច្បាប់ឡើងវិញ នៅក្នុងសិទ្ធអំណាចរបស់ខ្លួននោះ ក្រុមប្រឹក្សាត្រូវលុបចោលសកម្មភាព ឬ សេចក្តីសម្រេចមិនស្របច្បាប់នៅក្នុងអង្គប្រជុំរបស់ខ្លួន និងត្រូវផ្សព្វផ្សាយជាសាធារណៈ ពីការ លុបចោលនោះ ។

ជនណា ឬ បុគ្គលណាដែលបានទទួលរងនូវការខូចខាត ឬ បានបង់ពន្ធ ឬ កម្រៃដោយ សារតែសកម្មភាព ឬ សេចក្តីសម្រេចមិនស្របច្បាប់នោះ អាចទាមទារឱ្យក្រុមប្រឹក្សាផ្តល់សំណង និងការបង់ប្រាក់មកវិញឱ្យបានគ្រប់ចំនួន។

ជនណាដែលត្រូវបានក្រុមប្រឹក្សាបដិសេធន៍មិនផ្តល់សំណង ឬ ការបង់ប្រាក់មកឱ្យវិញ នៅក្នុងរយៈពេលពីរ(០២)ខែ ជននោះអាចជូនដំណឹង នឹងអាចប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីសម្របសម្រួលដោះស្រាយ។

ក្នុងករណីដែលជនណា មិនឯកភាពតាមការសម្របសម្រួល ដោះស្រាយរបស់រដ្ឋមន្ត្រីក្រសួង មហាផ្ទៃជននោះមានសិទ្ធិប្តឹងទៅតុលាការ។

[២៧]មាត្រា ៤៩ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ឆ្នាំ ២០០១។
[២៨]មាត្រា ៦០ ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨។
[២៩]មាត្រា ៥៧ និង មាត្រា ៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ឆ្នាំ ២០០១។

ការត្រួតពិនិត្យចំពោះគ្រឹះស្ថានសាធារណៈ ធ្វើឡើងដោយក្រសួងអាណាព្យាបាលបច្ចេកទេស និងអាណាព្យាបាលហិរញ្ញវត្ថុ[៣០]។ ការត្រួតពិនិត្យនេះ អាចមានទម្រង់ពីរ ៖

- **ការត្រួតពិនិត្យនយោបាយ**

ការត្រួតពិនិត្យនេះធ្វើឡើងដោយសភា លើអំណាចអង្គការនីតិប្រតិបត្តិ។

- **ការត្រួតពិនិត្យរដ្ឋបាល**

ការត្រួតពិនិត្យរដ្ឋបាល ធ្វើឡើងដោយអាជ្ញាធររដ្ឋបាលឯករាជ្យ (អ្នកការពារសិទ្ធិប្រជាពលរដ្ឋ)។ គេនិយាយពីការត្រួតពិនិត្យផ្ទៃក្រៅ ពីព្រោះអាជ្ញាធរទាំងនេះ គេចផុតពីរាល់អំណាចឋានានុក្រម។

**ក. ការត្រួតពិនិត្យរបស់សភា**

នៅក្នុងរបបសភានិយម សភាអាចអញ្ជើញសមាជិកណាម្នាក់របស់រាជរដ្ឋាភិបាល ឱ្យឆ្លើយនឹងសំណួរសភាបាន។ មាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញ ១៩៩៣ បានចែងថា "តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល។ សំណួរនេះ ត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា។"

នេះវាជាការទទួលខុសត្រូវជាបុគ្គល ឬជាសមូហភាពនៃរដ្ឋាភិបាលក្នុងរបបសភានិយម។ គណៈកម្មការជំនាញរបស់សភា ត្រួតពិនិត្យផងដែរ សេចក្តីព្រាងច្បាប់ដែលព្រាងបឋម ដោយរដ្ឋបាលកណ្តាល (ក្រសួង)។ បានសេចក្តីថា នៅពេលអនុម័តសេចក្តីព្រាងច្បាប់ ដោយគណៈកម្មការជំនាញ គណៈកម្មការអាចអញ្ជើញតំណាងរដ្ឋាភិបាល តាមរយៈរដ្ឋបាលកណ្តាលឱ្យមកឆ្លើយបំភ្លឺ ទិដ្ឋភាពច្បាប់ និងនយោបាយ ទាក់ទងនឹងសេចក្តីព្រាងច្បាប់។

សភា ក៏ធ្វើការត្រួតពិនិត្យផងដែរ លើមន្ត្រីរាជការ តាមការអនុម័ត ឬមិនអនុម័ត សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

[៣០] ក្រសួងអាណាព្យាបាលបច្ចេកទេស (ក្រសួងនៃការភ្ជាប់ខ្លួន) ក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ (គឺក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ព្រះរាជក្រឹត្យ ចុះថ្ងៃ ៣១ ធ្នូ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តចំពោះគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ព្រះរាជក្រមលេខ ជ/ស/រកម/០៦៩៦/០៣ ច្បាប់ ១៧ មិថុនា ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។

**ខ. ការត្រួតពិនិត្យដោយអាជ្ញាធររដ្ឋបាលឯករាជ្យ**

ការត្រួតពិនិត្យដោយអាជ្ញាធររដ្ឋបាលឯករាជ្យ។ ជាសញ្ញាណមួយដែលចម្លងចេញពីគំរូនៃការត្រួតពិនិត្យរដ្ឋបាល ក្នុងការអនុវត្តច្បាប់នៅប្រទេស ស៊ុយអែត ហៅថា Ombudsman។ អាជ្ញាធររដ្ឋបាលឯករាជ្យ គឺជាស្ថាប័នមួយដែលមិនស្ថិតនៅក្រោមឋានានុក្រមរបស់រដ្ឋមន្ត្រី បំពេញមុខងារឯករាជ្យ ប៉ុន្តែ វាជាផ្នែកមួយទាំងស្រុង នៃរដ្ឋបាលរបស់រដ្ឋ។

អាជ្ញាធរនេះ មានតួនាទីធ្វើរបាយការណ៍ ទទួលពាក្យបណ្តឹងរបស់រាស្ត្រប្រជា ដោះស្រាយដូចតុលាការនៃពាក្យបណ្តឹង សម្របសម្រួល ផ្តល់យោបល់ឱ្យសភា ប្រធានាធិបតី។ បានន័យថា អាជ្ញាធរនេះ អាចប្រើដោយសភា ដោយរដ្ឋបាល។

នៅព្រះរាជាណាចក្រកម្ពុជាយើង មិនទាន់មានការបង្កើតស្ថាប័ននេះនៅឡើយ។

- **អាជ្ញាធររដ្ឋបាលឯករាជ្យ**

ជាភាសាអង់គ្លេស Quango (ស្រដៀងគ្នានឹងអង្គការក្រៅរដ្ឋាភិបាល) គឺជាអង្គការរដ្ឋមួយ ដែលមានឯករាជ្យច្រើន ឬ តិចពីអំណាចអង្គការនីតិប្រត្តិបត្តិ។ ដូច្នេះ គឺជាទម្រង់ពិសេសមួយ នៃអង្គការរដ្ឋបាល ដែលមានដើមកំណើតចេញមកពី Ombudsman របស់ ស៊ុយអែត[៣១]។ ដែលទទួលបាននូវកម្រិតស្វ័យភាព ដ៏ទូលំទូលាយចំពោះនយោបាយ ជាងរដ្ឋបាល Classic អាជ្ញាធររដ្ឋបាលឯករាជ្យតែងតែមានទណ្ឌកម្ម គឺទាំងបទបញ្ជា គឺអ្វីដែលប្រហាក់ប្រហែលគ្នានឹងតុលាការដែរ។ ដោយសារហេតុផលនេះហើយ គេនិយាយផងដែរពីអាជ្ញាធរនិយតកម្ម "Regulatory Authority" តាមន័យអង់គ្លេសនៃពាក្យនិយ័តកម្ម មានន័យស្មើនឹងការតាំងបទបញ្ជា។ ការកំណត់ពិតប្រាកដនៃអ្វីដែល ជាអាជ្ញាធររដ្ឋបាលឯករាជ្យ ឬអ្វីដែលមិនមែនជាអាជ្ញាធររដ្ឋបាលឯករាជ្យ នៅតែមិនច្បាស់លាស់ ដោយហេតុថាគ្មានលក្ខណៈវិនិច្ឆ័យទូទៅភាគច្រើន ទាំងនេះត្រូវបានបង្កើតឡើងជាលក្ខណៈអាដហុក (Ad hoc) ដើម្បីឆ្លើយតបតាមបទពិសោធន៍ជាក់ស្តែង ទៅនឹងប្រភេទមួយចំនួននៃបញ្ហា។ ក្រៅពីភាពខុសគ្នារបស់វា និងភាពខុសប្លែកគ្នានៃឈ្មោះរបស់ភ្នាក់ងារទាំងនេះ ភ្នាក់ងារទាំងអស់ ត្រូវបញ្ជាក់លក្ខណៈដោយឯករាជភាពមិនដាច់ខាត ឬមានស្វ័យភាពចំពោះរដ្ឋាភិបាល។ គំរូរដ្ឋបាលពិសេសនេះ បានរីកចម្រើនយ៉ាងខ្លាំង ចាប់ទសវត្សរ៍ឆ្នាំ ១៩៧០ នៅក្នុងលទ្ធិប្រជាធិបតេយ្យសេរីភាគច្រើន ទោះបីប្រជាធិបតេយ្យខ្លះមានអាយុចំណាស់ជាងគេក៏ដោយ។

[៣១] ឡៅពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ឈើរ ទីមិចត្រុប) ២៣៦។

ពាក្យអាជ្ញាធររដ្ឋបាលឯករាជ្យ ត្រូវបានប្រើដោយសភា ដោយស្តែងចេញច្បាស់លាស់ នៅប្រទេសបារាំង ចាប់តាំងពីការបង្កើតសន្ធានការីនៃសាធារណៈរដ្ឋ ក្នុងឆ្នាំ ១៩៧៣ គណៈកម្មការជាតិ ព័ត៌មានវិទ្យា និងសេរីភាព ប៉ុន្តែ គ្របដណ្តប់ផងដែរ អង្គការប្រហាក់ប្រហែលគ្នាច្រើន ឬ តិច។ ប្រទេសអ៊ីតាលីប្រើពាក្យតែមួយ ដូចនៅក្នុងប្រទេសបារាំង ឧទាហរណ៍៖ គណៈកម្មការឃ្លាំមើលមូលនិធិសោធនបង្កើតឡើងក្នុងឆ្នាំ ១៩៩៣ ប្រទេសអាល្លឺម៉ង់ អេស្ប៉ាញ ឬឥណ្ឌា "អាជ្ញាធរនិយតករទូរគមនាគមន៍ឥណ្ឌា" នៅទីបញ្ចប់ ពាក្យនេះត្រូវចម្លងយកមកប្រើ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន រួមមានអាល់សេរី ថៃឡង់ដ៍។

ដូចគ្នានឹងអាជ្ញាធររដ្ឋបាលឯករាជ្យនៅសហរដ្ឋអាមេរិក គឺភ្នាក់ងារឯករាជ្យ "Regulatory Agencies" ឬ "Independence Regulatory Commission) តួយ៉ាង Interstate Commerce Commission ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៨៨៧ ឬ Food and Drug Administration។ នៅចក្រភពអង់គ្លេស អៀកឡង់ដ៍ ឬនៅអូស្ត្រាលី គេនិយាយពី Quangos។

នៅចក្រភពអង់គ្លេស មានភ្នាក់ងារឯករាជ្យច្រើនប្រភេទ៖ Les quangos (ប្រហាក់ប្រហែលអង្គការក្រៅរដ្ឋាភិបាល) ដែលរាប់បញ្ចូល Press Complaints commission office of communication ឬ Water Services Regulation Authority។ Quangos ខ្លះទៀត ស្រដៀងគ្នាទៅនឹងគ្រឹះស្ថានសាធារណៈផងដែរ (មានបុគ្គលភាពគតិយុត្ត) ប៉ុន្តែ ខុសពីគ្រឹះស្ថានសាធារណៈ មិនអាស្រ័យនឹងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ ឬបច្ចេកទេសទេ។

អង្គការស្វយ័ត (Non-Departmental Public Bodies) ដែលរាប់បញ្ចូល ប៉ុស្តិ៍ BBC, S4C, គណៈកម្មាធិការស្តីពីស្តង់ដារនៃជីវិតសាធារណៈ (Committee on Standards of Public Life) គណៈកម្មការទទួលពាក្យបណ្តឹងនគរបាលឯករាជ្យ (Independence Police Complaints Commission) ឬគណៈកម្មការសមភាព និងសិទ្ធិមនុស្ស (Equality and Human Rights Commission)។

អង្គការមិនមែនក្រសួងរបស់រដ្ឋាភិបាល (N0n-Ministry Government Department) ឧទាហរណ៍៖ ការិយាល័យនិយតកម្មផ្លូវដែក...។ នៅសហរដ្ឋអាមេរិក លោក MiChel Gentot ជាទីប្រឹក្សា និងជាអតីតប្រធានគណៈកម្មការចូលទៅកាន់ឯកសាររដ្ឋបាល ក៏ដូចជាគណៈកម្មការជាតិព័ត៌មានវិទ្យា និងសេរីភាព ចាត់ទុកថា មានតែភ្នាក់ងារឯករាជ្យរបស់សហរដ្ឋអាមេរិកតែប្រាំបីប៉ុណ្ណោះ (ក្នុងនោះមាន គណៈកម្មការទំនាក់ទំនងសហព័ន្ធ (Federal Communications Commission) និង (ភ្នាក់ងារការពារបរិស្ថាន) អាចវាយតម្លៃបានយ៉ាងពិតប្រាកដថាជាអាជ្ញាធររដ្ឋបាលឯករាជ្យ។

នៅព្រះរាជាណាចក្រកម្ពុជា អាចចាត់ទុកថាជាអាជ្ញាធររដ្ឋបាលឯករាជ្យ មានដូចជា អាជ្ញាធរសវនកម្ម ជាតិ (២០០០) អាជ្ញាធរអគ្គីសនីកម្ពុជា (២០០០) និង គ.ជ.ប...(១៩៩៧) ។

### ❖ អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី

នៅក្នុងវិស័យភូមបាលនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានបង្កើតប្រភេទនៃលិខិតបទដ្ឋានគតិយុត្តរដ្ឋបាលសាធារណៈជាច្រើន មានតួយ៉ាងដូចជា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត ...ក្នុងគោលបំណងសម្របសម្រួល និងផ្តល់សេវាសាធារណៈ ដល់រាស្ត្រប្រជា ឱ្យមានប្រសិទ្ធភាព និងតម្លាភាព ស្របតាមកម្មវត្ថុនៃសេវាសាធារណៈ។ ដោយកំណើនប្រជាជនកាន់តែច្រើន និងតម្រូវការគោលនយោបាយនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តម្រូវឱ្យមានការធ្វើសម្បទានដីសង្គមកិច្ច និងសម្បទានដីសេដ្ឋកិច្ច។ ទំនាស់ដីធ្លីក៏មានកាន់តែច្រើនឡើងៗ និងស្ទើរគ្រប់ទីកន្លែង ដោយសារការមិនគោរពនូវវិសាលភាព និងភាពមិនច្បាស់លាស់របស់អ្នកដែលបានទទួលដី។ ត្បិតច្បាប់ភូមិបាល ឬអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច និងសម្បទានដីសេដ្ឋកិច្ច ត្រូវបានបង្កើតឡើងក៏ពិតមែនតែវានៅតែមានភាពខ្វះចន្លោះ និងគ្មានតម្លាភាព មិនស្របទៅតាមកាលានុវត្តភាពក្នុងការអនុវត្តចំពោះវិស័យនេះ។

ដោយមើលឃើញអំពីបញ្ហាទាំងនេះ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមួយ ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ចុះថ្ងៃទីទី២៦ខែកុម្ភៈឆ្នាំ២០០៦។ ការបង្កើតអាជ្ញាធរនេះ គោលបំណងដើម្បីសំរាលបន្ទុកដល់ក្រសួងសាមី (ក្រសួងរៀបចំដែនដីនគរូប នីយកម្ម និងសំណង់) ចំពោះវិស័យនេះ មានសមាសភាពចំនួន២២រូប ដែលក្នុងនោះរួមមានចាប់តាំងពីតំណាងនាយករដ្ឋមន្ត្រីជាប្រធាន រដ្ឋមន្ត្រីក្រសួងសាមី ជាអនុប្រធានទី១ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការក្រសួងពាក់ព័ន្ធមួយចំនួន អគ្គស្នងការនគរបាលជាតិ អគ្គមេញ្ជាការ អគ្គមេញ្ជាការរង មេបញ្ជាការកងទ័ព មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មេធាវីរាជរដ្ឋាភិបាល តំណាងមកពីគណបក្សសមរង្ស៊ី គណបក្សហ៊្វុនស៊ិនប៉ិច និងតំណាងអង្គការក្រៅរដ្ឋាភិបាល សំខាន់ៗដែលពាក់ព័ន្ធ ជាសមាជិក។ ចំពោះសមាសភាពជាក់ស្តែងនឹងត្រូវកំណត់ដោយអនុក្រឹត្យ។ អាជ្ញាធរនេះ មានអគ្គលេខាធិការដ្ឋានជាសេនាធិការ។

អាជ្ញាធរជាតិនេះ មានស្វ័យភាពលើបេសកកម្មតួនាទីនិងភារកិច្ចមួយចំនួនដូចជាៈ

ទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លី តាមរយៈការអប់រំផ្សព្វផ្សាយឱ្យសាធារណជនយល់ដឹងអំពីផលវិបាក បណ្តាលមកពីទំនាស់ដីធ្លី និងមានវិធានការដាក់វិន័យ ចំពោះជនល្មើសដែលបានរំលោភបំពានលើបញ្ហាដីធ្លីដោយខុសច្បាប់ជាធរមាន។ ទទួលសំណុំរឿងទំនាស់ដីធ្លីដែលហួសពីសមត្ថកិច្ច

គណៈកម្មការសូរិយោដីថ្នាក់ជាតិ និងទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធទំនាស់ដីធ្លី។ ឃ្លាំមើល ការដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសូរិយោដី និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការដោះស្រាយទំនាស់ដីធ្លីជូនប្រមុខរាជរដ្ឋាភិបាល។

ដោយឡែក ចំពោះអគ្គលេខាធិការដ្ឋានដែលជាសេនាធិការរបស់អាជ្ញាធរជាតិនេះ មានតួនាទី និងភារកិច្ចដូចជា៖

ទទួល និងពិនិត្យសំណុំរឿងពាក្យបណ្តឹង និងចុះស្វែងយល់ស៊ើបអង្កេត ហើយធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេត ពាក់ព័ន្ធនឹងបញ្ហាទំនាស់ដីធ្លី ដើម្បីដាក់ជូនប្រធានអាជ្ញារធរជាតិដោះស្រាយទំនាស់ដីធ្លី ពិនិត្យសម្រេចតាមដំណាក់កាល និងករណីនីមួយៗ។ រៀបចំការប្រជុំ និងធ្វើកំណត់ហេតុអំពីអង្គប្រជុំរបស់អាជ្ញាធរជាតិនេះ។ ចុះស្វែងយល់ ស៊ើបអង្កេត និងឃ្លាំមើលសកម្មភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី តាមការបញ្ជាណែនាំរបស់ប្រធានអាជ្ញាធរជាតិនេះ បញ្ជូនកំណត់ហេតុ និងភស្តុតាងទាំងអស់ទៅតុលាការ នៅពេលមានការប្តឹងតវ៉ាលើសេចក្តីសម្រេចរបស់អាជ្ញាធរជាតិនេះ ទៅតុលាការ។ រៀបចំ និងតម្កល់ទុកឯកសារពាក់ព័ន្ធទំនាស់ និងបណ្តឹងដីធ្លី រៀបចំសេចក្តីព្រាងរបាយការណ៍ រៀបចំសេចក្តីព្រាងរបាយការណ៍ អំពីសកម្មភាពការងាររបស់អាជ្ញាធរជាតិនេះ ជូនប្រធានអាជ្ញាធរជាតិនេះតាមកាលកំណត់ ដើម្បីរាយការណ៍ជូនប្រមុខ រាជរដ្ឋាភិបាល។ ផ្សព្វផ្សាយជូនសាធារណជនអំពីលទ្ធផលនៃដំណោះស្រាយទំនាស់ដីធ្លី បានដោះស្រាយចប់ជាស្ថាពរ។

ហេតុដូច្នេះ យើងឃើញហើយថា អំណាចសាធារណៈ ត្រូវបានប្រគល់ទៅដល់អាជ្ញាធរជាតិមួយនេះ តាមរយៈបេសកកម្ម តួនាទី និងភារកិច្ចរបស់មន្ត្រីដែលបានតែងតាំង ដើម្បីជាការជួយសម្រួល និងដោះស្រាយទំនាស់ដីធ្លីដែលកើតមាន។ មិនត្រឹមតែប៉ុណ្ណោះ គេក៏ឃើមានការផ្តល់ឱ្យអាជ្ញាធរមានសិទ្ធិដាក់វិន័យផងដែរ ចំពោះជនល្មើស ដែលបានរំលោភបំពាន លើបញ្ហាដីធ្លីដោយខុសច្បាប់ជាធរមាន។

### ❖ មុខងារសាធារណៈ

ចំពោះវិស័យនេះ មន្ត្រីមុខងារសាធារណៈដែលបានកំណត់អំពីបុគ្គលិកលក្ខណៈ ដែលត្រូវជ្រើសរើសឱ្យចូលបម្រើការងារក្នុងក្របខណ្ឌរដ្ឋ បម្រើដល់សេវាសាធារណៈជូនដល់រាស្ត្រប្រជាក្រៅពីវិស័យតុលាការ ដំណើរការនិងការប្រព្រឹត្តិទៅ ត្រូវស្ថិតក្រោមច្បាប់ស្តីពីសបាលក្ខខន្តិកៈម

ន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា តាមព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់លេខ ០៦/នស/៩៤ ដែលត្រូវបានរដ្ឋសភាអនុម័ត នៅ ថ្ងៃទីទី ២១ ខែតុលា ឆ្នាំ ១៩៩៤។

មន្ត្រីសាធារណៈដែលស្ថិតនៅក្រោមច្បាប់នេះ ត្រូវបំពេញតួនាទីរបស់ខ្លួនឱ្យសមស្របតាមច្បាប់ ដែលបានកំណត់ជាធរមាន។

មន្ត្រីដែលបម្រើការនៅក្នុងមុខងាររដ្ឋបាលរបស់ខ្លួន ត្រូវគោរពផងដែរ ចំពោះចំនុចដែលបញ្ញតិអំពីវិន័យ មាត្រា ៣៥ នៅក្នុងច្បាប់នេះដូចជា៖ ហាមយកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្សេងទៀត យកឥទ្ធិពល និងអំណាចនៅក្នុងមុខងាររបស់ខ្លួន ទៅប្រើដើម្បីទាញយកផលប្រយោជន៍អ្វីមួយឬដើម្បីសំឡុត គម្រាមកំហែង បំពានសិទ្ធិពលរដ្ឋ....ហាមការបោះពុម្ពផ្សាយ ឬផ្សព្វផ្សាយពតិមានដែលមានពាក់ព័ន្ធនៅក្នុងមុខងារក្រសួង ដោយពុំមានការអនុញ្ញាតជាមុន ពីប្រធានស្ថាប័ន ដែលសាមីខ្លួននៅក្រោមឱវាទ ឬ ប្រកបមុខរបរបន្ថែមត្រួតលើមុខងាររបស់ខ្លួនជាអ្នករាជការ ក្នុងករណីដែលលក្ខន្តិកៈដោយឡែកនៃអង្គការនីមួយៗហាមឃាត់។ រាល់អំពើបំពាននឹងបទប្បញ្ញត្តិនៃមាត្រានេះអាចបណ្ដាលឱ្យទទួលទណ្ឌកម្មផ្នែកវិន័យណាមួយ ដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ ដោយមិនគិតដល់ការចោទប្រកាន់ជាបទអាជ្ញា ដែលអាចកើតឡើងទៀតផង។

បទប្បញ្ញត្តិទាំងនេះហើយដែលផ្ដល់ឱ្យប្រធានស្ថាប័ន ឬបុគ្គលដែលត្រូវបានកំណត់ថាមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យលើរាល់សកម្មភាពរបស់មន្ត្រីរាជការ នៅក្នុងពេលបំពេញមុខងាររបស់ខ្លួន។ មិនត្រឹមតែប៉ុណ្ណោះ មានថែមផងដែរអំពីទោសខាងផ្នែកព្រហ្មទណ្ឌ ប្រសិនបើការដែលបានប្រព្រឹត្តរបស់មន្ត្រីរាជការនោះ ត្រូវបានគេរកឃើញថា ជាបទល្មើសព្រហ្មទណ្ឌ។

យោងតាមការលើកឡើងខាងលើ អំពីស្ថាប័នសាធារណៈរបស់រដ្ឋទាំងពីរ នេះគឺជាសកម្មភាពដែលអង្គការនីតិប្រត្តិបត្តិធ្វើការត្រួតពិនិត្យសកម្មភាពរដ្ឋបាល តាមរយៈប្រធានស្ថាប័នរបស់ខ្លួនផ្ទាល់ដែលវាស្ថិតនៅក្រៅសមត្ថកិច្ចរបស់តុលាការ ឬ សភា។

# សេចក្តីសន្និដ្ឋាន

នៅក្នុងប្រទេសដែលប្រកាន់យកការដឹកនាំតាមរបៀបម៉ាក្សីស ឬផ្តាច់ការនិយម អ្នកដឹកនាំចូលចិត្តប្រើអំណាចហិង្សា អំណាចកំរោល សង្កត់សង្កិនរាស្ត្រ តាមរយៈច្បាប់ជាក់ស្តែង ដែលអាជ្ញាធររដ្ឋមានសមត្ថកិច្ចជាអ្នកបង្កើត ឬតាមការបញ្ជាដោយផ្ទាល់របស់គេតែម្តង។ សកម្មភាពរបស់អាជ្ញាធរ ពុំត្រូវបានត្រួតពិនិត្យដោយស្ថាប័នឯករាជ្យណាមួយឡើយ។ សកម្មភាពរបស់អាជ្ញាធររដ្ឋ គឺជា "រដ្ឋបាលកិច្ច"។

ការផ្លាស់ប្តូរជាប្រវត្តិសាស្ត្រ នាំឱ្យនីតិរដ្ឋបាល ក៏ដូចជាការដឹកនាំគ្រប់គ្រងប្រទេសមានការវិវត្តផងដែរ។ ព្រះរាជាណាចក្រកម្ពុជាក្រោយឆ្នាំ ១៩៩៣ រាជរដ្ឋាភិបាល បានធ្វើសកម្មភាពជាច្រើន ក្នុងការអភិវឌ្ឍន៍ និងស្តារឡើងលើវិញលើគ្រប់វិស័យ ក្នុងគោលបំណងធ្វើកំណែទម្រង់រដ្ឋឱ្យបានល្អ។ ដើម្បីធានានូវទំនុកចិត្ត ដល់សហគមន៍អន្តរជាតិ និងសុខសន្តិភាពលើផ្ទៃប្រទេសដោយឈរលើគោលការណ៍ប្រជាធិបតេយ្យសេរី ស្របតាមធម្មនិយាមគតិយុត្តជាតិ និងអន្តរជាតិ។

រដ្ឋបាល គឺជាឧបករណ៍ដ៏សំខាន់ ជាដៃជាជើងរបស់អំណាចនយោបាយ ឬអ្នកដឹកនាំ ក្នុងការសម្រេចកិច្ចការទាំងនេះ។ ហេតុដូច្នេះ សកម្មភាពរបស់រដ្ឋបាលនៃប្រទេសដែលគោរពគោលការណ៍ប្រជាធិបតេយ្យសេរី ស្របតាមច្បាប់ ជានីតិរដ្ឋ ត្រូវបានកំណត់យ៉ាងច្បាស់លាស់អំពីព្រំដែននៃអំណាច សកម្មភាព ឱ្យស្របទៅនឹងផលប្រយោជន៍សាធារណៈ និងធានាការពារសិទ្ធិសេរីភាពរបស់ឯកជន។ រាជការ ខិតខំស្វែងរកនូវការបម្រើផលប្រយោជន៍ទូទៅ ឱ្យបានសម្រេចមុនអ្វីៗទាំងអស់។ រាជការ ត្រូវខំប្រឹងប្រែង បំពេញកិច្ចការដោយប្រុងប្រយ័ត្នបំផុត ដើម្បីអភិបាលកិច្ចល្អ មិនខ្ជះខ្ជាយ មិនបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ។

ដោយហេតុថាការបម្រើផលប្រយោជន៍ទូទៅ ជាគោលដៅធំបំផុតរបស់រាជការ រាជការពុំត្រូវគិតអំពីភាពខាត ឬចំណេញទេ ចំពោះកិច្ចខ្លះ ប្រសិនវាជាលក្ខខណ្ឌតម្រូវ ទោះខាតក៏រាជការត្រូវតែធ្វើ។ ឧទាហរណ៍ ៖ (ការចែកអំណោយ និងជួយសង្គ្រោះបន្ទាន់ដល់ប្រជាពលរដ្ឋរងគ្រោះ ចំពោះហេតុការណ៍ប្រធានស័ក្តកើតឡើងម្តងៗ រដ្ឋត្រូវធ្វើគ្រប់មធ្យោបាយ ចំណាយអស់ធនធាន ប៉ុន្មានក៏ត្រូវធានានូវសុខសុវត្ថិភាពរបស់ប្រជាពលរដ្ឋរបស់ខ្លួន នេះហើយជាកាតព្វកិច្ចរបស់រាជការ។

រដ្ឋបាល ជាឧបករណ៍ដ៏សំខាន់នៃអំណាច។ វាមានលក្ខណៈផ្តាច់ការ ដោយរដ្ឋបាលបង្ខំឱ្យបុគ្គលអនុវត្តន៍សេចក្តីសម្រេចរបស់ខ្លួនជាឯកតោភាគី។ ក្នុងករណីរឹងទទឹង រដ្ឋបាលបង្ខំតាម

ការប្រើកម្លាំង ឱ្យបុគ្គលអនុវត្តន៍សេចក្ដីសម្រេចរបស់ខ្លួន។ រដ្ឋ អាចប្រើសេចក្ដីសម្រេចសាធារណៈ ដែលខ្លួនមានភាពផ្ដាច់មុខ ប៉ុន្តែការប្រើកម្លាំងនេះ ក៏ត្រូវគោរពព្រំដែនរបស់វាដែរ មានន័យថា គេបង្ខំ រដ្ឋបាល ឱ្យគោរពវិធានមួយចំនួន ដែលរាស្ត្រប្រជាអាចទាមទារឱ្យមានការគោរពនេះ។ ការជំទាស់នេះ ត្រូវបន្ទន់បន្ថិច ជាមួយនឹងសញ្ញាណនៃរដ្ឋប្រជាធិបតេយ្យ។ វិធាននីតិ មិនចងជើងរដ្ឋបាល ដែលទទួលបាននូវអំណាចវាយតម្លៃដ៏ទូលំទូលាយ លើកាលានុវត្តភាពនៃសកម្មភាពរបស់ខ្លួនទេ ចំពោះរឿងនេះ រដ្ឋបាលមានអំណាចឆន្ទានុសិទ្ធិ (ចេញសេចក្ដីសម្រេច នៅក្រៅវិធានដែលបានរៀបចំ)។ រដ្ឋបាល ក៏មានអំណាចបកស្រាយដ៏ទូលាយដែរ (អំណាចវាយតម្លៃលើវិធាន) ស្របទៅនឹងច្បាប់។

សកម្មភាពទាំងឡាយរបស់រដ្ឋបាល នឹងត្រូវត្រួតពិនិត្យយ៉ាងម៉ត់ចត់ និងតឹងរឹងផងដែរ ដើម្បីធានាថា រដ្ឋបាល មិនធ្វើរំលោភច្បាប់ ឬហួសពីព្រំដែនរបស់ខ្លួន ដោយមធ្យោបាយឆន្ទានុសិទ្ធិ ក្រៅពីច្បាប់បានកំណត់ទុកនោះទេ។ មួយវិញទៀត រដ្ឋបាលក៏ត្រូវគោរពនូវគោលការណ៍នីត្យានុកូលភាពតាមឋានានុក្រម ស្របទៅនឹងតម្លៃគតិយុត្ត។ ការត្រួតពិនិត្យនៃសកម្មភាពរដ្ឋបាល អាស្រ័យទៅតាមប្រទេសដែលប្រកាន់យកប្រព័ន្ធច្បាប់ខុសប្លែកគ្នា (Common Law ឬ Civil Law) ។ តុលាការធម្មតា (នីតិរូម) ក៏មិនចម្លែកទាំងស្រុងពីតុលាការរដ្ឋបាលដែរ។ ជាទូទៅ ស្ថាប័នតុលាការ និង អាជ្ញាធររដ្ឋបាលឯករាជ្យ មានសមត្ថកិច្ចក្នុងការត្រួតពិនិត្យនៃសកម្មភាពរបស់រដ្ឋបាល ឬដាក់ទណ្ឌ ដល់បុគ្គលដែលគេរកឃើញថាបានធ្វើខុស ក្នុងការបំពេញកិច្ចរដ្ឋបាល។

ដោយផលប្រយោជន៍ទូទៅ ត្រូវមានឧត្តមភាពលើផលប្រយោជន៍ឯកជន មធ្យោបាយរបស់រដ្ឋ ដាច់ខាតត្រូវតែធំជាងមធ្យោបាយរបស់ឯកជន។ "ធំ" នៅទីនេះ គេមិនសំដៅលើកត្តាសត្យានុម័តរបស់រដ្ឋបាលនោះឡើយ គឺជាការសំដៅទៅសិទ្ធិអំណាចរបស់រាជការ។

រួមសេចក្ដីមក ជាគោការណ៍ គ្មានទេសមភាពគតិយុត្ត រវាងទំនាក់ទំនងរបស់រាជការនិងរាស្ត្រប្រជា។ ហើយបុព្វសិទ្ធិនៃអំណាចសាធារណៈ ជាមធ្យោបាយសំខាន់មួយ របស់រាជការ សម្រាប់បម្រើគោលដៅធំបំផុតរបស់ខ្លួន គឺផលប្រយោជន៍ទូទៅ។

# ការផ្តល់អនុសាសន៍

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវលើប្រធានមួយនេះ យើងឃើញហើយថា មួយផ្នែកធំនៃនីតិវិធី និងបែបបទក្នុងវិស័យរដ្ឋបាលសាធារណៈរបស់កម្ពុជា គឺបានមកអំពីការបន្សល់ទុករបស់រដ្ឋការបារាំងនៅសម័យអាណានិគមខ្លះ និងមួយផ្នែកបានមកអំពីការសិក្សាស្រាវជ្រាវ របស់អ្នកទស្សនៈវិទូ អ្នកប្រាជ្ញា សាស្ត្រាចារ្យខាងនីតិសាធារណៈ ទាំងជាតិ និងបរទេស តាមរយៈការចងក្រងជាទ្រឹស្តី នូវបច្ចេកទេស និងទម្រង់ផ្សេងៗដែលពួកគាត់គិតថាវាសារៈប្រយោជន៍ ក្នុងការរួមចំណែកអភិវឌ្ឍន៍ដល់វិស័យនេះ ជាពិសេសចំពោះអ្នកនយោបាយ ដើម្បីដឹកនាំក្បាលម៉ាស៊ីនរដ្ឋបាលឱ្យចេញពីការិយាធិបតេយ្យភាព និងការរំលោភដល់សិទ្ធិសេរីភាពជាសារវន្តរបស់រាស្ត្រប្រជា។

ទោះជាយ៉ាងនេះក្តី បច្ចុប្បន្នភាពនៃសកម្មភាពរដ្ឋបាលសាធារណៈ របស់រាជការនៅតែមានកម្រិត ភាពស្រពិចស្រពិល និងពុំសូវមានប្រសិទ្ធិភាព។ ដោយហេតុថា រដ្ឋបាលកិច្ច គឺមានភាពស្មុគស្មាញ ទាំងបច្ចេកទេស និងទម្រង់ ព្រោះវាត្រូវធានានូវគោលការណ៍ពីរ គឺផលប្រយោជន៍ទូទៅ និងសិទ្ធិសេរីភាពជាសារវន្តរបស់បុគ្គលឯកជន។

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទ **"រដ្ឋបាល និង ការគោរពច្បាប់" (ជ្រុងទស្សនៈផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅកម្ពុជា)** និងបានធ្វើការសិក្សាស៊ីជម្រៅទៅលើបញ្ហាការគោរពគោលការណ៍នីត្យានុកូលភាពនៅក្នុងនីតិខ្មែរ បន្ទាប់ពីបានធ្វើការកត់សម្គាល់ពីការយឺតយ៉ាវដោយសារតែការគ្មានប្រាក់ដើម្បីសងការខូចខាតដល់បុគ្គល ក្រោយពីមានការរំលោភនីត្យានុកូលភាព ដោយភ្នាក់ងាររដ្ឋបាល យើងធ្វើអនុសាសន៍ ដល់រដ្ឋនូវអ្វីដូចតទៅៈ

1. បង្កើតឱ្យមានបណ្ដឹងខាងនីតិរដ្ឋបាល
2. រៀបចំឱ្យមានប្រព័ន្ធត្រួតពិនិត្យរឹងមាំ នូវអ្វីដែលទាក់ទងនីតិវិធីរដ្ឋបាល
3. បង្កើតគ្រឹះស្ថាន ឬសាលាដើម្បីតាមដានមើលរាល់បុគ្គលដែលចូលទៅក្នុងរដ្ឋបាល អាចមានមូលដ្ឋានបញ្ញាជាអប្បបរិមាខាងរដ្ឋបាល។
4. ផ្តន្ទាទោសឱ្យបានតឹងរឹងគ្រប់ភ្នាក់ងារ ដែលរំលោភភាពស្របនៃនីត្យានុកូលភាព
5. ត្រូវមានភាពអត់ឱនសូន្យ ចំពោះការខកខានរបស់ភ្នាក់ងាររដ្ឋបាល។
6. រដ្ឋត្រូវមានទីប្រឹក្សាច្បាប់មានសមត្ថភាពពេញលេញ មុននឹងចេញរាល់សេចក្តីសម្រេច។

7. ពិនិត្យមើលឡើងវិញពីការតម្លើងប្រាក់ខែ ដល់មន្ត្រីរាជការ។
8. ត្រូវធានាឱ្យបាន នូវស្វ័យភាពនៃការធ្វើវិមជ្ឈការសេវាសាធារណៈ។
9. ត្រូវធានាពីភាពអាចចូលទៅមើលអត្ថបទច្បាប់យ៉ាងងាយ ដល់ភ្នាក់ងាររដ្ឋបាល។
10. រាជរដ្ឋាភិបាល ត្រូវបង្កើនល្បឿននូវគោលនយោបាយអភិវឌ្ឍន៍វិស័យរដ្ឋបាលសាធារណៈ ឱ្យមានធនធានប្រកបដោយប្រសិទ្ធភាព តាមរយៈការទទួលបានការអប់រំបណ្តុះបណ្តាលយ៉ាងទូលាយទាំងជាតិ និងអន្តរជាតិ ដោយការបញ្ជូន សិស្ស និស្សិត និង មន្ត្រីរាជការសាធារណៈដែលកំពុងប្រត្តិបត្តិនូវក្នុងក្របខណ្ឌនៃមុខងារសាធារណៈ តាមផ្នែក អង្គការ ស្ថាប័ន និងគ្រឹះស្ថានសាធារណៈផ្សេងទៀតរបស់រដ្ឋឱ្យទៅសិក្សា ស្រាវជ្រាវបន្ថែមនៅប្រទេសដែលដើរមុខខាងរដ្ឋបាល សាធារណៈ។
11. រាជរដ្ឋាភិបាល ត្រូវមានគោលនយោបាយច្បាស់លាស់ និង ឆន្ទៈ យ៉ាងពិតប្រាកដ ក្នុងការធានាឱ្យមានឯករាជ្យភាព និងការគោរពនីត្យានុកូលភាពនៃរដ្ឋបាល។ និយាយរួម រដ្ឋបាលសាធារណៈ ត្រូវតែជានីតិស្វយ័ត ដាច់ដោយឡែកពីវិធាននៃនីតិឯកជន។ ឧទាហរណ៍៖ (នីតិរដ្ឋប្បវេណី) ឬនិយាយម្យ៉ាងទៀត រឿងរដ្ឋបាលត្រូវតែមិនមែនជារឿងរដ្ឋប្បវេណី។ តាមរយៈនេះ រាជរដ្ឋាភិបាល គួរបង្កើតនូវលិខិតបទដ្ឋានគតិយុត្តដើម្បីធានាដល់ការអនុវត្តព្រមនឹងទ្រឹស្តី ប្រកបដោយតកវិជ្ជានៃវិទ្យាសាស្ត្ររដ្ឋបាល។
12. ក្នុងករណីកម្ពុជាពុំទាន់មានធនធាន និងលទ្ធភាពគ្រប់គ្រាន់ ក្នុងការបង្កើតតុលាការរដ្ឋបាល ដែលជាតុលាការមួយដាច់ដោយឡែកពីតុលាការនៃនីតិរួម ដូចតាមបណ្តាលប្រទេសនីតិរដ្ឋជឿនលឿនមួយចំនួន កម្ពុជាគួរដាក់ឱ្យមានផងដែរ នូវសភាររដ្ឋបាលមួយនៅសាលាឧទ្ធរណ៍តាមរយៈច្បាប់រៀបចំអង្គការតុលាការ ដើម្បីជាជំហានដំបូងនៃការសិក្សាផង និងជាការផ្តល់នូវដំណោះស្រាយប្រកបដោយបទដ្ឋានខាងឯកទេស នៅក្នុងក្របខណ្ឌគតិយុត្តនៃនីតិរដ្ឋបាល។ ដោយយោងតាមច្បាប់រៀបចំអង្គការតុលាការចំនួនបីដែលរដ្ឋសភាបានពិភាក្សាអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយនោះ គេឃើញមានការបង្កើតឱ្យមានសភាចំនួន ៤ នៅសាលា ឧទ្ធរណ៍ គឺសភាររដ្ឋប្បវេណី សភាព្រហ្មទណ្ឌ សភាការងារ និងសភាពាណិជ្ជកម្ម ដោយឡែកសភា រដ្ឋបាលពុំត្រូវបានបង្កើតឡើងនោះទេ។
13. រាជរដ្ឋាភិបាលខ្លួនឯងផ្ទាល់ ត្រូវបែងចែកឱ្យដាច់ រវាងបញ្ហានយោបាយ និងការផ្តល់ សេវាកម្មសាធារណៈដល់សាធារណជន។ ការនិយមដឹកនាំប្រទេសដោយឈរលើទស្សនៈ "រដ្ឋបក្សនិយម" បន្តិចម្តងៗ នាំឱ្យមានការរើសអើង ខាងការទទួលបានសមភាពសេវាសាធារណៈ

ព្រោះមន្ត្រីសាធារណៈទាំងនោះត្រូវបំពេញកិច្ចដោយគិតគូរអំពីបក្សពួក ឬអ្នកដែលប្រកាន់នយោបាយ ទៅរកបក្សរបស់ខ្លួន ត្រូវមានអាទិភាពជាអ្នកធម្មតា។ ដូច្នេះ រាជរដ្ឋាភិបាលត្រូវញែកឱ្យដាច់ពីគ្នា រវាងការប្រកាន់គណៈបក្សនយោបាយ ឬនិន្នាការនយោបាយ និងការទទួល-ផ្តល់សេវាសាធារណៈ តាមរយៈការបង្កើតកម្មវិធី សិក្ខាសាលាថ្នាក់ជាតិ ឬតាមមូលដ្ឋាន ដើម្បីអប់រំបណ្តុះបណ្តាលដល់ មន្ត្រីសាធារណៈ ឱ្យយល់ដឹងបានកាន់តែទូលំទូលាយ អំពីការអភិវឌ្ឍប្រទេស ដោយសារអភិបាលកិច្ចល្អរបស់រដ្ឋ ជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន សម្រួលដល់វិនិយោគិនបរទេស និងក្នុងស្រុក។

# ឯកសារយោង

## I.ឯកសារច្បាប់ជាតិ


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣។
- អនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ។
- ប្រកាសលេខ ៣១ ប្រ.ក ចុះថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធរដ្ឋបាលខេត្ត ក្រុង។
- ព្រះរាជក្រមលេខ ជ/ស/រកម/០៦៩៦/០៣ ច្បាប់ ១៧ មិថុនា ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។
- ព្រះរាជក្រឹត្យ ចុះថ្ងៃ ៣១ ធ្នូ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តចំពោះគ្រឹះស្ថានសាធារណៈរដ្ឋបាល។
- ច្បាប់ភូមិបាលឆ្នាំ ២០០១។
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ឆ្នាំ ២០០១។
- ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨។


## II.ឯកសារជាសៀវភៅទ្រឹស្តី

### A. ឯកសារជាខេមរភាសា


- **សាយ បូរី**. ២០០១. *នីតិរដ្ឋបាលទូទៅ.* ភ្នំពេញ៖ បណ្ណាគារអង្គរ។
- **ឡើក ពិដោរ**. ២០១០. ទ្រឹស្តីរដ្ឋបាលសាធារណៈ. ភ្នំពេញ៖ ឈើរទីម៉ិចគ្រុប។


### B. ឯកសារជាភាសាបារាំង


- **André de Laubadère**, *Traité de droitadministratif*, éd.15, L.G.D.J., 1999.
- • RenéChapus, *Droitadministratifgénéral*, Tome I, 13ème édition, Montchrestien, 1999.
- • André de Laubadère, J.C. Venezia, Yves Gaudemet, *Traité de droitadministratif*, Tome I, 14ème édition, LGDJ, 1996.

• GeorgesVedel et Pierre Delvolvé, *Droitadministratif*, 2 volumes, 12ème édition, P.U.F, 1992.

•M.Long, P.Weil, G.Braibant, P.Delvolvé, B.Genevois*:Les Grandsarrêts de la jurisprudence administrative*, dit GAJA, Dalloz, 12$^{ème}$édition, 1999: consultation indispensable.

•Dans la collection *Documents d'études*, édités par la Documentation françaisedans le thème Jurisprudence, *Jurisprudence du Conseild'Etat*, n°6.01 à 6.10, de 1988 à 1997: comprend analyses de la jurisprudence de l'annéesuivies d'un choixd'arrêts de l'année (conclusions publiées). [Danscettemême collection ThèmeDroitadministratif, n°2.01 à 2.12: ex: l'administrationterritoriale I et II, le contentieuxadministratif I et II.]

- •*RecueilLebon*, recueil des décisions du Conseild'Etat et du Tribunal des conflits, des arrêts des coursadministrativesd'appel et des jugements des tribunauxadministratifs (1821): 5 fascicules par an, un volume par année, tables: reproduit les arrêts les plus significatifs, par matière, parfois les conclusions des commissaires du gouvernement.

- Revue du droit public et de la science politique en France et à l'étranger, *(RDP)*depuis 1894, bimestrielle.
- L'Actualitéjuridique - droitadministratif, (*AJDA)*, depuis 1945, mensuelle.
- Etudes et Documents du Conseild'Etat, depuis 1947. *(EDCE*): annuel. Actuellement sous le titre Rapport du Conseild'Etatdepuisl'année 1990.
- Revue administrative (*RA*), fondée en 1948, bimestrielle.
- La Revue française de droitadministratif (*RFDA*), fondée en 1984, bimestrielle.

EtaussiRecueilDalloz, Semainejuridique (JCP), Gazette du Palais, Les Petites Affiches…

- <u>*Les actes de colloques:*</u> on citeraprincipalement le colloqueorganiséparl' UniversitéParisII-Panthéon-Assas, en 1988, Conseilconstitutionnelet Conseild'Etat, LGDJ Montchrestien, 1988.
- Imbert (J.) Histoire des InstitiutionsKhmeres. 1961 Edité par E.K.L.I.P,, Phnom Penh,,
- នីតិរដ្ឋបាលបារាំង (Le Droit administrative françis) របស់សាស្ត្រាចារ្យ Guy Braibant.

- Claudu-Gilles GOUR, Institutions constitutionelles et politiques du Cambodge, Paris, Dalloz, 1965, Annexe III, "Statuts du Sangkum Reastr Niyum", pp. 417-424.

- NORODOM RANARIDDH, DROIT PUBLIC CAMBODGIEN, TOME 1, 1998.

C. ឯកសារជាភាសាអង់គ្លេស

- C. J. HAMSON, 1954, EXECUTIVE DISCRETION and JUDICIAL CONTROL. An Aspect of the French Conseild′Etat, London
- William F. Funk and Richard H. Seamon (Dec 9, 2011). Examples & Explanation of Administrative Law.
- Kai Hauerstein, JörgMenzel (Eds.) The Development of Cambodian Administrative Law. Phnom Penh April 2014.

## III.អត្ថបទរបស់អ្នកនិពន្ធ

- F.-H. Lawson, Revue international de droitcomparé 1951 Volume 3. Le droit administrative anglais. pp. 412-426.
- Text: GrégoryMikaelian (Centre Asie du Sud-Est, UMR 8170, CNRS) – Campus Asie 2014, 17-II-2014, Phnom Penh (deltadumekong@yahoo.com).

## IV.Website

- www.toupie.org/Dictionnaire/Pouvoir_discretionnaire.htm
- Exercise-of-discretion-in-admin-decision-making.pdf
- www.google.fr/#q=polizeisstaat